ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



# របាយការណ៍បូកសរុបលទ្ធផល
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០១៨
# និងទិសដៅអនុវត្ត ឆ្នាំ ២០១៩

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ



[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]



[illegible]

# មាតិកា

I.ស្ថានភាពទូទៅ ....................................................................................... 1

II.លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៨ ........................................ 2

១. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ........ 2

ក. ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ដែលសម្រេចបាន ........................ 2

ខ. អនុស្សរណៈនៃការយោគយល់គ្នាដែលបានចុះហត្ថលេខារួច ........................................ 3

គ. សេចក្តីព្រាងច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ................................ 3

ឃ. សន្ធិសញ្ញាកំពុងរៀបចំ ..................................................................... 4

ង. បទដ្ឋានគតិយុត្តកំពុងរៀបចំ .................................................................. 4

២. ការងារបង្ការ ទប់ស្កាត់ .................................................................. 4

២.ក. ការលើកកម្ពស់ការយល់ដឹង ..................................................................... 4

២.ក.១. ការផ្សព្វផ្សាយជាសាធារណៈ ............................................................ 4

២.ក.១.១. ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ................................................ 4

២.ក.១.២. វេទិកាអន្តរសាសនា ................................................................... 5

២.ក.២. ការផ្សព្វផ្សាយតាមរយៈវេទិកា និងកម្មវិធីផ្សេងៗ ........................................ 5

២.ក.២.១. ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ ............................................. 5

២.ក.២.២. ការផ្សព្វផ្សាយតាមរយៈការសម្តែងសិល្បៈ ................................................ 7

២.ក.៣. ការផលិត និងចែកផ្សាយសម្ភារ ឧបករណ៍ និងប្រព័ន្ធផ្សព្វផ្សាយ ............................ 7

២.ក.៣.១. ការបញ្ជ្រាបខ្លឹមសារផ្សព្វផ្សាយ ............................................................ 7

២.ក.៣.២.ការចូលរួមជាវាគ្មិន ........................................................................ 8

២.ក.៣.៣. ការផលិត បោះពុម្ព និងចែកចាយសម្ភារៈអប់រំផ្សព្វផ្សាយ (Information Education and Communication :IEC materials) ................................................ 8

២.ខ. ការបង្ការ ទប់ស្កាត់ តាមវិធានការជំនាញ ....................................................... 9

២.ខ.១. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ ................................ 9

២.ខ.២. ការអប់រំណែនាំ និងតម្រង់ទិស .............................................................10

២.ខ.៣. វិធានការជំនាញទប់ស្កាត់ការធ្វើទេសន្តរប្រវេសន៍ (ចំណាកស្រុក) ............................10

២.ខ.៣.១.ការគ្រប់គ្រងជនបរទេស ...................................................................10

២.គ. ការតាមដានចំណាកស្រុក ...........................................................................11

២.ឃ. វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ ...............12

២.ង. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈអាពាហ៍ពិពាហ៍ទៅក្រៅប្រទេស ....................13
២.ច. កិច្ចការពារកុមារ ....................14
២.ឆ. ការលើកកម្ពស់ជីវភាព កាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន ....................14
២.ជ. ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន ....................15
២.ឈ. ការសិក្សាស្រាវជ្រាវ ....................15
**៣. លើកកម្ពស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស .................... 16**
៣.ក. ការងារអនុវត្តច្បាប់ បង្ក្រាបបទល្មើស ....................16
៣.ក.១.ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ ....................16
៣.ក.១.១.ករណីអំពើជួញដូរមនុស្ស ....................16
៣.ក.១.២.ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ ....................17
៣.ក.២. ការកសាងសំណុំរឿង និងជនសង្ស័យបទល្មើសជួញដូរមនុស្ស បញ្ជូនទៅតុលាការ ....17
៣.ក.៣.ការបង្ក្រាបករណីជួលពពោះជំនួស ដើម្បីនាំទារកឆ្លងដែនខុសច្បាប់ ....................19
៣.ខ.កិច្ចការយុត្តិធម៌ ....................19
៣.ខ.១.លទ្ធផលចំណាត់ការផ្តន្ទាទោស ....................19
៣.ខ.១.១.ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ....................19
៣.ខ.១.២.ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ....................19
៣.ខ.១.៣.ចំណាត់ការរបស់ចៅក្រមជំនុំជម្រះនៃសាលាដំបូង រាជធានី-ខេត្ត ....................20
៣.គ.ការដោះស្រាយករណីវិវាទរវាងពលករទេសន្តរប្រវេសន៍ និងបណ្តាក្រុមហ៊ុននានា ....................20
**៤.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ .................... 20**
៤.ក.ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន(ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ និងការទទួលសាកសព .................... 21
៤.ក.១.ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់ ....................21
៤.ក.២.ការទទួលសាកសពបញ្ជូនត្រឡប់ .................... 23
៤.ខ.ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស .................... 23
៤.គ.ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ .................... 24
**III.ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល .................... 25**
**១.ការបណ្តុះបណ្តាល និងសិក្ខាសាលា .................... 25**
១.ក.ការបណ្តុះបណ្តាល ....................25

១.ក.១.ការបណ្តុះបណ្តាលក្នុងប្រទេស...... 25
១.ក.២.ការបណ្តុះបណ្តាលក្រៅប្រទេស ...... 26
១.ខ.សិក្ខាសាលា ...... 27
១.ខ.១.សិក្ខាសាលាក្នុងប្រទេស ...... 27
១.ខ.២.សិក្ខាសាលាក្រៅប្រទេស ...... 30
២.សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ ...... 30
២.ក.សន្និសីទថ្នាក់ជាតិ និងអន្តរជាតិ ...... 30
២.ខ.កិច្ចប្រជុំ ជាអន្តរជាតិនៅក្នុងប្រទេស និងក្រៅប្រទេស ...... 30
២.គ.ទស្សនកិច្ចសិក្សា...... 33
២.ឃ.ការទទួលជួបពិភាក្សាការងារ ...... 34
៣.ការងារសម្របសម្រួល ......34
IV.ការសន្និដ្ឋានវាយតម្លៃ...... 35
១.ចំណុចខ្លាំង ...... 35
២.ចំណុចខ្វះខាត និងភាពប្រឈម ...... 36
៣.សំណូមពរ...... 36
៤.សន្និដ្ឋាន ...... 36
V.ទិសដៅឆ្នាំ២០១៩ ......37
- ឧបសម្ព័ន្ធ
- កម្រងរូបភាព

# របាយការណ៍បូកសរុប
# សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៨ និងទិសដៅ ឆ្នាំ២០១៩

(គិតចាប់ពីថ្ងៃទី ០១ ខែមករា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨)

## I.ស្ថានភាពទូទៅ

កម្ពុជាបានឆ្លងកាត់គ្រប់ដំណាក់កាល នៃប្រវត្តិសាស្ត្រ និងបានកំណត់ច្បាស់ថា សន្តិភាព ស្ថិរភាពនយោបាយ គឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍គ្រប់វិស័យ។ សមិទ្ធិផលនៃកិច្ចអភិវឌ្ឍន៍របស់ព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេលជិតពីរទសវត្សរ៍កន្លងទៅនេះ គឺជាសក្ខីភាពនៃការសម្រេចបាននូវសមិទ្ធិផលសំខាន់ៗជាច្រើន ក្នុងនោះ ស្ថិរភាពទាំងខាងនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម រួមទាំងការអភិវឌ្ឍន៍សេដ្ឋកិច្ចដែលមានកំណើនថេរក្នុងរង្វង់៧% ក្នុងរយៈពេលពីរទសវត្សរ៍កន្លងទៅនេះ បានធ្វើឲ្យកម្ពុជាអាចឈានទៅដោះស្រាយបញ្ហាប្រឈមទាំងឡាយដោយជោគជ័យ ទោះបីជាត្រូវទទួលរងផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអន្តរជាតិ ការធ្លាក់ចុះសេដ្ឋកិច្ចសកលលោក ឬសង្គ្រាមពាណិជ្ជកម្មពិភពលោកក៏ដោយ។ ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងបាននូវអតិផរណា ស្ថិរភាពនៃអត្រាប្តូរប្រាក់ និងការពង្រឹងសមត្ថភាពប្រកួតប្រជែងសេដ្ឋកិច្ច តាមរយៈការបង្កើនផលិតភាពនៃវិស័យកសិកម្ម ការកសាងមូលដ្ឋានសេដ្ឋកិច្ចជនបទ ការពន្លឿនពិពិធកម្មសេដ្ឋកិច្ចដោយពង្រឹងបរិយាកាសអំណោយផល សម្រាប់ទាក់ទាញកំណើនទេសចរណ៍ ការវិនិយោគឯកជន ទាំងក្នុង និងក្រៅប្រទេស ដើម្បីពង្រីកវិស័យឧស្សាហកម្ម កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និងផ្នែកទន់ ព្រមទាំងការរីកលូតលាស់យ៉ាងឆាប់រហ័សនៃវិស័យសេវាកម្ម ពាណិជ្ជកម្មខ្នាតតូច មធ្យម ធំ ជាដើម បានបង្កើតការងារជូនប្រជាពលរដ្ឋកម្ពុជា ជាពិសេសយុវជនរាប់សែននាក់ក្នុងមួយឆ្នាំៗ ។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាល បានទំនាក់ទំនងស្វែងរកទីផ្សារការងារ និងទីផ្សារផលិតផល នៅក្រៅប្រទេសបន្ថែមទៀត ធ្វើឲ្យអត្រានៃភាពក្រីក្រធ្លាក់ចុះមកត្រឹម១០% និង គម្លាតនៃប្រាក់ចំណូលរបស់ប្រជាជនមានកម្រិតកាន់តែទាប។

ទន្ទឹមនឹងសមិទ្ធិផលជាច្រើនដែលរាជរដ្ឋាភិបាលសម្រេចបាន ក៏មានក្រុមអ្នកធ្វើអាជីវកម្មលើមនុស្ស មិនបានព្រងើយកន្តើយឡើយ ហើយបានរិះរកគ្រប់វិធី ដើម្បីកេងប្រវ័ញ្ចគ្រប់រូបភាពពីស្ថានភាពនៃការធ្វើចំណាកស្រុកទៅក្រៅប្រទេសក៏ដូចជានៅក្នុងស្រុក ដើម្បីជួញដូរមនុស្ស កេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ជួញដូរទារក កុមារ និងជួញដូរសរីរាង្គ ជាដើម ។ល។

ឆ្នាំ២០១៨ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោស ជាបន្តបន្ទាប់ ក្រោមកិច្ចខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ប្រកបដោយកិច្ចសហការល្អ រវាងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធជាសមាជិក គ.ជ.ប.ជ ក៏ដូចជាគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ /គ.ខ.ប.ជ) ហេតុទទួលបានលទ្ធផលគួរឲ្យមោទនៈ ក្នុងការអនុវត្តយុទ្ធសាស្ត្រទាំងបួន គឺការពង្រឹងច្បាប់ គោលនយោបាយ ការងារបង្ការ ទប់ស្កាត់ ការអនុវត្តច្បាប់យុត្តិធម៌ព្រហ្មទណ្ឌ និងកិច្ចការពារជនរងគ្រោះ។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II.លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៨

### ១. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក. ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ដែលសម្រេចបាន

**១. រាជរដ្ឋាភិបាលបានដាក់ចេញ៖**

- គោលនយោបាយលើកកម្ពស់លក្ខខណ្ឌការងារ និងបៀវត្សរ៍កម្មករ កម្មការិនីក្នុងស្រុក ដោយតម្លើងប្រាក់ឈ្នួលអប្បបរមា ១៧០ដុល្លាអាមេរិក (ឆ្នាំ២០១៨) និង ដល់១៨២ដុល្លាអាមេរិក (ឆ្នាំ២០១៩) សម្រាប់កម្មករវាយនភ័ណ្ឌកាត់ដេរ សំលៀកបំពាក់ និងផលិតស្បែកជើង ថែមទាំងអត្ថប្រយោជន៍ផ្សេងៗទៀត ។
- គោលនយោបាយ របបសន្តិសុខសង្គម រួមមានរបបគ្រោះថ្នាក់ការងារ របបថែទាំសុខភាព និងរបបសោធននិវត្តន៍សម្រាប់កម្មករ និយោជិក នៃវិស័យឯកជន។

**២. គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

- ប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ (២០១៨-២០២០) ដើម្បីអនុវត្តច្បាប់ស្តីពី យុត្តិធម៌អនីតិជន ដែលរៀបចំដោយក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**៣. ក្រសួងអប់រំ យុវជន និងកីឡា**

- ប្រកាសឲ្យអនុវត្តគោលនយោបាយ ស្តីពី "កិច្ចការការពារកុមារនៅតាមសាលារៀន"។
- ចេញសេចក្តីសម្រេចលេខ ៣៨ អយក.សសរ ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការបង្កើតក្រុមការងារបង្ការ ទប់ស្កាត់អំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ។
- ចេញសេចក្តីប្រកាសលេខ ១៨៥៩ អយក.ប្រក ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការចាត់តាំងក្រុមការងារបង្ការ ទប់ស្កាត់អំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ។

**៤. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- ដាក់ចេញគោលនយោបាយទេសន្តរប្រវេសន៍ការងារកម្ពុជា ឆ្នាំ២០១៩-២០២៣ និងគោលការណ៍ណែនាំស្តីពីការដោះស្រាយវិវាទរបស់ពលករទេសន្តរប្រវេសន៍។
- ចេញសេចក្តីប្រកាសលេខ ២៣៥ កប/ប្រ.ក.ម.ព ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ស្តីពីលក្ខខណ្ឌការងារ កម្មករការងារផ្ទះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**៥. ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- ប្រកាសអន្តរក្រសួងលេខ ៧១៩ ប្រក ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជណាចក្រកម្ពុជា។

### ខ. អនុស្សរណៈនៃការយោគយល់គ្នាដែលបានចុះហត្ថលេខារួច

- អនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋឥណ្ឌា ស្តីពី **«កិច្ចសហប្រតិបត្តិការសម្រាប់ការងារបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ ការសង្គ្រោះ ការស្តារឡើងវិញ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរ»** នៅថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១៨ នៅទីក្រុងញូដេលី ប្រទេសឥណ្ឌា ដែលមានលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ នៃគ.ជ.ប.ជ ជាតំណាងរាជរដ្ឋាភិបាល។
- អនុស្សរណៈនៃការយោគយល់គ្នារវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ GVC (GRUPPO DI VOLONTARIA TO CIVILE) អង្គការមិនមែនរដ្ឋាភិបាលរបស់អ៊ីតាលី ស្តីពី៖ **«ការគាំទ្រ និងការតស៊ូមតិ លើសិទ្ធិពលករទេសន្តរប្រវេសន៍កម្ពុជា ក្នុងប្រទេសថៃ ក្នុងការបង្ការ ទប់ស្កាត់ ពីការរំលោភបំពានផ្សេងៗ និងអំពើជួញដូរមនុស្ស»** នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨។
- អនុស្សរណៈនៃការយោគយល់គ្នារវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសមាគមមូលនិធិ **ឈាន ឆាយ** ដើម្បីមនុស្សធម៌ ស្តីពី៖ **«ការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសក្នុងចំណោមពលករទេសន្តរប្រវេសន៍នៅប្រទេសថៃ»** នៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១៨។
- សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា (MAC) សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី៖ **«ការសហការការពារពលករកម្ពុជាធ្វើការនៅម៉ាឡេស៊ី»** ជាមួយសមាគមម៉ាឡេស៊ីនៃទីភ្នាក់ងារស្ត្រីជំនួយការមេផ្ទះ (PAPA) សមាគមជាតិធនធានមនុស្សម៉ាឡេស៊ី (PUSMA) និងសមាគមជាតិម៉ាឡេស៊ីទីភ្នាក់ងារការងារ(PIKAP) នៅថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៨ ក្រោមអធិបតីភាព រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅទីស្តីការក្រសួងការងារ។

### គ. សេចក្តីព្រាងច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានបន្តដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងច្បាប់៖
  - ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA)
  - ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានរៀបចំសេចក្តីព្រាង នីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់ការគ្រប់គ្រងករណីមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងប្រទេសថៃ និងកម្ពុជា ស្តីពីដំណើរការគ្រប់គ្រងករណីរួមគ្នាក្នុងគោលបំណងតាមដានការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីចុះហត្ថលេខាជាមួយក្រសួងអភិវឌ្ឍសង្គម និងសន្តិសុខមនុស្ស ប្រទេសថៃ។

### ឃ. សន្ធិសញ្ញាកំពុងរៀបចំ

- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ទ្វេភាគី៖
  - **ស្តីពី "ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" ចំនួន បី គឺ**
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយ៖ (១)សាធារណរដ្ឋប្រជាមានិតឡាវ (២)សាធារណរដ្ឋបារាំង និង(៣)សាធារណរដ្ឋកូរ៉េខាងត្បូង។
  - **ស្តីពីការ "បញ្ជូនទណ្ឌិត" ជាមួយ៖**
    - ✓ (១)ចក្រភពអង់គ្លេស (២)ប្រទេសប៉េរូ និង(៣)សាធារណរដ្ឋប្រជាមានិតឡាវ។
- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International ។

### ង. បទដ្ឋានគតិយុត្តកំពុងរៀបចំ

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីបែបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ២. ការងារបង្ការ ទប់ស្កាត់

### ២.ក. ការលើកកម្ពស់ការយល់ដឹង

#### ២.ក.១. ការផ្សព្វផ្សាយជាសាធារណ:

| ល.រ | ផ្សព្វផ្សាយតាមរយៈ | ចំនួនលើក | ចំនួនអ្នកចូលរួម |
|---|---|---|---|
| ១ | ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ | ២.៨៧៣ | ៩៩១.៤២០ នាក់ |
| ២ | វេទិកាអន្តរសាសនា | ០១ | ១.៥០០ នាក់ |
| ៣ | ការសម្តែងសិល្បៈ | ០១ | ២.០០០ នាក់ |
| ៤ | វេទិកាសាធារណៈ និងភូមិ-ឃុំមានសុវត្ថិភាព | ៦១.៧០០ | ៤.៤៥៧.៨៥១ នាក់ |
| **សរុប** | | **៦៤.៥៧៥** | **៥.៤៥២.៧៧១ នាក់** |

#### ២.ក.១.១. ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- **ថ្នាក់ជាតិ**

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានសហការជាមួយអង្គភាពពាក់ព័ន្ធ និងអង្គការដៃគូដូចជា៖ USAID, WINROCK, The Asia Foundation, UN-ACT, Terre des Hommes, IJM, IOM, APLE, Cambodia Acts...ផលិតសម្ភារផ្សព្វផ្សាយអប់រំ និងទូរទស្សន៍ BTV ដែលបានសហការជាមួយទូរទស្សន៍ PNN ផលិតជាខ្សែវីដេអូ បទយកការណ៍ ស្តីពីអំពើជួញដូរមនុស្ស និងការសម្តែងសិល្បៈចម្រុះរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីបញ្ជ្រាបការយល់ដឹងដល់អង្គពិធីទាំងមូល ក្នុងកម្មវិធីយុទ្ធនាការនៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ លើកទី១២ ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ

ដែលមានអ្នកចូលរួមប្រមាណ៣.០០០អង្គ/នាក់ ជាថ្នាក់ដឹកនាំកំពូលសំខាន់ៗ ក្នុងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ អង្គទូតនានាដែលមាននិវេសនដ្ឋាន នៅកម្ពុជា អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តំណាងផ្នែកសាសនា និយោជិត កម្មករ និយោជក សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ និងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

- **ថ្នាក់ក្រោមជាតិ**

- **លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត** ទាំង ២៥រាជធានី-ខេត្ត និងបានសហការជាមួយអង្គការដៃគូ រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៨ និងផលិតសម្ភារផ្សព្វផ្សាយអប់រំក្នុងយុទ្ធនាការ ដែលមានអ្នកចូលរួមជាថ្នាក់ដឹកនាំ ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធនានា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ សរុបចំនួន **២.៨៧២**លើក មនុស្សប្រមាណ **៩៨៨.៤២០**នាក់ (ស្រី **២៨៣.៧២០**នាក់)។

### ២.ក.១.២. វេទិកាអន្តរសាសនា

- **ថ្នាក់ជាតិ**

- ឆ្នាំ២០១៨ នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយអង្គការ ការីតាស (Caritas) ក្រសួងធម្មការ និងសាសនា និងមេដឹកនាំសាសនាធំៗ នៅកម្ពុជា រៀបចំកម្មវិធីវេទិកាអន្តរសាសនាថ្នាក់ជាតិ លើកទី២ នៅកម្ពុជា ដើម្បីប្រារព្ធពិធីសូត្រធម៌អធិដ្ឋាន និងបញ្ជូនសារតាមបែបសាសនា ក្នុងខ្លឹមសារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ នៅមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្រ ដែលមានអ្នកចូលរួមប្រមាណ**១.៥០០អង្គ**/នាក់។

## ២.ក.២. ការផ្សព្វផ្សាយតាមរយៈវេទិកា និងកម្មវិធីផ្សេងៗ

### ២.ក.២.១. ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ

**ស្ថាប័នថ្នាក់ជាតិ រួមជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ** មន្ទីរ អង្គភាពពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំមានសុវត្ថិភាព**" ការអប់រំផ្សព្វផ្សាយរបស់ក្រសួង ស្ថាប័ន ដល់មន្ត្រីរាជការ អាជ្ញាធរ កម្លាំងសមត្ថកិច្ច សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន **៦១.៧០០**លើក មានអ្នកចូលរួមសរុបចំនួន **៤.៤៥៧.៨៥១**នាក់ (ធៀបនឹងឆ្នាំ២០១៧ មានចំនួន **៤.៩៥៩.៩៣៨**នាក់) ថយចុះចំនួន **៥០២.០៨៧**នាក់ ស្មើនឹង **១០,១២%** (ស្រីចំនួន **២.៣៤៩.០៩១**នាក់)។ ដូចមានតារាងទិន្នន័យខាងក្រោម៖

## តារាងទិន្នន័យការអប់រំផ្សព្វផ្សាយ និងវេទិកាសាធារណៈក្នុងភូមិ-ឃុំមានសុវត្ថិភាព

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| | **ក្រសួង ស្ថាប័ន** | | | | | | |
| ១ | ក្រសួងអប់រំ យុវជន និងកីឡា | ១១ | ១.២០០ | ១១៣ | | | |
| ២ | ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | ៥ | ៣៩.៩១៥ | ១៨.៣០០ | | | |
| ៣ | ក្រសួងកិច្ចការនារី | ៨ | ៦៩៦ | ៣៨៣ | | | |
| ៤ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៥ | ១.៤០០ | | | | |
| ៥ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ៤ | ៣២១ | ១២១ | | | |
| ៦ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៣.១១៤ | ១៩៩.៧៦២ | ១១២.៨៤២ | | | |
| ៧ | កាកបាទក្រហមកម្ពុជា | ១៧ | ២.៣៣០ | ១.៣៥៣ | | | |
| ៨ | សមាគមន៍នារីកម្ពុជាដើម្បី សន្តិភាព និងអភិវឌ្ឍន៍ | ១៧៨ | ១.៦៧០ | | | | |
| | **សរុបអ្នកចូលរួម ក្រសួង ស្ថាប័ន** | ៣.៣៤២ | ២៤៧.២៩៤ | ១៣៣.១១២ | | | |
| | **រាជធានី-ខេត្ត** | | | | | | |
| ១ | រាជធានីភ្នំពេញ | មិនមានរបាយការណ៍ | | | | | |
| ២ | ខេត្តកណ្តាល | ៣.៥៤១ | ៤០៩.១០១ | ២០៣.៤០៧ | ១.៧៩៤ | ៩២.០៧១ | ៤៤.៦១៥ |
| ៣ | ខេត្តបាត់ដំបង | ៧.៤៤២ | ៥៣៣.៣០៩ | ២៧៤.៥០០ | ៣.៩០២ | ១៤១.៤៩៨ | ៧២.៥៦៧ |
| ៤ | ខេត្តពោធិ៍សាត់ | ៤.៩៧៦ | ៨៩១.៧១០ | ៤៩៩.៧៧៩ | ១.៥៩១ | ៩៤.១៨៦ | ៤៩.០២០ |
| ៥ | ខេត្តសៀមរាប | ៣៧៩១ | ២៧៧.៤៦៧ | ១៥៤.៨៤៧ | ៦៨៩ | ២៦.០៨០ | ១៤.៨៩៤ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៥.៩២៧ | ៣០៩.០៣៦ | ១៦៤.៨៨៥ | ៥.៤៥១ | ២១២.៥៤០ | ១១១.២៨៨ |
| ៧ | ខេត្តកំពង់ចាម | ៣.៦៤៤ | ៨០.៨៣៧ | ៤៤.៦០០ | ៣.៩០៨ | ២២៩.៣៧៦ | ១៤៥.៩៦៦ |
| ៨ | ខេត្តព្រះសីហនុ | ២៧៣ | ១៦.៩២៦ | ៨.០០៥ | ១៣៨ | ៨.៥២៨ | ៣.៧៨១ |
| ៩ | ខេត្តព្រះវិហារ | ១៤៧ | ១៥.២១៨ | ៦.៨២៣ | មិនមានរបាយការណ៍ | | |
| ១០ | ខេត្តស្វាយរៀង | ៣០ | ១.៧២៥ | ១.១០៣ | ៣.៣៧២ | ១២៨.៤៤៨ | ៧១.៦៩១ |
| ១១ | ខេត្តប៉ៃលិន | ៦៥៥ | ២៩.៤៦៦ | ១២.៣៣៨ | ៦៨៦ | ២២.៦៦៦ | ៩.៤៥៧ |
| ១២ | ខេត្តកោះកុង | ២០០ | ២៥.៨១៨ | ១១.៥៤២ | ១៥៦ | ៧.៨៦៩ | ៣.៧១០ |
| ១៣ | ខេត្តកំពត | ២១ | ៧២៩ | ៤៧៧ | ១៤៨៤ | ៥៧.០៩៥ | ៣១.៤១០ |
| ១៤ | ខេត្តកំពង់ធំ | ៨៥ | ៣៧.២៥០ | ១៩.៦៦៣ | មិនមានរបាយការណ៍ | | |
| ១៥ | ខេត្តតាកែវ | ៩៤២ | ៥០.៩០៧ | ២៣.៣២២ | ១២១ | ៤.៥៦៥ | ១.៩៤១ |
| ១៦ | ខេត្តក្រចេះ | ២២ | ១.៤៨០ | ១.០៨៩ | ២៥ | ២.៣០០ | ១.៩៥០ |
| ១៧ | ខេត្តកែប | ២០ | ៣៦០ | ២១០ | ៣២៤ | ៥៣.៩៨៧ | ២៦.៣៥៥ |
| ១៨ | ខេត្តកំពង់ស្ពឺ | ២.០៨២ | ៣៥២.៣២០ | ១៧០.៣៥០ | មិនមានរបាយការណ៍ | | |
| ១៩ | ខេត្តស្ទឹងត្រែង | ៦ | ៣៦៣ | ២៤៥ | មិនមានរបាយការណ៍ | | |
| ២០ | ខេត្តរតនគិរី | ១៨៦ | ៣៤.៦១៨ | ៣.៨៣៨ | ២៧៤ | ១៩.២០៦ | ៨.៥០៩ |
| ២១ | ខេត្តព្រៃវែង | ៥ | ៨.៦៤៣ | ២.៥០០ | ៤ | ៦០០ | ៤៥០ |
| ២២ | ខេត្តត្បូងឃ្មុំ | មិនមានរបាយការណ៍ | | | ២១ | ១.០៨៦ | ៦៧៦ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ១១៩ | ២.២១៦ | ១.៦៨១ | មិនមានរបាយការណ៍ | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ១៧ | ៣.១៩២ | ២.០៩៨ | មិនមានរបាយការណ៍ | | |
| ២៥ | ខេត្តមណ្ឌលគិរី | ១៨២ | ២៤.៩៣៩ | ១០.០៨១ | ៥ | ៨២៦ | ៣១៦ |
| | **សរុបអ្នកចូលរួម រាជធានី-ខេត្ត** | ៣៤.៤១៣ | ៣.១០៧.៦៣០ | ១.៦១៧.៣៨៣ | ២៣.៩៤៥ | ១.១០២.៩២៧ | ៥៩៨.៥៨៦ |
| | **សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត** | ចំនួន ៦១.៧០០ លើក | | ចំនួនមនុស្សសរុប ៤.៤៥៧.៨៥១ នាក់ | | ចំនួនស្ត្រី ២.៣៤៩.០៩១ នាក់ | |

### ២.ក.២.២. ការផ្សព្វផ្សាយតាមរយៈការសម្តែងសិល្បៈ

- **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

  នាយកដ្ឋានសិល្បៈនិងទស្សនីយភាព និងមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ បានសម្តែងសិល្បៈជាឈុតល្ខោននិយាយខ្លី ស្តីពីគ្រោះថ្នាក់នៃការជួញដូរមនុស្ស និងគ្រឿងញៀន ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ និងទិវាវប្បធម៌ជាតិ២០១៨ ដល់ប្រជាពលរដ្ឋ មន្ត្រីបុគ្គលិក និងសិស្ស និស្សិតចូលរួមសរុបចំនួន ២.០០០នាក់។

## ២.ក.៣. ការផលិត និងចែកផ្សាយសម្ភារ ឧបករណ៍ និងប្រព័ន្ធផ្សព្វផ្សាយ

### ២.ក.៣.១. ការបញ្ជ្រាបខ្លឹមសារផ្សព្វផ្សាយ

- **ថ្នាក់ជាតិ**
- **ក្រសួងអប់រំ យុវជន និងកីឡា**

  បានសហការជាមួយអង្គការ UNICEF ដាក់បញ្ចូលខ្លឹមសារការកេងប្រវ័ញ្ចផ្លូវភេទ តាមប្រព័ន្ធអ៊ីនធឺណេត(Internet) នៅក្នុងកម្មវិធីសិក្សានៅសាលាបឋមសិក្សា និងមធ្យមសិក្សា ដើម្បីផ្សព្វផ្សាយបន្តដល់កុមារក្រៅសាលារៀន នៅតាមសហគមន៍ ដោយមានការគាំទ្រពីអង្គការ NGORC ។

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

  ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានសហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជា Telecommunication Regulator of Cambodia(TRC) បង្ហោះសារទៅតាមប្រព័ន្ធទូរស័ព្ទចល័ត ទូទាំងប្រទេស ចំនួន ០២សារ៖

  - **ស្តីពីការ " ជួលពពោះជំនួស គឺជាអំពើលក់-ដូរទារក ត្រូវផ្តន្ទាទោសជាដាច់ខាត "**
  - **ស្តីពីការ " អបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ "**

- **ថ្នាក់ក្រោមជាតិ**

- ខេត្តកោះកុង បាត់ដំបង សៀមរាប ព្រះវិហារ ក្រចេះ កំពង់ចាម និងខេត្តកំពត៖ បានលើកយកខ្លឹមសារច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ផ្សព្វផ្សាយតាមប៉ុស្តិ៍វិទ្យុចំនួន១.២៤៤លើក។
- **ខេត្តបាត់ដំបង**

  មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយមជ្ឈមណ្ឌល ធនធានពលករទេសន្តរប្រវេសន៍(MRC) ខេត្តបាត់ដំបង ផ្សព្វផ្សាយការយល់ដឹងតាមរយៈកម្មវិធីវិទ្យុ ស្តីពីការធ្វើទេសន្តរប្រវេសន៍ដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ជនបទ ក្នុងខេត្តបាត់ដំបង និងមួយផ្នែកនៃខេត្តប៉ៃលិន ពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ ។

- **ខេត្តសៀមរាប**

  មន្ទីរព័ត៌មានខេត្ត បានសហការជាមួយស្នងការដ្ឋាននគរបាល អង្គភាពជុំវិញខេត្ត និងអង្គការពាក់ព័ន្ធនានា ផលិតកម្មវិធីសន្ទនាដើម្បីផ្សព្វផ្សាយតាមវិទ្យុជាតិនគរភ្នំយ៉ាងទូលំទូលាយដល់សហគមន៍ អាជ្ញាធរមូលដ្ឋានក្រុង-ស្រុក ឃុំ/សង្កាត់ ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកខុសច្បាប់ និងអំពើហិង្សាក្នុងគ្រួសារ។

- **ខេត្តបន្ទាយមានជ័យ**
សមត្ថកិច្ចនគរបាល និងអង្គការដៃគូ បានបំផុសសកម្មភាពតាមសហគមន៍ដើម្បីលើកកម្ពស់ការយល់ដឹងពីសិទ្ធិកុមារ និងកិច្ចការការពារកុមារ តាមរយៈបណ្ណាល័យចល័ត ស្ពាននីតិសម្បទាចល័ត ភ្នាក់ងារសុវត្ថិភាពកុមារស្ម័គ្រចិត្ត កម្មវិធីវិទ្យុ បង្កើតលេខទូរស័ព្ទសុវត្ថិភាពកុមារបន្ទាន់(០៩៥ ៩៦០ ៣០៣) ការជួបជុំគ្នាជាមួយក្រុមគោលដៅនៅតាមសហគមន៍ និងធ្វើសកម្មភាពអប់រំតាមចិញ្ចើមថ្នល់ ។ល។

## ២.ក.៣.២.ការចូលរួមជាវាគ្មិន

➢ **ក្នុងប្រទេស**

- **ថ្នាក់ជាតិ**

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមផ្តល់បទសម្ភាសន៍៖ នៅស្ថានីយ៍ទូរទស្សន៍បាយ័ន (BTV) និងនៅស្ថានីយ៍ទូរទស្សន៍ NICE (NICE TV) របស់ក្រសួងមហាផ្ទៃ ស្តីពី «**ការស៊ីឈ្នួលពពោះជំនួស ឬការជួញដូរទារកឆ្លងដែន**» និងអំពី «**ស្ថានភាពពលករវិលត្រលប់តាមច្រកទ្វារព្រំដែនអន្តរជាតិ**»។
- **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានចូលរួមជាវាគ្មិននៅវិទ្យុVOD ស្តីពី «**ការធ្វើចំណាកស្រុក និងអំពើជួញដូរមនុស្ស**»។
- **ក្រុមជំនួយកិច្ចការយុត្តិធម៌ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
បានចូលរួមធ្វើជាវាគ្មិនក្នុងកម្មវិធីសម្លេងសមភាពយេនឌ័រ(CCIM) វិទ្យុមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ លើប្រធានបទចំណាកស្រុកប្រកបដោយសុវត្ថិភាព ទាំងក្នុង និងក្រៅប្រទេស និងបញ្ហាប្រឈមផ្សេងៗ ដោយការកេងប្រវ័ញ្ច ការរំលោភបំពាន និងការជួញដូរមនុស្ស។

➢ **ក្រៅប្រទេស**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**
លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានចូលរួមជាវាគ្មិន ក្នុងកិច្ចពិភាក្សាជាសាធារណៈ អំពីបទបញ្ញត្តិនានា និងគោលនយោបាយរវាងកម្ពុជា-ថៃ លើបញ្ហាការជួញដូរមនុស្ស និងពលករអន្តោប្រវេសន៍ នៅមូលនិធិ SEA Junction នាទីក្រុងបាងកក ប្រទេសថៃ។

## ២.ក.៣.៣. ការផលិត បោះពុម្ព និងចែកចាយសម្ភារៈអប់រំផ្សព្វផ្សាយ(Information Education and Communication :IEC materials)

- **ថ្នាក់ជាតិ**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
បានផលិត និងបោះពុម្ពឯកសារ ស្តីពីការណែនាំការធ្វើទេសន្តរប្រវេសន៍ និងការធ្វើការងារដោយភាពវៃឆ្លាត ចំនួន ៧០.០០០ច្បាប់ សម្រាប់ធ្វើការអប់រំ ផ្សព្វផ្សាយដល់អាជ្ញាធរមានសមត្ថកិច្ច អ្នកធ្វើការងារពាក់ព័ន្ធសហគមន៍ និងប្រជាពលរដ្ឋ។
- **ក្រសួងអប់រំ យុវជន និងកីឡា**
បានចែកខិតប័ណ្ណផ្សព្វផ្សាយ ចំនួន ៣.៣៧២សន្លឹក (ព័ត៌មានស្តីអំពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងចំណាកស្រុកប្រកបដោយសុវត្ថិភាព) ដល់ក្រុមគោលដៅ និងប្រជាពលរដ្ឋ

ក្នុងនោះមាន៖ រាជធានីភ្នំពេញ ខេត្តស្វាយរៀង កោះកុង ព្រៃវែង កំពង់ចាម កំពង់ធំ សៀមរាប បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ បានចំនួន ៤២.៣៧២នាក់។

- **ក្រសួងធម្មការ និងសាសនា**

បានសហការជាមួយអង្គការដៃគូ ដែលធ្វើការផ្តោតលើក្រុមកុមាររ័យជំទង់ និងយុវជន បានផលិតគំនូរជីវចល ផ្សព្វផ្សាយតាមរយៈវីដេអូ ស្តីពីការទប់ស្កាត់អំពើហិង្សា និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងការជួញដូរមនុស្សនៅតាមវត្តអារាម និងសហគមន៍ បានចំនួន០៥ រាជធានី-ខេត្ត មាន៖(រាជធានីភ្នំពេញ ខេត្តកណ្តាល ព្រះសីហនុ សៀមរាប និងខេត្តបាត់ដំបង) មានអ្នកចូលរួមចំនួន **៦០អង្គ/នាក់**។

- **ថ្នាក់ក្រោមជាតិ**

- **ខេត្តសៀមរាប**

**មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត** បានចុះចែកសម្ភារសិក្សា ដល់សិស្សានុសិស្ស ចំនួន ៨០នាក់ (ស្រី ៤២នាក់) ក្នុងគម្រោងលុបបំបាត់ពលកម្មកុមារក្នុងវិស័យឡឥដ្ឋ បានចំនួន ០៣លើក នៅក្រុងសៀមរាប ស្រុកសូទ្រនិគម និងស្រុកបន្ទាយស្រី។

- **ខេត្តកំពង់ធំ**

បានចែកខិត្តប័ណ្ណផ្សព្វផ្សាយអប់រំ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋនៅឃុំបន្ទាយស្ទោង និងឃុំសំព្រោច ស្រុកស្ទោង រួមទាំងសមាជិកក្រុមប្រឹក្សាឃុំ សមាជិកភូមិ អនុភូមិ និងមេភូមិ សរុបចំនួន **១៥១**នាក់ (ស្រី **១១១**នាក់)។

- **ខេត្តឧត្តរមានជ័យ**

ការិយាល័យជំនាញសហការជាមួយអធិការកិច្ចក្រុង/ស្រុក ចុះបិទផ្សាយអត្ថបទច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមបណ្តាគោលដៅសំខាន់ៗ មួយចំនួន។

- **ខេត្តកំពង់ស្ពឺ**

បានផលិតបដា ពាក្យស្លោក មួយចំនួនពាក់ព័ន្ធខ្លឹមសារនៃវិធានការច្បាប់ប្រយុទ្ធប្រឆាំង និងអំពើជួញដូរមនុស្ស និងធ្វើការចងបដា ពាក្យស្លោក ទាំងនោះ នៅខាងមុខមន្ទីរ អង្គភាព ស្ថាប័នពាក់ព័ន្ធ និងនៅតាមវិទ្យាល័យនានាទូទាំងខេត្ត។

## ២.ខ. ការបង្ការ ទប់ស្កាត់ តាមវិធានការជំនាញ

### ២.ខ.១. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

- **ថ្នាក់ជាតិ**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- ក្រសួងបានអនុញ្ញាត និងកំណត់ឲ្យទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ចំនួន **១០៣** ធ្វើការជ្រើសរើសពលករខ្មែរ មុនបញ្ជូនទៅធ្វើការងារនៅក្រៅប្រទេស ដោយត្រូវធ្វើការបង្ហាត់បង្រៀនភាសា បណ្តុះបណ្តាលជំនាញបឋម របៀបរបបការងារ ច្បាប់ជាធរមាន របស់ប្រទេសទទួលពលករ លក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅ ទំនៀមទំលាប់ប្រពៃណីនៃពលរដ្ឋប្រទេសទទួល និងត្រូវរៀបចំឯកសារផ្លូវច្បាប់ ក៏ដូចជាឯកសារបញ្ជាក់ទីកន្លែងធ្វើការជាក់លាក់មុននឹងបញ្ជូនពលករមួយលើកៗ ដោយត្រូវនាំពលករទៅដាក់ឲ្យដល់កន្លែងធ្វើការពិតប្រាកដផងដែរ។

- បានចុះធ្វើអធិការកិច្ចទីភ្នាក់ងារឯកជនជាប្រចាំ ដើម្បីពង្រឹងសមត្ថភាព និងតម្រង់ទិសឲ្យទីភ្នាក់ងារជ្រើសរើសឯកជននីមួយៗ គោរពនិងអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ ដើម្បីការការពារ និងលើកកម្ពស់សិទ្ធិពលករខ្មែរនៅក្រៅប្រទេស។
- បានត្រួតពិនិត្យ ផ្សព្វផ្សាយ និងណែនាំ អំពីនីតិវិធីនៃការជ្រើសរើសកម្មករវ័យក្មេង នៅតាមបណ្ដារោងចក្រ សហគ្រាស ដែលមានអ្នកចូលរួមសរុបចំនួន ៤០០នាក់ (ស្រី ២២៩នាក់)។
- បានពង្រឹងផ្នែកមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ការងារ ដែលមាននៅក្នុងនាយកដ្ឋានមុខរបរ និងហាត្ថពលកម្ម និងនៅតាមមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈទាំងនៅរាជធានី និងខេត្តទាំង២៤ សម្រាប់ទទួលពិនិត្យ និងដោះស្រាយវិវាទពលករទេសន្តរប្រវេសន៍ និងការផ្ដល់ប្រឹក្សាយោបល់។
- បានពង្រឹងការការពារ ការលើកកម្ពស់សិទ្ធិ ការបង្ការ ទប់ស្កាត់ ដល់ពលករទេសន្តរប្រវេសន៍ការងារ ជៀសវាងពីការជួញដូរមនុស្ស និងការកេងប្រវ័ញ្ច ត្រូវបានធ្វើឡើងតាមរយៈការពង្រឹងប្រសិទ្ធភាព នៃការផ្ដល់សេវារបស់ទីភ្នាក់ងារជ្រើសរើសឯកជន ការអនុវត្តច្បាប់បទបញ្ញានានាជាធរមាន និងបន្តកិច្ចសហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។

### ២.៥.២. ការអប់រំណែនាំ និងតម្រង់ទិស

- **ថ្នាក់ជាតិ**
  - **ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**
    - បានអប់រំណែនាំ និងតម្រង់ទិសពលករខ្មែរមុនចេញដំណើរទៅធ្វើការនៅក្រៅប្រទេស សរុបចំនួន ៦៨.៥៧១នាក់ (ស្រី ២៨.០៥៤នាក់)។
    - បានអប់រំផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងជាប្រចាំដល់កម្មករ និយោជិក អំពីរបបសន្តិសុខសង្គម និងផ្សព្វផ្សាយឲ្យបានទូលំទូលាយ អំពីទីផ្សារការងារ ការធ្វើអភិបាលកិច្ចដើម្បីជាជម្រើសសម្រាប់ប្រជាពលរដ្ឋក្នុងការធ្វើការងារក្នុងប្រទេស ដើម្បីកាត់បន្ថយភាពប្រថុយប្រថានក្នុងការស្វែងរកការងារ នៅក្រៅប្រទេស។

### ២.៥.៣. វិធានការជំនាញទប់ស្កាត់ការធ្វើទេសន្តរប្រវេសន៍ (ចំណាកស្រុក)

#### ២.៥.៣.១.ការគ្រប់គ្រងជនបរទេស

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

**អគ្គនាយកដ្ឋានអន្តោប្រវេសន៍** មានវិធានការគ្រប់គ្រងជនបរទេស ដែលស្នាក់នៅ និងធ្វើការខុសច្បាប់នៅកម្ពុជា និងបានអនុវត្ត ដូចខាងក្រោម៖

១. <u>ការងារអនុវត្តនីតិវិធី និងការបណ្ដេញចេញជនបរទេសខុសច្បាប់</u>

ក.លទ្ធផលរយៈពេលពេញមួយឆ្នាំនេះ បានរកឃើញ និងឃាត់ខ្លួនជនបរទេសល្មើសច្បាប់ចំនួន ១.៣៤៨នាក់ មាន ៥២សញ្ជាតិ (ភាគច្រើន៖ ជនជាតិចិន ៩៥០នាក់ វៀតណាម ២០៩នាក់ នីហ្សេរីយ៉ា ១០៨នាក់ អាមេរិក ១៨នាក់ កូរ៉េខាងត្បូង ១៧នាក់ (តែ៤៧សញ្ជាតិទៀត ពុំបានដាក់បញ្ចូលទេព្រោះមានមនុស្សតែ ចំនួន ៤៦នាក់)។

ខ.<u>ប្រភេទបទល្មើស និងចំនួនជនបរទេសល្មើសច្បាប់:</u> មនុស្សចំនួន ១.១២៦នាក់ (ក្នុងនោះមានតែ៤១៥នាក់ នៅក្នុង០៦ចំណុចខាងក្រោមប៉ុណ្ណោះ ពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស) មានដូចជា៖

- ជនបរទេសស្នាក់នៅ និងធ្វើការខុសច្បាប់៖ មានចំនួន **១៧៧**នាក់ ស្មើនឹង **២០**សញ្ជាតិ ហើយត្រូវបានបណ្តេញចេញពីប្រទេស។
- ស្នាក់នៅលើសទិដ្ឋាកាកំណត់៖ មានចំនួន **៨៦**នាក់ ស្មើនឹង **២២**សញ្ជាតិ ហើយត្រូវបានបណ្តេញចេញពីប្រទេស។
- ស្នាក់នៅខុសច្បាប់គ្មានឯកសារចំនួន **១៤៧**នាក់ស្មើនឹង **២១**សញ្ជាតិ។
- ជួញដូរផ្លូវភេទ៖ ០១ករណី មនុស្ស ០២នាក់ ជនជាតិវៀតណាម (នៅព្រះវិហារ) កសាងសំណុំរឿងបញ្ជូនទៅតុលាការ។
- ជួញដូរមនុស្សឆ្លងដែន៖ ០១ករណី មនុស្ស ០១នាក់ ជនជាតិម៉ាឡេស៊ី បញ្ជូនចេញពីប្រទេស។
- រៀបអាពាហ៍ពិពាហ៍ខុសច្បាប់៖ ០២ករណី មនុស្ស០២នាក់ (ជនជាតិអាមេរិក ០១នាក់ និងថៃ ០១នាក់)។

២. **កំណត់បទល្មើសស្នាក់នៅខុសច្បាប់**

បានឃាត់ខ្លួនជនបរទេសល្មើសច្បាប់ចំនួន **១.៣៤៨**នាក់ មាន **៥២**សញ្ជាតិ (ភាគច្រើនជនជាតិចិន **៩៥០**នាក់ វៀតណាម **២០៩**នាក់ នីហ្សេរីយ៉ា **១០៨**នាក់ អាមេរិក **១៨**នាក់ កូរ៉េខាងត្បូង **១៧**នាក់ ...)។

៣. **ការងារចុះផ្តល់ឯកសារជ្របាលកម្ពុជាមិនប្រក្រតី**

អនុវត្តអនុក្រឹត្យលេខ១៩២ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ ស្តីពីការដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ដែលជនបរទេសកំពុងកាន់កាប់ប្រើប្រាស់ ក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃបានចាត់វិធានការដកហូតបានចំនួន ៣៥.០០១ឯកសារ ស្មើនឹង ៨៨,៧៩% និងកំពុងខិតខំអនុវត្តបន្តសំដៅបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០១៩។

## ២.គ. ការតាមដានចំណាកស្រុក

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិបានធ្វើបច្ចុប្បន្នភាពលើទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស ប្រចាំខែនីមួយៗ បានពិនិត្យឃើញថា នៅតែបន្តកើតមានឡើង ជាក់ស្តែងឆ្នាំ២០១៨ នេះ មានតួលេខ ដូចខាងក្រោម៖

***តារាងតាមដានបច្ចុប្បន្នភាពលើទិន្នន័យពលករខ្មែរចំណាកស្រុក***

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| មករា | ៣០០.០៧៧ | ១២៧.៧៤៩ | ៨.៤៧៨ | ៣.១៦៥ | ១៦៨.០៤២ | ៧៤.៦៣៥ | ៩៥៦ | ៤២៧ | ១៣២.០៣៥ | ៥៣.១១៤ | ៧.៥២២ | ២.៧៣៨ | ថយចុះ ២១.៥២០ |
| កុម្ភៈ | ២៨៨.៧៦៣ | ១២៦.៨២៩ | ៨.៥១៣ | ៣.១៦៦ | ១៥៧.១៤៧ | ៧៣.៦៥៨ | ៩៩៧ | ៤២៧ | ១៣១.៦១៦ | ៥៣.១៧១ | ៧.៥១៦ | ២.៧៣៩ | ថយចុះ ១១.៨១៤ |
| មីនា | ២៦០.២២៨ | ១១៤.១២៩ | ៦.៨៨០ | ២.៤៧៩ | ១៥៥.៣៧៧ | ៧០.៩៩៥ | ៤២៨ | ១៥៣ | ១០៤.៨៥១ | ៤៣.១៣៤ | ៦.៤៥២ | ២.៣២៦ | ថយចុះ ២៨.០៣៥ |
| មេសា | ៣២២.៨៦៧ | ១៤៧.៩៥៨ | ៩.០៥០ | ៣.៥០៨ | ១៨៣.០៦៤ | ៩១.៦៤៨ | ១.៨០៦ | ៧៧៦ | ១៣៩.៨០៣ | ៥៦.៣៩០ | ៧.២៤៤ | ២.៧៣២ | កើនឡើង ៦២.៦៣៩ |
| ឧសភា | ៣២២.៨៩៩ | ១៤៧.៩១២ | ៧.៨៧៨ | ២.៩៧៨ | ១៨៣.៧៥៥ | ៩១.៤៥០ | ៦១៩ | ២៥៣ | ១៣៩.១៤៤ | ៥៦.៤២៦ | ៧.២៥៩ | ២.៧២៥ | កើនឡើង ២២ |
| មិថុនា | ៣៤២.៣៩២ | ១៥៣.១៩៤ | ៩.០៥៦ | ៣.៣៦៧ | ១៩២.៤៧២ | ៨៨.៦៩៥ | ៦៥២ | ២៧៦ | ១៤៩.៩២០ | ៦៤.៤៩៩ | ៨.៤០៤ | ៣.០៩១ | កើនឡើង ១៩៤៩៣ |
| កក្កដា | ៤០៥.៨៥៣ | ១៥៦.៩១២ | ៨.៤៤៥ | ២.៧៥១ | ១៩៧.២១០ | ៩០.៧០៩ | ៦៥២ | ២៧៦ | ២០៨.៦៤៣ | ៦៦.៩០៣ | ៧.៧៩៣ | ២.៤៧៥ | កើនឡើង ៦៣.៤៦១ |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សីហា | ៣១១.៧៨៦ | ១៥៩.១២៤ | ១១.០២០ | ៤.២៥២ | ១៩៥.៣៧៦ | ៩០.៨៦៥ | ២.១០០ | ៩៤០ | ១១៦.៤១០ | ៦៨.៦៥៩ | ៨.៩២០ | ៣.៣០២ | ថយចុះ ៩៤.០៦៧ |
| កញ្ញា | ៣៦២.៤៥៩ | ១៥៩.៧៨៦ | ៩.៤៨៨ | ៣.៤៨០ | ១៩៨.២៦៥ | ៩១.៦៧១ | ៦៥៣ | ២៧៧ | ១៦៤.២៣០ | ៦៨.០៧៥ | ៨.៨៣៥ | ៣.៣០៣ | កើនឡើង ៥០.៧០៩ |
| តុលា | ៣៦១.១៥១ | ១៦១.៤៤០ | ៩.៤២៧ | ៣.៤៥២ | ១៩៩.៩០៥ | ៩៥.០៥៩ | ៦៥៣ | ២៧៧ | ១៦១.២៤៦ | ៦៦.៣៤១ | ៨.៧៧៤ | ៣.២៦៥ | ថយចុះ ២.២៦០ |
| វិច្ឆិកា | ៣៧០.១៧០ | ១៦០.២១១ | ៩.៣៨៦ | ៣.៥១១ | ២០៨.៣២៩ | ៩៣.៨០៩ | ៦៥៣ | ២៧៧ | ១៦១.៨៤១ | ៦៦.៤០២ | ៨.៧៣៣ | ៣.២៣៤ | កើនឡើង ២,៤៧ |
| ធ្នូ | ៣៧១.៤៨៣ | ១៦១.០៦៦ | ១០.៦៨៣ | ៤.១៥៦ | ២១០.០៦១ | ៩៥.២៤៨ | ១.៩៨៩ | ៩០៧ | ១៦១.៤២២ | ៦៥.៨១៨ | ៨.៦៩៤ | ៣.២៤៩ | កើនឡើង ៤៩,៨៨៧ |

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

- **ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង៖**

  ស្នងការដ្ឋាននគរបាលខេត្ត និងវរៈនគរបាលការពារព្រំដែនគោកលេខ ៨១៧ ៨១៩ ៨២៣ ៣១០ បានធ្វើការទប់ស្កាត់ពលករខ្មែរ ដែលបម្រុងធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ សរុបចំនួន **០៤**លើក មនុស្សចំនួន **១៣៩**នាក់ (ស្រី **៦៣**នាក់)។

## ២.ឃ. វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ជាសេនាធិការ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត(ខេត្តកំពត តាកែវ កែប មណ្ឌលគិរី ព្រះសីហនុ កោះកុង ក្រចេះ ឧត្តរមានជ័យ ស្វាយរៀង កណ្តាល រតនគិរី សៀមរាប ស្ទឹងត្រែង ពោធិ៍សាត់ កំពង់ធំ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តបន្ទាយមានជ័យ) បានធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម៖

**ការធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តបទល្មើសសញ្ញាកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា និងខារ៉ាអូខេ៖**

| ឆ្នាំ២០១៨ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិយាយ | ខែមករា | ខែកុម្ភៈ | ខែមីនា | ខែមេសា | ខែឧសភា | ខែមិថុនា | ខែកក្កដា | ខែសីហា | ខែកញ្ញា | ខែតុលា | ខែវិច្ឆិកា | ខែធ្នូ |
| គោលដៅ | ៨០២ | ៥២៣ | ៦១១ | ៤២១ | ២៧៤ | ៤៩៨ | ៥២៥ | ៥៩៣ | ៦៥៩ | ៣៧៥ | ៦៨៦ | ៥៦៥ |
| ចំនួនមនុស្ស | ២.២៣៥ | ១.៧៥៣ | ២.០៣៧ | ១.៨៤៥ | ៩៣៩ | ២.១៩៤ | ២.៦១៦ | ២.២៥៦ | ២៦.១៧៨ | ១.៦៦២ | ១៨.៨៣៧ | ១.៣៣៨ |

- កំណត់គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន **៦៦**គោលដៅ សរុបចំនួន**៧៥**គោលដៅទូទាំងរាជធានី-ខេត្ត។
- ល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន ៣៤៦លើក ក្នុងនោះមាន៖ ខេត្ត កែប ព្រះវិហារ មណ្ឌលគិរី កំពង់ធំ កំពង់ស្ពឺ ឧត្តរមានជ័យ ក្រចេះ ស្ទឹងត្រែង ព្រៃវែង និងខេត្តស្វាយរៀង ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ**

| ស្នងការដ្ឋាន រាជធានី ខេត្ត | ឆ្នាំ២០១៨ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខែមករា | ខែកុម្ភៈ | ខែមីនា | ខែមេសា | ខែឧសភា | ខែមិថុនា | ខែកក្កដា | ខែសីហា | ខែកញ្ញា | ខែតុលា | ខែវិច្ឆិកា | ខែធ្នូ |
| | ២៤ លើក | ២២ លើក | ២២ លើក | ២២ លើក | ២១ លើក | ២២ លើក | ៣៥ លើក | ៣៣ លើក | ២៤ លើក | ៤០ លើក | ៤១ លើក | ៤០ លើក |
| សរុប | ៣៤៦លើក | | | | | | | | | | | |

- **រាជធានី ខេត្ត**
- **ខេត្តសៀមរាប៖**
- **រដ្ឋបាលក្រុងសៀមរាប**

បានធ្វើការដឹកនាំ និងជំរុញឲ្យមន្ត្រីក្រោមឱវាទ ចុះពិនិត្យតាមបណ្តាភូមិ និងប៉ុស្តិ៍រដ្ឋបាល ទាំង ១២សង្កាត់ ដែលមានប្រជាការពារសរុប ៧១ក្រុម ស្មើនឹង១១១គោលដៅ មានមនុស្សសរុប ចំនួន ២.៥៣២នាក់ លើ៥៩ភូមិ។

- **ស្នងការដ្ឋាននគរបាលខេត្តសៀមរាប៖**
  - បានហាមឃាត់ និងបញ្ឈប់សកម្មភាពភ្ញៀវទេសចរណ៍ ដែលបានបង្កើតក្រុមសប្បាយរាំតាមក្បាច់រួមភេទ នៅចំណុចហាង Scoot Mit ក្នុងតំបន់ Pub Street មានចំនួន ៣៦នាក់ (ស្រី ១១នាក់) ក្នុងនោះបានឃាត់ខ្លួនជនបរទេសចំនួន ០៥នាក់ (ស្រី ០៣នាក់) ដែលជាអ្នកប្រមូលផ្តុំភ្ញៀវ។ ស្នងការដ្ឋាននគរបាលខេត្ត បានឲ្យធ្វើកិច្ចសន្យាផ្តិតមេដៃ និងធ្វើការអប់រំណែនាំឲ្យយល់អំពីវប្បធម៌ខ្មែរ មុននឹងឲ្យពួកគេត្រឡប់ទៅទីលំនៅដ្ឋានវិញ។
  - បានសហការជាមួយអង្គការ Friend International គម្រោងកល្យាណមិត្ត បានដាក់បណ្តាញភ្នាក់ងារដើម្បីការពារសុវត្ថិភាពកុមារ ដល់ក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បី ចំនួន៤៥នាក់។
- **មន្ទីរទេសចរណ៍ខេត្តសៀមរាប**

បានចុះត្រួតពិនិត្យនៅតាមបណ្តាសេវាកម្មសណ្ឋាគារ ផ្ទះសំណាក់ ខារ៉ាអូខេ ដើម្បីជំរុញឲ្យម្ចាស់អាជីវកម្មបន្តអនុវត្តច្បាប់ ស្តីពីការទប់ស្កាត់ទេសចរណ៍ផ្លូវភេទ និងការជួញដូរមនុស្ស និងបន្តបិទផ្សាយហាមមិនឲ្យក្មេងអាយុក្រោម១៨ឆ្នាំ ចូលទៅមណ្ឌលកម្សាន្តដោយគ្មានអាណាព្យាបាលទៅជាមួយ។

- **មន្ទីរធម្មការ និងសាសនាខេត្តសៀមរាប**

បានធ្វើសេចក្តីណែនាំ ប្រគេន និងជំរាបជូនដល់មន្ត្រីសង្ឃ នៃការិយាល័យធម្មការ និងសាសនា ខេត្ត/ក្រុង/ស្រុក ដើម្បីជំរុញព្រះសង្ឃដែលជាធម្មធឹក បន្តបញ្ជ្រាបការអប់រំ ផ្សព្វផ្សាយដល់ពុទ្ធបរិស័ទចំណុះជើងវត្ត ឲ្យបានយល់ដឹង **«អំពីសុវត្ថិភាព និងគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកទៅក្រៅប្រទេស»** នៅក្នុងកម្មវិធីបុណ្យនានា រួមមានកាន់បិណ្ឌ បុណ្យកឋិនទាន និងបុណ្យចេញព្រះវស្សាជាដើម។

- រដ្ឋបាលខេត្តចំនួន៣ បន្ទាយមានជ័យ បាត់ដំបង និងប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន ៩២.០៨១ ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន ដើម្បីអាចចេញចូលស្របច្បាប់ រយៈពេលខ្លី។

## ២.៦. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈអាពាហ៍ពិពាហ៍នៅក្រៅប្រទេស

- ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានសហការគ្នាដើម្បី អនុវត្តបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដើម្បីការពារហានិភ័យនៃអាពាហ៍ពិពាហ៍ ដោយបង្ខំ បន្លំ និងផ្ទុយពីធន្ទះ ដែលនាំទៅដល់ការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ឬការជួញដូរផ្លូវភេទ។
- ក្រសួងមហាផ្ទៃ បានបង្កើតក្រុមការងារនៃក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ក្នុងនោះ មានមន្ត្រីជំនាញពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ។ ក្នុងឆ្នាំ២០១៨ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង

ការពារអនីតិជន បានធ្វើការសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ចំនួន ១.៥៦០គូ និងបានទំនាក់ទំនងស្វែងរកព័ត៌មានពីនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈ ទូរស័ព្ទផ្ទាល់ចំនួន ១៥០នាក់ ដើម្បីបញ្ជាក់ភាពសង្ស័យពាក់ព័ន្ធនឹងការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

## ២.ច. កិច្ចការពារកុមារ

- **ថ្នាក់ជាតិ**
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

បានខិតខំអនុវត្តលើកិច្ចការពារកុមារ ដោយផ្អែកលើគោលការណ៍ ៣គឺ៖ (១)ដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដើម្បីឲ្យកុមារទទួលបានការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មកុមារទៅក្នុងសង្គមជាតិ (២)កិច្ចសហការជាមួយ អង្គការសង្គមស៊ីវិលនានា និងការប្រយុទ្ធប្រឆាំងការជួញដូរស្ត្រី និងកុមារ (៣)ការលើកកម្ពស់ការងារសមរម្យ និងសុវត្ថិភាពកុមារ ។ ជាក់ស្តែង ក្រោយពេលបានចុះត្រួតពិនិត្យតាមបណ្តាសហគ្រាស ដែលមានកុមារធ្វើពលកម្ម ក្រសួង បានដកហូតកុមារចំនួន ២០០នាក់ (ស្រី ១០៥នាក់) តាមគម្រោងបង្ការទប់ស្កាត់ និងដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ។

- **ថ្នាក់ក្រោមជាតិ**
- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត**
  - **ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ និងមានការចូលរួមសហការពីអង្គការម្លប់តាប៉ាង**

    បានដាក់បណ្តាញភ្នាក់ងារ ដើម្បីការពារសុវត្ថិភាពកុមារ មានក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បីចំនួន១៤៣នាក់ ផ្ទះសំណាក់ សណ្ឋាគារ ២៤កន្លែង អ្នកលក់តាមឆ្នេរសមុទ្រ ៧១នាក់ បណ្តាញតាមសហគមន៍ ៦០នាក់ ផ្នែកភ្នាក់ងារទេសចរណ៍០២នាក់ សមាជិកបណ្តាញបុគ្គលិក ផ្ទះសំណាក់/សណ្ឋាគារ ៣៧៤នាក់។
  - **ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម**

    បានត្រួតពិនិត្យសកម្មភាព និងបំពេញទម្រង់ភ្នាក់ងារដើម្បីការពារសុវត្ថិភាពកុមារ នៅតាមគោលដៅនីមួយៗ បានចំនួន០៩ ដែលមាន៖ភ្នាក់ងារម៉ូតូឌុប ចំនួន ២៩នាក់ ភ្នាក់ងាររ៉ឺម៉កកង់បី ចំនួន ១៩នាក់ និងភ្នាក់ងារសហគមន៍ ចំនួន ០១នាក់។

## ២.ឆ. ការលើកកម្ពស់ជីវភាព កាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន

- **ថ្នាក់ជាតិ**
- **ក្រសួងអប់រំ យុវជន និងកីឡា**

បានសហការជាមួយអង្គការ CCPCR និង CEDAC ផ្តល់សេវាដល់ជនដែលងាយរងគ្រោះដោយអំពើជួញដូរមនុស្ស៖ (ក្រុមសន្សំប្រាក់ មុខរបរខ្នាតតូច ការចិញ្ចឹមសត្វ ដាំបន្លែ...) ដល់គ្រួសារសិស្សក្រីក្រ បានចំនួន ៥៨៤នាក់ ក្នុងនោះមាន៖ រាជធានីភ្នំពេញ ខេត្តស្វាយរៀង កោះកុង ព្រៃវែង កំពង់ចាម កំពង់ធំ សៀមរាប បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ។

- **ថ្នាក់ក្រោមជាតិ**
- **ខេត្តតាកែវ (មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត)**

បានបើកវគ្គបណ្តុះបណ្តាល បានចំនួន ១៥វគ្គ ដល់សិក្ខាកាមជាប្រជាពលរដ្ឋចំនួន ៣៧៥នាក់ (ស្រី ២៣៦នាក់) រួមមានជំនាញ៖ ជួសជុលកុំព្យូទ័រ សំណង់ជាងកំបោរ តបណ្តាញអគ្គិសនី ផ្សារដែក រចនាបោះពុម្ព កែសម្ផស្ស កាត់ដេរសម្លៀកបំពាក់ ដីកំប៉ុស្តដំណាំ បន្លែចម្រុះ ចិញ្ចឹមត្រី

ចិញ្ចឹមជ្រូកចាក់វ៉ាក់សាំង ចិញ្ចឹមមាន់ចាក់វ៉ាក់សាំង និងបណ្តុះផ្សិតចំបើង ក្នុងគោលបំណង កាត់បន្ថយការធ្វើចំណាកស្រុកពីសំណាក់បងប្អូនប្រជាពលរដ្ឋ ដែលគ្មានចំណេះ ជំនាញ ដើម្បីអាចរកការងារធ្វើបង្កើនជីវភាព។

## ២.ច. ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ទីភ្នាក់ងារជ្រើសរើសឯកជនដែលមានអាជ្ញាប័ណ្ណ ចំនួន១០៣ និងការជ្រើសរើសតាមប្រព័ន្ធ អនុគ្រោះ មុខរបរ Employment Permit System (EPS) របស់រាជរដ្ឋាភិបាលកម្ពុជា និងបានបញ្ជូនពលករទៅធ្វើការ ដោយស្របច្បាប់នៅក្រៅប្រទេស ចំនួន ១០៤.៩៣៧នាក់ (ស្រី៤១.៥៩៩នាក់) ក្នុងនោះ៖

- ប្រទេសថៃឡង់ដ៍ ចំនួន ៩៦.៦៩៩នាក់ (ស្រី៣៨.៦៨០នាក់)
- ប្រទេសជប៉ុន ចំនួន ៣.០០២នាក់ (ស្រី ១.៤១៧នាក់)
- ប្រទេសសឹង្ហបូរី ចំនួន ២៨៧នាក់ (ស្រី ២៨៧នាក់)
- តំបន់រដ្ឋបាលពិសេសហុងកុង ចំនួន ៥៤នាក់ (ស្រី ៥៤នាក់)
- ប្រទេសអារ៉ាប៊ីសាអូឌីត ចំនួន ១៦នាក់ (ស្រី ១៦នាក់)
- ប្រទេសម៉ាឡេស៊ី ចំនួន ០៩នាក់ (ស្រី ០៣នាក់)
- **ប្រទេសកូរ៉េតាមប្រព័ន្ធអនុគ្រោះមុខរបរ(EPS)** ចំនួន៤.៨៧០នាក់ (ស្រី ១.១៤២នាក់)។

## ២.ឈ. ការសិក្សាស្រាវជ្រាវ

- **ថ្នាក់ជាតិ**
- **ក្រសួងអប់រំ យុវជន និងកីឡា**

បានចុះសិក្សាផលប៉ះពាល់នៃអំពើជួញដូរមនុស្ស នៅគ្រឹះស្ថានសិក្សា ចំនួន០៩ខេត្ត ដោយ មានការចូលរួមពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត/ស្រុក និងគ្រឹះស្ថានសិក្សា ក្នុងនោះមានខេត្ត៖ កោះកុង បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ សៀមរាប កំពង់ឆ្នាំង ស្វាយរៀង ត្បូងឃ្មុំ និងខេត្តរតនគិរី សរុបចំនួន២៧០នាក់ (ស្រី៣៤នាក់)។

- **អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

បានចងក្រងព័ត៌មានដែលបានផ្សព្វផ្សាយតាមរយៈគេហទំព័រជាតិ អន្តរជាតិនានា ពាក់ព័ន្ធនឹង អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងឆ្នាំ២០១៨ សរុបចំនួន ១.០០៧ អត្ថបទ ក្នុងនោះទទួលបានពីសារព័ត៌មានអន្តរជាតិចំនួន ៥១ អត្ថបទ។

- **ថ្នាក់ក្រោមជាតិ**
- **ខេត្តបាត់ដំបង (មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត)**

បានរៀបចំវេទិកាពិគ្រោះយោបល់ ស្តីពីតម្រូវការក្នុងវិស័យឯកជនផ្សារភ្ជាប់នឹងការអភិវឌ្ឍ កម្មសិក្សាស្របតាមតម្រូវការទីផ្សារការងារ ដែលមានការចូលរួមពីសហគ្រាស គ្រឹះស្ថានក្នុងវិស័យ ឯកជន ដូចជា៖ ក្រុមហ៊ុន រោងចក្រ សិប្បកម្ម ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អង្គការ ក្រៅរដ្ឋាភិបាល សណ្ឋាគារ ផ្ទះសំណាក់ អាហារដ្ឋាន សរុបចំនួន ១០០សហគ្រាស គ្រឹះស្ថាន អ្នកចូលរួមចំនួន ១២០នាក់ (ស្រី ៤០នាក់)។

- **ខេត្តសៀមរាប (មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប)**

បានចុះធ្វើការសម្ភាសដល់មាតា បិតា របស់កុមារ ក្នុងគម្រោងបង្ការ ទប់ស្កាត់ និងដកហូត ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ ដោយបានធ្វើកិច្ចសន្យាបញ្ឈប់ប្រើប្រាស់កុមារក្នុងវិស័យ ទេសចរណ៍ នៅក្រុងសៀមរាប ស្រុកសូទ្រនិគម និងស្រុកបន្ទាយស្រី។

## ៣. លើកកម្ពស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

ដើម្បីលើកកម្ពស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ គណៈកម្មាធិការជាតិ ផ្តោតការយកចិត្តទុកដាក់ទៅលើជំនាញពីរសំខាន់ គឺ ការបង្ក្រាប និងការផ្តន្ទាទោស។

ខាងក្រោមនេះជាលទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលទទួលបានពីអង្គភាព៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ចំនួន ១៩ រួមមាន រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ ក្រចេះ មណ្ឌលគិរី សៀមរាប ព្រះសីហនុ កំពត កែប តាកែវ កណ្តាល ស្វាយរៀង ព្រៃវែង និងខេត្តត្បូងឃ្មុំ)។ **(ឧបសម្ព័ន្ធ១)**

### ៣.ក. ការអនុវត្តច្បាប់ បង្ក្រាបបទល្មើស

#### ៣.ក.១.ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

**អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់)** កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បាន៖

តាមដានស្រាវជ្រាវ បង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុប***បាន ១៣៤/១៥៩ករណី បើប្រៀបធៀបនឹង ឆ្នាំ២០១៧ មានការថយចុះចំនួន ២៥ករណី ស្មើនឹង១៥,៧២%។*** សរុបជនសង្ស័យ ដែលត្រូវបានឃាត់ខ្លួន និងបញ្ជូនទៅសាលាដំបូងចំនួន **២២៤/២០៣**នាក់ ធៀបនឹងឆ្នាំ២០១៧ កើនឡើងចំនួន **២១**នាក់ (ស្រី **៩៨**នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន **១៧**នាក់ និងជនបរទេសចំនួន **៣១/២០**នាក់ មាន **០៩**សញ្ជាតិ គឺ៖ ចិន **១៥**នាក់ អង់គ្លេស **០៦**នាក់ វៀតណាម **០៣**នាក់ កាណាដា **០២**នាក់ អូស្ត្រាលី **០១**នាក់ ន័រវេស **០១**នាក់ ហុល្លង់(Netherland) **០១**នាក់ នូវែលហ្សេឡង់ **០១**នាក់ និងហ្វីលីពីន **០១**នាក់។

ក្នុងប្រតិបត្តិការបង្ក្រាប សមត្ថកិច្ចបានសង្គ្រោះជនរងគ្រោះ ករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទសរុបចំនួន **២៣០/៣៤៥**នាក់ (ធៀបនឹងឆ្នាំ២០១៧ ថយចុះចំនួន **១១៥**នាក់) ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ **៩២**នាក់ អាយុពី១៥ឆ្នាំ-១៧ឆ្នាំ **២៣**នាក់ និងអាយុ១៨ឆ្នាំឡើង **១១៥**នាក់ (បានបញ្ជូនទៅមន្ទីរសង្គមកិច្ច **៩២**នាក់ ទៅអង្គការដៃគូ **០២**នាក់ និងបញ្ជូនទៅគ្រួសារចំនួន **១៣៦**នាក់)។

##### ៣.ក.១.១.ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន **៣៩/៤៨ករណី** (ប្រៀបធៀបនឹងឆ្នាំ២០១៧ ថយចុះចំនួន **០៩**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **១០៥**នាក់ (ស្រី **៧៨**នាក់) ក្នុងនោះមានអនីតិជន **០១**នាក់ និងជនបរទេស **០៥**នាក់ សញ្ជាតិចិន។ សង្គ្រោះជនរងគ្រោះចំនួន **៦៤**នាក់ អាយុក្រោម១៥ឆ្នាំ **០៩**នាក់ អាយុពី១៥-១៧ឆ្នាំ **១០**នាក់ និងអាយុ១៨ឆ្នាំឡើង **៤៥**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន **២០**នាក់ អង្គការដៃគូចំនួន **០២**នាក់ និងទៅគ្រួសារចំនួន **៤២**នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

***តារាងស្ថិតិបទល្មើសជួញដូរមនុស្ស***

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០៧ | ១០(អនីតិ.១) | |
| -ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១០ | ១៥ | ចិន៣ |
| -ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១១ | ១៣ | |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០២ | ០៣ | ចិន១ |
| -អំពើលក់ដូរមនុស្ស | ០១ | ០១ | |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០២ | ០៣ | |

| | | | |
|---|---|---|---|
| -អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ០៣ | ៥៣ | ចិន១ |
| -ការដឹកជញ្ជូនដោយមានគោលដៅ | ០១ | ០៤ | |
| -ការទទួលយកមនុស្សដោយជួយដល់ជនល្មើស | ០១ | ០១ | |
| -អំពើអូសទាញពេស្យាចារកុមារ | ០១ | ០២ | |
| *សរុប* | *៣៩ករណី* | *១០៥ នាក់(អនីតិ.១)* | *០៥ នាក់* |

### ៣.ក.១.២.ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន**៩៥/១១១ករណី** (ប្រៀបធៀបនឹងឆ្នាំ២០១៧ ថយចុះចំនួន **១៦**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **១១៩/១៣១**នាក់ ក្នុងនោះ៖ ស្រី **២០**នាក់ ជនសង្ស័យជាអនីតិជន **១៦**នាក់ និងជនបរទេស **២៦**នាក់ មានសញ្ជាតិអង់គ្លេស **០៦**នាក់ វៀតណាម **០៣**នាក់ កាណាដា **០២**នាក់ អូស្ត្រាលី **០១**នាក់ ន័រវេស **០១**នាក់ ហុល្លង់ (Netherland)**០១**នាក់ នូវែលហ្សេឡង់ **០១**នាក់ ចិន **១០**នាក់ និងហ្វីលីពីន **០១**នាក់។ សង្គ្រោះជនរងគ្រោះចំនួន **១៦៦**នាក់ ក្នុងនោះ៖ មានអាយុក្រោម១៥ឆ្នាំ **៨៣**នាក់ អាយុ១៥-១៧ឆ្នាំ **១៣**នាក់ និងអាយុ១៨ឆ្នាំឡើង **៧០**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន **៧២**នាក់ និងទៅគ្រួសារចំនួន **៩៤**នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

#### *តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -ស្ថានទម្ងន់ទោស( ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង ) | ០១ | ០១ | អូស្ត្រាលី១ |
| -សញ្ជារកម្ម | ០៨ | ១៧(អនីតិ.១) | ចិន១០ |
| -សញ្ជារកម្ម (មានអនីតិជន) | ០៥ | ០៦ | វៀតណាម៣ |
| -ស្ថានទម្ងន់ទោសនៃសញ្ជារកម្ម | ០២ | ០៤ | |
| -សញ្ជារកម្ម( ទាក់ទងនឹងពេស្យាចារកុមារ ) | ០៣ | ០៦(អនីតិ.១) | |
| -ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចា | ០១ | ០១ | |
| -រូបភាព និងសម្ភារអាសអាភាសនៃកុមារ | ០២ | ១១(អនីតិ.១) | អង់គ្លេស៥ កាណាដា២ ន័រវេស១ ហុល្លង់ (Netherland)១ នូវែលហ្សេឡង់១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៥២ | ៥២(អនីតិ.១២) | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ២១ | ២១(អនីតិ.១) | ហ្វីលីពីន១ អង់គ្លេស១ |
| *សរុប* | *៩៥ករណី* | *១១៩នាក់(អនីតិ.១៦)* | *២៦នាក់* |

### ៣.ក.២. ការកសាងសំណុំរឿង និងជនសង្ស័យបទល្មើសជួញដូរមនុស្ស បញ្ជូនទៅតុលាការ

#### តារាងបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឆ្នាំ២០១៨

| ល.រ | អំពើ | មាត្រា | ចំនួនករណី | | ចំនួនជនសង្ស័យ | | ចំនួនជនរងគ្រោះ | |
|---|---|---|---|---|---|---|---|---|
| | | | ជួញដូរមនុស្ស | អាជីវកម្មផ្លូវភេទ | ជួញដូរមនុស្ស | អាជីវកម្មផ្លូវភេទ | ជួញដូរមនុស្ស | អាជីវកម្មផ្លូវភេទ |
| ១ | ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ៩* | ៧ | | ១០ | | ៩ | |
| ២ | ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១០* | ១០ | | ១៥ | | ១២ | |
| ៣ | ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១១* | ១១ | | ១៣ | | ២៨ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៤ | ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចន៍ | ១២* | ២ | | ៣ | | ២ | |
| ៥ | អំពើលក់ដូរមនុស្ស | ១៤* | ១ | | ១ | | | |
| ៦ | អំពើលក់ដូរមនុស្សដោយមានគោលដៅ | ១៥* | ២ | | ៣ | | ១ | |
| ៧ | អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ១៦* | ៣ | | ៥៣ | | | |
| ៨ | ការដឹកជញ្ជូនដោយមានគោលដៅ | ១៧* | ១ | | ៤ | | ៤ | |
| ៩ | អំពើនាំឆ្លងដែន | ១៨* | | | | | | |
| ១០ | ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ២០* | ១ | | ១ | | ២ | |
| ១១ | ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ២១* | | | | | | |
| ១២ | ស្ថានទម្ងន់ទោស (ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង) | ២២* | | ១ | | ១ | | ៣ |
| ១៣ | សញ្ចារកម្ម | ២៦* | | ៨ | | ១៧ | | ៣៤ |
| ១៤ | សញ្ចារកម្ម (មានអនីតិជន) | ២៦* | | ៥ | | ៦ | | ២៦ |
| ១៥ | ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ២៧* | | ២ | | ៤ | | ១៣ |
| ១៦ | សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | ២៨* | | ៣ | | ៦ | | ៤ |
| ១៧ | ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ៣២* | | ១ | | ១ | | ៥ |
| ១៨ | បទល្មើសទាក់ទងនឹងពេស្យាចារកុមារ | ៣៣* | | | | | | |
| ១៩ | ការទិញពេស្យាចារកុមារ | ៣៤* | | | | | | |
| ២០ | អំពើអូសទាញពេស្យាចារកុមារ | ៣៥* | ១ | | ២ | | ៦ | |
| ២១ | ការនាំឲ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌ ទាក់ទងទៅនឹងអំពើពេស្យាចារកុមារ | ៣៦* | | | | | | |
| ២២ | រូបភាព និងសម្ភារៈអាសអាភាស | ៣៩* | | | | | | |
| ២៣ | រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ៤១* | | ២ | | ១១ | | ១ |
| ២៤ | អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤២* | | ៥២ | | ៥២ | | ៥៤ |
| ២៥ | អំពើអាសប្រចាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤៣* | | ២១ | | ២១ | | ២៦ |
| ២៦ | កិច្ចសន្យាសម្រាប់អំពើលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ | ៤៥* | | | | | | |
| | សរុប | | ៣៩ | ៩៥ | ១០៥ | ១១៩ | ៦៤ | ១៦៦ |
| | សរុបរួម | | ១៣៤ ករណី | | ២២៤ នាក់ | | ២៣០ នាក់ | |

## តារាងបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឆ្នាំ២០១៨ ប្រៀបធៀបនឹងឆ្នាំ២០១៧

| ល.រ | អនុវត្ត | ករណី | ជនសង្ស័យ | ជនរងគ្រោះ |
|---|---|---|---|---|
| ១ | ឆ្នាំ២០១៨ | ១៣៤ | ២២៤ | ២៣០ |
| ២ | ឆ្នាំ២០១៧ | ១៥៩ | ២០៣ | ៣៤៥ |
| សម្គាល់ | | ថយចុះ:២៥ករណី | កើនឡើង២១នាក់ | ថយចុះ:១១៥នាក់ |



### ៣.ក.៣.ការបង្ក្រាបករណីផ្តលពពោះជំនួស ដើម្បីនាំទារកឆ្លងដែនខុសច្បាប់

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

**ក្នុងឆ្នាំ២០១៨ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ** បានរកឃើញបទល្មើសថ្មី និងបានបង្ក្រាបករណីផ្តលពពោះជំនួស ដើម្បីនាំទារកឆ្លងដែន បានចំនួន០២ករណី ដែលលើកទី១ ចាប់ខ្លួនជនសង្ស័យ ០៥នាក់ (ជនជាតិចិន ០១នាក់ ជនជាតិខ្មែរ ០៤នាក់)និងប្រមូលបាន ស្ត្រីពពោះជំនួស ៣២នាក់ និងលើកទី២ ចាប់ខ្លួនជនសង្ស័យ០៣នាក់ ជាជនជាតិខ្មែរ និងប្រមូលបានស្ត្រីពពោះជំនួស ១១នាក់។

**ករណីទី១** ដែលមានស្ត្រីពពោះ ៣២នាក់ ត្រូវបានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានសហការជាមួយក្រសួងសុខាភិបាល ផ្តល់គ្រូពេទ្យ ៣០ដើម្បីឲ្យស្ត្រី សម្រាក និងមន្ទីរពេទ្យ ១៦ឧសភា សហការជាមួយ មន្ទីរពេទ្យ ១៦ឧសភា របស់ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមេត្រីអន្តរជាតិ(AIM) ផ្តល់ការថែទាំ អប់រំ និងបានស្នើសុំតុលាការ ឲ្យដាក់នៅក្រៅឃុំ ដើម្បីមានលទ្ធភាពចិញ្ចឹមថែទាំទារក ដែលជាមុខសញ្ញារងគ្រោះដោយអំពើជួញដូរ។ **ឯករណីទី២** កំពុងស្ថិតក្នុងនីតិវិធីតុលាការនៅឡើយ។

## ៣.ខ.កិច្ចការយុត្តិធម៌

### ៣.ខ.១.លទ្ធផលចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

#### ៣.ខ.១.១.ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន **១៥៤**ករណី ជនរងគ្រោះចំនួន **១៨៣**នាក់(ស្រី **១៣៧**នាក់) អនីតិជន **១០២**នាក់ (ស្រី**៧៩**នាក់) ជនត្រូវចោទមានចំនួន **១៩៦**នាក់ ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន **៩៩**ករណី តម្កល់ទុកឥតចាត់ការ ០៤ករណី និងកំពុងចាត់ការចំនួន **៥១**ករណី ដូចមានតារាងរាយលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| សរុប ១៥៤ | ២៣ | ៥៨ | ២៣ | ៧៩ | ១៣៥ | ៣៧ | ២២ | ០២ | ៩៩ | ៤ | ៥១ |
| | ៨១នាក់ | | ១០២នាក់ | | ១៧២នាក់ | | ២៤នាក់ | | ១៥៤ករណី | | |

#### ៣.ខ.១.២.ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់ចៅក្រមស៊ើបសួរ រាជធានី-ខេត្ត សរុបមានចំនួន **៤២០**ករណី ជនរងគ្រោះ**៥២៣**នាក់ (ស្រី**៤៧៤**នាក់) អនីតិជន**៣០៧**នាក់(ស្រី២៩០នាក់) ជនត្រូវចោទមានចំនួន **៥៣៨**នាក់(ស្រី**៧១**នាក់) អនីតិជន **៧៦**នាក់(ស្រី០៤នាក់) នៅក្នុងឃុំចំនួន៤១២នាក់ (ស្រី៨៣នាក់) អនីតិជន ៦៩នាក់ (ស្រី៣២នាក់) នៅក្រៅឃុំ **១៧៥**នាក់ (ស្រី៦១នាក់) អនីតិជន ៤៦នាក់(ស្រី១៤នាក់) និងបានចំណាត់ការបញ្ជូនទៅជម្រះចំនួន **៧៥**ករណី លើកលែងចោទ ០២ករណី និងកំពុងចាត់ការចំនួន ៣៤៣ករណី ដូចមានតារាងរាយលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួររាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | នៅក្នុងឃុំ | | | | នៅក្រៅឃុំ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជំនុំជម្រះ | លើកលែងចោទ | កំពុងចាត់ការ |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | | |
| សរុប | ៣២ | ១៨៤ | ១៧ | ២៩០ | ៣៩៥ | ៦៧ | ៧២ | ៤ | ២៩២ | ៥១ | ៣៧ | ៣២ | ៨២ | ៤៧ | ៣២ | ១៤ | ៧៥ | ២ | ៣៤៣ |
| ៤២០ | ២១៦នាក់ | | ៣០៧នាក់ | | ៤៦២នាក់ | | ៧៦នាក់ | | ៤១២នាក់ | | | | ១៧៥នាក់ | | | | ៤២០ករណី | | |

### ៣.ខ.១.៣.ចំណាត់ការរបស់ចៅក្រមជំនុំជម្រះនៃសាលាដំបូង រាជធានី-ខេត្ត

ចំណាត់ការរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត សរុបមានចំនួន ២១៤ករណី ជនរងគ្រោះចំនួន **២៧៣**នាក់(ស្រី **២៥២**នាក់) អនីតិជន **១១៤**នាក់(ស្រី **១០៧**នាក់) ជនជាប់ចោទសរុប **២៥៣**នាក់ (ស្រី **៤៣**នាក់) និងប្រភេទចំណាត់ការ (ទោសព្យួរគ្មាន ពិន័យជាប្រាក់គ្មាន រួចផុតពីបទចោទ ០១នាក់ រំលត់បណ្តឹងអាជ្ញាគ្មាន ចាត់ការរួច **៧២**ករណី ផ្តន្ទាទោសដាក់ពន្ធនាគារក្នុងឃុំ **១២៥**នាក់ នៅក្រៅឃុំ **៥៣**នាក់ និងកំពុងចាត់ការ **១៤២**ករណី) ដូចមានតារាងរាយលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | ប្រភេទចំណាត់ការ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោសពន្ធនាគារ | | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | ក្នុងឃុំ | ក្រៅឃុំ | |
| សរុប | ១៤ | ១៤៥ | ៧ | ១០៧ | ២១០ | ៤៣ | ០ | ០ | ១ | ០ | ៧២ | ១២៥ | ៥៣ | ១៤២ |
| ២១៤ | ១៥៩នាក់ | | ១១៤នាក់ | | ២៥៣នាក់ | | | | នាក់ | | ករណី | នាក់ | នាក់ | ករណី |

ក្រាហ្វិក ចំណាត់ការរបស់ចៅក្រមជំនុំជម្រះឆ្នាំ២០១៨ ប្រៀបធៀបនឹងឆ្នាំ២០១៧




### ៣.គ.ការដោះស្រាយករណីវិវាទទាក់ទងពលករទេសន្តរប្រវេសន៍ និងបណ្តាក្រុមហ៊ុននានា

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
  បានទទួលនិងដោះស្រាយវិវាទផ្នែក ទេសន្តរប្រវេសន៍ ចំនួន **៣៧**ក្រុមហ៊ុន មានសំណុំរឿងចំនួន **៣៩**ករណី ក្នុងនោះមានពលករចំនួន **៥៨៧**នាក់ (ស្រី **២១៨**នាក់)។ បណ្តឹងសះជាចំនួន **៣១**ករណី បណ្តឹងមោឃៈ ០១ករណី និងបណ្តឹងកំពុងតាមដានដោះស្រាយបន្តមានចំនួន **០៧**ករណី។

### ៤.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

ការទទួលពលករ និងពលរដ្ឋខ្មែររងគ្រោះដែលត្រូវបញ្ជូនត្រឡប់មកវិញដោយអាជ្ញាធរបរទេស ត្រូវបានយកចិត្តទុកដាក់ពង្រឹងកិច្ចសហការ និងបានធ្វើជាប្រចាំ។

## ៤.គ.ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន(ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ និងការទទួលសាកសព

### ៤.គ.១.ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

យោងស្ថិតិ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** ក្រោមកិច្ចសហការជាមួយអង្គការដៃគូ បានបញ្ជូនពលរដ្ឋខ្មែរដែលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស និងមូលហេតុផ្សេងៗ តាមរយៈស្ថានទូត ស្ថានតំណាងនៅប្រទេសចំនួន០៨ មានមនុស្សចំនួន ៨.៤៨៩នាក់ (ស្រី ៣៣០នាក់)ដូចដែលមានតារាងខាងក្រោម៖

| ល.រ | ប្រទេស | មូលហេតុនៃការវិលត្រឡប់ | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|
| ១ | ចិន | ករណីជួញដូរមនុស្ស | ១២៣ | ១២២ |
| ២ | អារ៉ាប់ប៊ីសាអូឌីត | ករណីជួញដូរមនុស្ស | ០៤ | ០៤ |
| ៣ | ម៉ាឡេស៊ី | ឆ្លងដែនខុសច្បាប់ | ២១៨ | ១២២ |
| ៤ | ឥណ្ឌូនេស៊ី | ឆ្លងដែនខុសច្បាប់ | ០២ | ០០ |
| ៥ | សិង្ហបុរី | មិនអាចទ្រាំការងារបាន | ១៥ | ១៥ |
| ៦ | វៀតណាម | ឆ្លងដែនខុសច្បាប់ | ៦១ | ៣៨ |
| | | ករណីជួញដូរមនុស្ស | ២៧ | ២៧ |
| ៧ | ឡាវ | ឆ្លងដែនខុសច្បាប់ | ១២ | ០២ |
| ៨ | ថៃ | ករណីជួញដូរមនុស្ស | ២៦ | ០០ |
| | | ឆ្លងដែនខុសច្បាប់ | ៨.០០១ | ០០ |
| សរុបរួម | | | ៨.៤៨៩នាក់ | ៣៣០នាក់ |

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាសរុបចំនួន **២២៤**នាក់ (ស្រី **១៥៩**នាក់ កុមារ **១៦**នាក់) មានដូចខាងក្រោម៖

- បានទទួលជនសង្ស័យរងគ្រោះ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់ពីប្រទេសនានា ចំនួន **២០២**នាក់ (ស្រី **១៤៧**នាក់) ក្នុងនោះមកពីប្រទេស៖ ចិន **៨៩**នាក់ វៀតណាម **២៩**នាក់ (ឆ្លងដែនទៅចិន) ម៉ាឡេស៊ី **៦១**នាក់ សូម៉ាលី **២១**នាក់ និងអារ៉ាប់ប៊ីសាអូឌីត **០២**នាក់ ក្នុងនោះមានករណី៖ រៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ **៩៦**នាក់ និងជួញដូរកម្លាំងពលកម្ម **១០៦**នាក់ (ដោយមានការសហការពី អង្គការសម្ព័ន្ធចាប់ដៃ(Chab Dai Coalition) អង្គការ IOM អង្គការរតនៈអន្តរជាតិ(RATANAK INTERNATIONAL) អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) អង្គការក្តីសង្ឃឹមនិងយុត្តិធម៌(Hope for Justice) អង្គការមេត្រីអន្តរជាតិ(IIM) និងអង្គការ ADHOC)។
- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានទទួលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃប្រទេសថៃDepartment of Social Development and Walfare (DSDW) សរុបចំនួន **២០**នាក់ (ស្រី **០២**នាក់) កុមារ **១៦**នាក់។
- បានធ្វើមាតុភូមិនិវត្តន៍ស្ត្រីរងគ្រោះជនជាតិវៀតណាមដោយអំពើជួញដូរមនុស្ស ចំនួន **០២**នាក់ ត្រឡប់ទៅប្រទេសវៀតណាមវិញ ដោយមានការរៀបចំពីមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ដោយមានការសហការពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងអង្គការមេត្រីអន្តជាតិ។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួលពលករខ្មែរដែលត្រឡប់ពីបណ្តាប្រទេសផ្សេងៗចំនួន ២១០នាក់ (ស្រី ១៣៨នាក់) ក្នុងនោះបានសម្ភាស ចំនួន ១៩៩នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

| ល.រ | មកពីប្រទេស | ចំនួនសរុប | សម្ភាសន៍ | ទៅតាមរយៈ | | | |
|---|---|---|---|---|---|---|---|
| | | | | ក្រុមហ៊ុន | មេខ្យល់ | ខ្លួនឯង | អ្នកស្គាល់គ្នា |
| ១ | ចិន | ៨៤ | ៨២ | | ៧៧ | | ៥ |
| ២ | ម៉ាឡេស៊ី | ៥៧ | ៤៩ | ៨ | ៣១ | ៧ | ៣ |
| ៣ | វៀតណាម | ២១ | ២០ | ១ | ១៨ | | ១ |
| ៤ | ថៃ | ៣ | ៣ | | ៣ | | |
| ៤ | ឥណ្ឌូនេស៊ី | ៥ | ៥ | | | | ៥ |
| ៥ | អារ៉ាប៊ីសាអូឌីត | ៥ | ៥ | ៣ | ២ | | |
| ៦ | សូម៉ាលី | ៣៥ | ៣៥ | | ៣០ | | ៥ |
| សរុប | | ២១០នាក់ | ១៩៩នាក់ | ១២នាក់ | ១៦១នាក់ | ៧នាក់ | ១៩នាក់ |

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

**ស្នងការដ្ឋាននគរបាលខេត្ត** ចំនួន៥ បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងតាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម ចំនួន ១.០៦៩លើក មនុស្សសរុបចំនួន ៣១.៥៣៦នាក់ (ស្រី ១១.១៦៧នាក់) អនីតិជន ៣.០៣០នាក់ ៖

+ **តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ** ចំនួន ១.០៥៧លើក មនុស្សចំនួន ៣១.៣២៨នាក់ (ស្រី ១១.០៣០នាក់) អនីតិជន ២.៨៨៩នាក់៖

- ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យ ចំនួន ៨២០លើក មនុស្សចំនួន ២៨.៨៦៩នាក់ (ស្រី ១០.០៦៥នាក់) អនីតិជន ២.៨១៥នាក់ ក្នុងនោះមានពលរដ្ឋខ្មែរចំនួន ៨៥២នាក់ (ស្រី ៦៣នាក់) ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ និងឃាត់ខ្លួនលើសពីរយៈពេល១ខែ មុននឹងបញ្ជូនមកកម្ពុជាវិញ។
- ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ១២៣លើក មនុស្សចំនួន ១.០៣១នាក់ (ស្រី ៣៨៩នាក់) អនីតិជន ៧០នាក់ ក្នុងនោះ ច្រកទ្វារដូង ៨៤០នាក់ (ស្រី ៣១៩នាក់) និងច្រកភ្នំដី ១៩១នាក់ (ស្រី ៧០នាក់)។
- ស្នងការដ្ឋាននគរបាលខេត្តកោះកុង ០៥លើក មនុស្សចំនួន ៥៦នាក់(ស្រី ២៥នាក់) អនីតិជន ០៤នាក់។
- ស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន ១០៩លើក មនុស្សចំនួន ១.៣៧២នាក់ (ស្រី ៥៥១នាក់)។

+ **តាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត នៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង** ចំនួន ១២លើក មនុស្សចំនួន ២០៨នាក់ (ស្រី ១៣៧នាក់) អនីតិជន ១៤១នាក់។

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ១៨ប្រទេស សរុបចំនួន ៣១.៦០៩នាក់ (ស្រី ១០.៧២៨នាក់ កុមារ ២.៩១៥នាក់) ក្នុងនោះ៖ មាន០៦

ប្រទេស សរុបចំនួន ៣១.៤១០នាក់ ដូចជាប្រទេសថៃ ៣០.៦៣៦នាក់ កូរ៉េខាងត្បូង ២៧០នាក់ ម៉ាឡេស៊ី ១៧២នាក់ ចិន ១៥៦នាក់ ជប៉ុន ៩២នាក់ និងប្រទេសវៀតណាម ៨៤នាក់... (បញ្ជាក់នៅសល់ ១២ប្រទេស មានមនុស្សចំនួន ១៩៩នាក់ ពុំបានរាយឈ្មោះដាក់បញ្ចូលទេ)។

- **ទីចាត់ការការពារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ**

បានទទួល និងសម្របសម្រួលផ្តល់សេវាចាំបាច់ដល់ពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃបញ្ជូនមកវិញ តាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ សរុបចំនួន ៦.៨៤៥នាក់ (ស្រី ២.១៩៣នាក់) អនីតិជន ៦១៥នាក់ ក្នុងនោះមាន៖ ច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ចំនួន ៦.៣៥១នាក់ (ស្រី ២.១០៤នាក់) អនីតិជន ៦១៥នាក់ ច្រកទ្វារអន្តរជាតិដូង ខេត្តបាត់ដំបង ចំនួន ៤៩៣នាក់ (ស្រី ៨៩នាក់) និងខេត្តព្រះវិហារ ០១នាក់។

### ៤.ក.២.ការទទួលសាកសពបញ្ជូនត្រឡប់

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

**សាកសពដែលបញ្ជូនត្រឡប់តាមច្រកទ្វារអន្តរជាតិ** ក្នុងខេត្តបាត់ដំបង និងបន្ទាយមានជ័យ សរុបចំនួន ២០៦លើក មនុស្សចំនួន ២២១នាក់ (ស្រី ៤៧នាក់ និងកុមារ ០១នាក់)។

## ៤.ខ.ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

ក្រោមការដឹកនាំចង្អុលបង្ហាញរបស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការបានសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ ស្ថាប័នអយ្យការ តុលាការ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានកស្តុការនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធនាគារ និងអង្គការមេត្រីអន្តរជាតិ(AIM) អង្គការចាប់ដៃ ដើម្បីផ្តល់សេវាផ្នែកច្បាប់ និងគាំពារសេវាសង្គមកិច្ចដល់ស្ត្រីពពោះជំនួសចំនួន ៣២នាក់។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទានៅមជ្ឈមណ្ឌលរបស់រដ្ឋចំនួន ៨៤៨នាក់ (ស្រី ៦៤៣នាក់ កុមារ ១៦៩នាក់ )ដូចមានខាងក្រោម៖

- បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ៨៩នាក់ (ស្រី ៧៦នាក់) ទៅទទួលស្តារនីតិសម្បទា ពីអង្គការដៃគូមានដូចជាៈ អង្គការសម្ព័ន្ធចាប់ដៃ អង្គការលីកាដូ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) អង្គការសួននៃក្តីសង្ឃឹមកម្ពុជា(Garden of Hope in Cambodia) និងអង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិCambodian Women's Crisis Center (CWCC) ក្នុងនោះករណី៖រៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ៣៦នាក់ ជួញដូរផ្លូវភេទ ១១នាក់ និងជួញដូរកម្លាំងពលកម្ម ៤២នាក់។
- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានបញ្ជូនជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ សរុបចំនួន ១៣១នាក់ (ស្រី ៣៣នាក់ កុមារ ៨៩នាក់) ទៅអង្គការដៃគូដូចជា៖ អង្គការIOM០២នាក់

អង្គការដំណក់ទឹក ៨៨នាក់ អង្គការគ្រួសារថ្មី០៤នាក់ អង្គការកល្យាណមិត្ត(ភ្នំពេញ) ០១នាក់ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ Cambodian Women's Crisis Center (CWCC) ២៨នាក់

- អង្គការក្តីសង្ឃឹមនិងយុត្តិធម៌(Hope for Justice) ០៥នាក់ អង្គការលុបបំបាត់ការជួញដូរមនុស្សនៅសតវត្សទី២១(A21) ០១នាក់ និងអង្គការកឿន ០២នាក់ ដើម្បីទទួលសេវាស្នាក់នៅសុវត្ថិភាព អប់រំក្នុង និងក្រៅប្រព័ន្ធ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងផ្តល់សេវាផ្សេងៗទៀត មុនពេលធ្វើសមាហរណកម្មទៅសហគមន៍វិញ។
- **មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា(ស.អ.យ)រាជធានី-ខេត្ត** បានធ្វើការពិគ្រោះយោបល់ និងបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ១៧០នាក់ (ស្រី ១៦៩នាក់) ទៅទទួលសេវាស្តារនីតិសម្បទានៅមណ្ឌលរដ្ឋ និងអង្គការដៃគូ ក្នុងនោះមាន៖ មន្ទីរ ស.អ.យ រាជធានីភ្នំពេញ ១៥៩នាក់ តាកែវ ០៦នាក់ សៀមរាប ០៤នាក់ និងមន្ទីរ ស.អ.យខេត្តពោធិ៍សាត់ ០១នាក់ (ករណីជួញដូរមនុស្ស ៦៤នាក់ និងករណីធ្វើអាជីវកម្មផ្លូវភេទ ១០៦នាក់)។
- **មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា(ស.អ.យ)រាជធានី-ខេត្ត** សហការជាមួយអង្គការដៃគូ បានទទួល និងផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅសហគមន៍វិញសរុបចំនួន ៤៥៨នាក់ (ស្រី ២៤៥នាក់ កុមារី ៨០នាក់) ក្នុងនោះរួមមាន៖ អង្គការរតនៈអន្តរជាតិ(RATANAK INTERNATIONAL) ៥៦នាក់ អង្គការមេត្រីអន្តរជាតិ(AIM) ៥០នាក់ អង្គការសួននៃក្តីសង្ឃឹម(Garden of Hope in Cambodia) ៤២នាក់ អង្គការបេសកកម្មទូទាំងពិភពលោក ២០នាក់ អង្គការ អេ អ អឹម American Rehabilitation Ministry(ARM) ០១នាក់ អង្គការពន្លកថ្មី ១៦នាក់ អង្គការមូលនិធិហាការអន្តរជាតិ(Hagar International Foundation) ៦៤នាក់ អង្គការសម្ព័ន្ធចាប់ដៃ(Chab Dai Coalition) ២៦នាក់ អង្គការសង្គ្រោះជោគវាសនានៅកម្ពុជាSestiny Recue Cambodia (SRC) ៣៨នាក់ សមាគមកុមាររីករាយ ២៤នាក់ អង្គការវ៉េណាសេដីជាមួយស្ត្រីកម្ពុជា ១៦នាក់ អង្គការសកម្មភាពដើម្បីកុមារ ៧១នាក់ អង្គការសង្គ្រោះនិងថែទាំ(Citipointe) ០៦នាក់ និងមណ្ឌលកម្ពុជាដើម្បីកុមារ ២៣នាក់ ក្នុងនោះមានករណី៖ (ជួញដូរពលកម្ម ៧៩នាក់ រំលោភផ្លូវភេទ ១៥៣នាក់ ជួញដូរផ្លូវភេទ ២៣នាក់ បៀតបៀនកេរ្តិ៍ភេទ ៤២នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ០៩នាក់ រៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ៥២នាក់) ជួញដូរមនុស្ស ៧៤នាក់ ពេស្យាចារ ១៥នាក់ អំពើអាស ០១នាក់ និងរំលោភបំពានផ្លូវភេទ ១០នាក់។

## ៤.គ.ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងអង្គការមេត្រីអន្តរជាតិ(AIM) បានធ្វើសមាហរណកម្មស្ត្រីដែលជួលពពោះជំនួសចំនួន ៣២នាក់ និងទារកមុខសញ្ញាងាយរងគ្រោះ ទៅសហគមន៍។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ) និងមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្ត សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះឲ្យទៅតាមសហគមន៍វិញ សរុបចំនួន ៣០៣នាក់ (ស្រី ២៤៦នាក់) កុមារ ៦៣នាក់ ក្នុងនោះមាន៖

- បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរពលកម្មចំនួន ៨៨នាក់ (ស្រី ៨០នាក់)
- ដោយបានសហការជាមួយ៖ អង្គការរតនៈអន្តរជាតិ(RATANAK INTERNATIONAL) ៣៦នាក់ អង្គការមេត្រីអន្តរជាតិ(AIM) ០៨នាក់ អង្គការក្តីសង្ឃឹមនិងយុត្តិធម៌(Hope for Justice) ០៤នាក់ អង្គការចាប់ដៃ ០១នាក់ និងអង្គការដៃគូដទៃទៀត ៣៦នាក់ ក្នុងការជូនជនរងគ្រោះទៅសហគមន៍វិញ។
- មន្ទីរស.អ.យរាជធានី-ខេត្ត បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅគ្រួសារ និងសហគមន៍វិញសរុបចំនួន ១២៨នាក់(ស្រី ៦៥នាក់) កុមារ៦៣នាក់ ក្នុងនោះមាន៖ មន្ទីរខេត្តស្វាយរៀង ៩៥នាក់(ករណីលក់ឆ្នោត) ខេត្តតាកែវ ១២នាក់ ខេត្តកំពង់ធំ ០៩នាក់ និងខេត្តសៀមរាប ១២នាក់(ករណីជួញដូរកម្លាំងពលកម្ម ៩៥នាក់ ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ១២នាក់ និងករណីជួញដូរផ្លូវភេទ ២១នាក់)។
- មន្ទីរស.អ.យរាជធានី-ខេត្ត សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅសហគមន៍វិញសរុបចំនួន ៨៧នាក់ (ស្រី ៣៩នាក់ កុមារ ៤៨នាក់) ក្នុងនោះមាន៖ អង្គការរតនៈអន្តរជាតិ(RATANAK INTERNATIONAL) ០១នាក់ (សហការជាមួយមន្ទីរខេត្តកណ្តាល) អង្គការសួននៃក្តីសង្ឃឹមនៅកម្ពុជា(Garden of Hope in Cambodia)៤៩នាក់ អង្គការមេត្រីអន្តរជាតិ(IJM) ១៧នាក់ អង្គការសង្គ្រោះ និងថែទាំអន្តរជាតិស៊ីធីភញCitipointe International Care and Aid(CICA) ០៤នាក់ អង្គការសង្គ្រោះជោគវាសនាកម្ពុជា(Destiny Recue Cambodia(DRC) ១៦នាក់ អង្គការមូលនិធិហាការ ០៤នាក់ និងអង្គការតំណក់ទឹក ១៣នាក់ (ករណីរំលោភបំពានផ្លូវភេទ ១៧នាក់ ជួញដូរផ្លូវភេទ ១៨នាក់ ជួញដូរកម្លាំងពលកម្ម ២១នាក់ ជួញដូរមនុស្ស ២៨នាក់ រៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ២៣នាក់ និងករណីរំលោភបំពានផ្លូវភេទ ០៨នាក់)។

## III.ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ១.ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ១.ក.ការបណ្តុះបណ្តាល

##### ១.ក.១.ការបណ្តុះបណ្តាលក្នុងប្រទេស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ(គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ បើកវគ្គបណ្តុះបណ្តាលបានចំនួន ២៣៤វគ្គ មានសិក្ខាកាមចូលរួមចំនួន ៦.៣២១នាក់ ក្នុងនោះមានស្ត្រី ៣.១០៨នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិក គ.រ.ប.ជ/គ.ខ.ប.ជ ដូចមានតារាងវគ្គបណ្តុះបណ្តាលខាងក្រោម៖

*តារាងវគ្គបណ្តុះបណ្តាល*

❖ ក្រសួង ស្ថាប័ន បានសហការជាមួយអង្គការដៃគូមានអង្គការ(MOI , UNICEF វីនរ៉ក់អន្តរជាតិ,ទស្សនពិភពលោក,AIM SWAT, IJM, Child Fund, អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ....) ដល់គ្រូបង្គោល មន្ទីរអង្គភាពនានារបស់រដ្ឋ និងវិស័យឯកជន ទូទាំង ២៥រាជធានី-ខេត្ត និងបានបើកវគ្គបណ្តុះបណ្តាល ទាំងទ្រឹស្តី ទាំងការអនុវត្ត ស្តីពី៖
- ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាលើស្ត្រី និងកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទាំងប្រទេស។

- ទេសន្តប្រវេសន៍ និងសមភាពយេនឌ័រ ដល់អាជ្ញាធរ ភូមិ/ឃុំ/សង្កាត់ រាជធានី/ខេត្ត។
- ការថែទាំសុខភាពសម្រាប់កុមាររងគ្រោះដោយអំពើហិង្សា និងការរំលោភបំពាន ដល់លោកគ្រូ អ្នកគ្រូពេទ្យ និងបុគ្គលិកនៃមន្ទីរសុខាភិបាល និងការ សង្គ្រោះចិត្តសាស្ត្របឋម របស់សហគមន៍សម្រាប់ជួយដល់ជនរងគ្រោះ ដោយការជួញដូរមនុស្ស និងជនដែលងាយរងគ្រោះ រាជធានីខេត្ត។
- ជំនាញខុនគន្លឹះនៃការស្វែងរកការងារ ក្នុងការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។
- ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់ប្រតិបត្តិករទេសចរណ៍ និង វិនិយោគិន ទេសចរណ៍ចិន បញ្ជ្រាបនិងផ្សព្វផ្សាយក្នុងការចូលរួមទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ទេសចរណ៍ផ្លូវភេទ ដល់មន្ទីរទេសចរណ៍រាជធានី-ខេត្ត។

| ល.រ | ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០២ | ២០ | ០០ |
| ២ | ក្រសួងកិច្ចការនារី | ០៤ | ១៦៨ | ១៣៩ |
| ៣ | ក្រសួងអប់រំ យុវជន និងកីឡា | ១៨ | ៤៣២ | ៣៤ |
| ៤ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០៤ | ១២៣ | ៣៤ |
| ៥ | ក្រសួងទេសចរ | ០១ | ២០ | ១៣ |
| ៦ | អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ០៣ | ៨១ | ២២ |
| ៧ | អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន | ០៤ | ៨០ | ១៣ |
| ៨ | ខេត្តឧត្តរមានជ័យ | ០១ | ១៤៣ | ៤៦ |
| ៩ | ខេត្តបន្ទាយមានជ័យ | ៣២ | ៤៨៣ | ២៤៩ |
| ១០ | ខេត្តបាត់ដំបង | ១១ | ៣៧០ | ១៥៩ |
| ១១ | ខេត្តសៀមរាប | ២៣ | ៣៦០ | ៨៨ |
| ១២ | ខេត្តកំពង់ធំ | ២៣ | ៨៣៧ | ៥៥១ |
| ១៣ | ខេត្តព្រះសីហនុ | ២៥ | ៩៩៧ | ៥៦៨ |
| ១៤ | ខេត្តមណ្ឌលគិរី | ០១ | ៥០ | ២៦ |
| ១៥ | ខេត្តក្រចេះ | ០៧ | ៣៦០ | ២៦៥ |
| ១៦ | ខេត្តរតនគិរី | ០១ | ៤៨ | ៤៧ |
| ១៧ | ខេត្តព្រៃវែង | ០៥ | ១៧៣ | ០០ |
| ១៨ | ខេត្តស្វាយរៀង | ៦៤ | ១.៣១៨ | ៧៥៧ |
| ១៩ | ខេត្តកំពង់ស្ពឺ | ០១ | ៣៨ | ១៨ |
| ២០ | ខេត្តកំពត | ០២ | ៧០ | ២០ |
| ២១ | ខេត្តកោះកុង | ០២ | ១១០ | ៥៩ |
| | សរុប | ២៣៤ | ៦.៣២១ | ៣.១០៨ |

## ១.ក.២.ការបណ្តុះបណ្តាលក្រៅប្រទេស

- **ថ្នាក់ជាតិ**
  - **អគ្គស្នងការដ្ឋាននគរបាលជាតិ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចាត់បញ្ជូននាយនគរបាល ចំនួន ០៨រូប ដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី៖ (១)"ឯកទេសប្រឆាំងនឹងការរត់ពន្ធមនុស្សខុសច្បាប់ ការរត់ពន្ធជនអន្តោប្រវេសន៍ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទលើស្ត្រី និងកុមារ" នៅប្រទេសសឹង្ហបុរី។ (២)ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅប្រទេសចិន។ (៣)មន្ត្រីអនុវត្តច្បាប់សម្រាំង ដើម្បីបង្ក្រាបបទល្មើសលើកុមារ តាមប្រព័ន្ធអ៊ិនធើណេត ប្រទេសថៃ។ (៤)វគ្គបំប៉នការងារដឹកនាំសម្រាប់ថ្នាក់នាយកដ្ឋាន ស្នងការ និងការិយាល័យ ប្រទេសវៀតណាម។

- **អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**
  - បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រុមជំនួយកិច្ចការអនុវត្តច្បាប់ ចំនួន ០២រូប ទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីក្រុងណាននីង ខេត្តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន។
  - បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ចំនួន ០២រូប ទៅចូលរួម (០១)បណ្តុះបណ្តាលវគ្គខ្លីដោយJICA នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ស្តីពីការពង្រឹងបណ្តាញការងាររបស់ប្រទេសអាស៊ានលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានការចូលរួមចំនួនប្រាំបីប្រទេសក្នុងតំបន់អាស៊ាន (០២) **"វគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសន្តិសុខមនុស្សជាតិ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក"** នៅកោះជេជូ សាធារណរដ្ឋកូរ៉េខាងត្បូង។
- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

  បានចាត់បញ្ជូននាយនគរបាលជាន់ខ្ពស់ ដើម្បីទៅចូលរួម (១)វគ្គបណ្តុះបណ្តាល ប្រតិបត្តិការគ្រប់គ្រងការធ្វើសមាហរណកម្មព្រំដែន នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន និង(២)វគ្គបណ្តុះបណ្តាលកម្មវិធីគ្រប់គ្រង និងត្រួតពិនិត្យព្រំដែនលើកទី១៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។

- **ថ្នាក់ក្រោមជាតិ**
- **ខេត្តកំពង់ធំ**

  បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើកុមារ វគ្គទី៧ នៅបណ្ឌិត្យសភាសម្រាប់ការអនុវត្តច្បាប់អន្តរជាតិ International Law Enforcement Academy (ILEA) ទីក្រុងបាងកក ប្រទេសថៃ។

## ១.ខ.សិក្ខាសាលា

### ១.ខ.១.សិក្ខាសាលាក្នុងប្រទេស

- **ថ្នាក់ជាតិ**
- **ក្រសួងអប់រំ យុវជន និងកីឡា**

  បានសហការជាមួយអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ និងអង្គការវីនរ៉ក់អន្តរជាតិ បានរៀបចំសិក្ខាសាលា ស្តីពីការពង្រឹងការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្សនៅកម្ពុជា ចំនួន ១០វគ្គ នៅក្រុង-ស្រុក ទាំង១០ នៃខេត្តកំពង់ចាម ក្នុងនោះមាន៖ ក្រុងកំពង់ចាម ស្រុកបាធាយ ព្រៃឈរ ជើងព្រៃ កំពង់សៀម ចំការលើ កោះសូទិន ស្រីសន្ធរ កងមាស និងស្រុកស្ទឹងត្រង់ មានសិក្ខាកាមចូលរួមចំនួន ៦០០នាក់ (ស្រី ១១៣នាក់)។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
  - បានសហការជាមួយអង្គការ ILO-Triagle រៀបចំសិក្ខាសាលាពិគ្រោះយោបល់ (១)ដើម្បីធ្វើបច្ចុប្បន្នភាពគោលនយោបាយទេសន្តរប្រវេសន៍ការងារ សម្រាប់កម្ពុជាឆ្នាំ២០១៩-២០២៣ ឲ្យកាន់តែមានសុក្រឹតភាព ដែលមានសមាសភាពចូលរួមមកពីគ្រប់ភាគីពាក់ព័ន្ធចំនួន ១២០នាក់ នឹងត្រូវប្រកាសផ្សព្វផ្សាយ ដាក់ឲ្យអនុវត្តជាផ្លូវការណ៍នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨។ (២)ដើម្បីប្រមូលធាតុចូលជាចុងក្រោយពីបណ្តាក្រសួង ស្ថាប័ន សហជីព និយោជក អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធសម្រាប់រៀបចំចងក្រងឯកសារ

គោលការណ៍ណែនាំ ស្តីពីយន្តការទទួលពាក្យបណ្តឹង និងដោះស្រាយវិវាទ ទាក់ទងនឹងទេសន្តរប្រវេសន៍ការងារ។ (៣)ថ្នាក់ជាតិ ត្រៀមសម្រាប់វេទិកាអាស៊ានលើកទី១១ ស្តីពីពលករទេសន្តរប្រវេសន៍ ក្រោមប្រធានបទ ការប្រើប្រាស់ប្រព័ន្ធឌីជីថល ក្នុងការលើកកម្ពស់សមរម្យ សម្រាប់ពលករទេសន្តរប្រវេសន៍ នៅក្នុងក្របខណ្ឌអាស៊ាន ដោយផ្តោតសំខាន់លើ "ការប្រើប្រាស់ប្រព័ន្ធឌីជីថល សម្រាប់គ្រប់គ្រងពលករទេសន្តរប្រវេសន៍ និងសេវាឌីជីថលសម្រាប់ពលករទេសន្តរប្រវេសន៍"។

- បានសហការជាមួយអង្គការ(IOM) រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីចំណាកស្រុកដោយសុវត្ថិភាព និងជំនាញទន់ ដល់ភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ អ្នកផ្តល់សេវា អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន នៅខេត្តសៀមរាប សិក្ខាកាមចូលរួមចំនួន ៥០នាក់ (ស្រី ១៨នាក់)។
- បានរៀបចំសិក្ខាសាលា៖ (១)គោលនយោបាយ ស្តីពីទេសន្តរប្រវេសន៍ការងារ និងគោលការណ៍ណែនាំ ស្តីពីយន្តការទទួលពាក្យបណ្តឹង និងដោះស្រាយវិវាទទាក់ទងនឹងទេសន្តរប្រវេសន៍ មានសិក្ខាកាមចូលរួមចំនួន ៧០នាក់។ (២)ស្តីពីការចាប់ផ្តើមអនុវត្តគម្រោងសុវត្ថិភាព និងសមធម៌(Safe and Fair)សម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី ក្នុងក្របខណ្ឌអាស៊ានទាំង១០ប្រទេស គម្រោងនេះមានគោលបំណងសំខាន់ចំនួន ៣គឺ ការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ ក្នុងក្របខណ្ឌអាស៊ាន ការលុបបំបាត់អំពើហិង្សាលើស្ត្រីពលករទេសន្តរប្រវេសន៍ ក្នុងក្របខណ្ឌអាស៊ាន និងប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្មជាស្ត្រី ក្នុងក្របខណ្ឌអាស៊ាន។ (៣)ផ្សព្វផ្សាយ ស្តីពីការលើកកម្ពស់ការយល់ដឹងអំពីនីតិវិធី និងការធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់ ដល់អាជ្ញាធរមូលដ្ឋាន នៅខេត្តកំពង់ចាម សិក្ខាកាមចូលរួមចំនួន ១៥៥នាក់ (ស្រី ៥០នាក់)។

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានរៀបចំសិក្ខាសាលាស្តីពី "**គោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប**" នៅស្រុកចម្ការលើ ខេត្តកំពង់ចាម ដែលមានសិក្ខាកាមចូលរួមសរុប ៧០នាក់ (ស្រី ១៥នាក់) សមាសភាពមានដូចជា៖ មន្ត្រីថ្នាក់ស្រុក មន្ទីរស.អ.យស្រុក មេឃុំ មេភូមិ មន្ត្រីនៃគណៈកម្មាធិការការពារស្ត្រីនិងកុមារ(គ.ក.ន.ក) គ្រូបង្រៀន គ្រូពេទ្យ និងនគរបាលប៉ុស្តិ៍។
- បានរៀបចំសិក្ខាសាលាស្តីពី "**ការពង្រឹងយន្តការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស**" មានសិក្ខាកាមចូលរួមសរុប ៦៥នាក់ (ស្រី ២៩នាក់) សមាសភាពចូលរួមជាក្រុមការងារការពារជនរងគ្រោះ នៃគ.ជ.ប.ជ និងអង្គការដៃគូ នៅទីស្តីការក្រសួងសង្គមកិច្ច។

▪ **ក្រសួងកិច្ចការនារី**

បានរៀបចំសិក្ខាសាលាបូកសរុបការបញ្ចប់គម្រោង ស្តីពី "**ការទប់ស្កាត់អំពើជួញដូរផ្លូវភេទនៅកម្ពុជា**" ក្នុងគោលបំណងបង្ហាញអំពីសមិទ្ធផល បទពិសោធន៍ និងការអនុវត្តល្អ និងមានការចូលរួមពីក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ និងតំណាងក្រសួងសមភាពយេនឌ័រ និងគ្រួសារនៃប្រទេសកូរ៉េ មានចំនួន ៤៦នាក់ (ស្រី ៣១នាក់)។

- **ក្រសួងទេសចរណ៍**

  បានរៀបចំសិក្ខាសាលា ស្តីពី "**ការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍**" ដល់ម្ចាស់មូលដ្ឋាន អាជីវកម្ម សេវាកម្មទេសចរណ៍ មន្ទីរ អង្គភាព សមត្ថកិច្ច អាជ្ញាធរ ដែនដីពាក់ព័ន្ធ និងយុវជន នៅតាមបណ្តាខេត្តចំនួន ០៣ រួមមាន៖ ខេត្តពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តស្ទឹងត្រែង ក្នុងគោលបំណងដើម្បីចូលរួមលើកកម្ពស់ និងការទប់ស្កាត់ ការកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ សិក្ខាកាមចូលរួមចំនួន **២២៨**នាក់ (ស្រី **១០០**នាក់)។

- **ថ្នាក់ក្រោមជាតិ**

- **ខេត្តត្បូងឃ្មុំ**

  លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការស៊ីកាស្វា និងអង្គការភ្លែនអន្តរជាតិប្រចាំខេត្ត រៀបចំសិក្ខាសាលា ស្តីពីការអនុវត្តល្អ និងការពង្រឹងនីតិវិធីនគរបាលយុត្តិធម៌បែបកុមារមេត្រី និងសេវាសង្គម សមាសភាពចូលរួមមាន អភិបាលរង ស្នងការរង អធិការដ្ឋាននគរបាលក្រុងស្រុកទាំង៧ ប៉ុស្តិ៍នគរបាលប្រចាំច្រកព្រំដែនវៀតណាម ប៉ុស្តិ៍នគរបាលឃុំទាំង១២ ក្នុងស្រុកពញាក្រែក ស្រុកតំបែរ និងមន្ទីរពាក់ព័ន្ធនានា សរុបចំនួន **៧៩**នាក់ (ស្រី **៣៣**នាក់)។

- **ខេត្តកំពត**

  **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត** បានរៀបចំសិក្ខាសាលា ស្តីពីការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ដៃគូអនុវត្តន៍កម្មវិធីត្រីកោណ ក្នុងតំបន់អាស៊ាន មានសិក្ខាកាមចូលរួមចំនួន **១៩**នាក់ (ស្រី **០៤**នាក់)។

- **ខេត្តបាត់ដំបង**

  **លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំសិក្ខាសាលា៖**

  - ស្តីពីកិច្ចសហការ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្រ្តៃយ៍ គ.ជ.ប.ជ ដែលមានសមាសភាពចូលរួម៖ អភិបាលរងក្រុង/ស្រុក ស្នងការដ្ឋាននគរបាលខេត្ត កងរាជអាវុធហត្ថខេត្ត មន្ទីរទេសចរណ៍ខេត្ត មន្ទីរឧស្សាហកម្មនិងសិប្បកម្មខេត្ត មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត អយ្យការអមសាលាដំបូងខេត្ត មជ្ឈមណ្ឌលការងារខេត្ត អង្គការ IJM អង្គការWorld Vision លោកមេឃុំ និងមន្ត្រីនៃគណៈកម្មាធិការការពារស្ត្រីនិងកុមារ (គ.ក.ន.ក) និងអង្គការ ស្ថាប័នពាក់ព័ន្ធ សរុបចំនួន **៨៧**នាក់ (ស្រី**៤៩**នាក់)។
  - សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការប្រមូលអ្នកស្វែងរកការងារធ្វើនៅតាមមូលដ្ឋាននានាចំនួន **០៣**លើក មានអ្នកចូលរួមសរុប **១៤៥**នាក់ (ស្រី **២២** នាក់)។
  - ស្តីពីការប្រើប្រាស់ប្រាក់ឈ្នួល និងបើកប្រាក់បំណាច់អតីតភាពការងារជូនកម្មករ និយោជិក តាមប្រកាសលេខ(៤៤២ និង៤៤៣) មានអ្នកចូលរួមសរុប **១៣៨**នាក់ (ស្រី **៤៣**នាក់)។

- **ខេត្តកណ្តាល**

  បានសហការជាមួយអង្គការមូលនិធិហាការអន្តរជាតិ បើកសិក្ខាសាលាលើកកម្ពស់ការយល់ដឹងស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងទប់ស្កាត់អំពើជួញដូរមនុស្ស នៅភូមិព្រៃកតាទែន ឃុំស្វាយប្រទាល ស្រុកពញាឮ មានសិក្ខាកាមសរុប **២០០**នាក់។

- **ខេត្តស្វាយរៀង**

  បានសហការជាមួយអង្គការឆោលហ្សាន់កម្ពុជា រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ និងការជួញដូរគ្រឿងញៀនតាមបណ្តាគោលដៅទាំង១៣ នៅក្នុងស្រុកស្វាយជ្រំ និងស្រុករមាសហែក ខេត្តស្វាយរៀង មានអ្នកចូលរួមសរុប ៨៣នាក់ (ស្រី ២៥នាក់)។

### ១.១.២.សិក្ខាសាលាក្រៅប្រទេស

- **ថ្នាក់ជាតិ**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

  លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញទៅចូលរួមសិក្ខាសាលាការលើកកម្ពស់ការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ ស្តីពីដំណើរការចុះបញ្ជី និងអ្នកគ្មានឯកសារ ប្រព្រឹត្តទៅនៅសណ្ឋាគារហ៊ើលតុន ទីក្រុងបាងកក ប្រទេសថៃ។

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

  បានចាត់បញ្ជូនថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋាន ០១រូប ទៅចូលរួមសិក្ខាសាលាគោលនយោបាយអនុតំបន់មេគង្គលើកទី២ ស្តីពីភាពទៀងទាត់ និងការគ្រប់គ្រងទេសន្តរប្រវេសន៍អាពាហ៍ពិពាហ៍ ដែលរៀបចំដោយអង្គការ IOM នៅខេត្តគ័ងចូវ សាធារណរដ្ឋប្រជាមានិតចិន។

## ២.សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ២.ក.សន្និសីទថ្នាក់ជាតិ និងអន្តរជាតិ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

  លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងក្រុមការងារដែលមាន ក្រសួងកិច្ចការនារី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប និងអង្គការគាំទ្រផ្នែកច្បាប់ដល់កុមារ និងស្ត្រី (LSCW) បានចូលរួមសន្និសីទអន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍រវាងថៃ-កម្ពុជា ស្តីពីពលករទេសន្តរប្រវេសន៍ នៅទីក្រុងបាងកក ប្រទេសថៃ រៀបចំដោយគម្រោង MIG-GIGHTS របស់អង្គការក្រុមអ្នកស្ម័គ្រចិត្តអ៊ីតាលី(GVC)។

### ២.ខ.កិច្ចប្រជុំ ជាអន្តរជាតិនៅក្នុងប្រទេស និងក្រៅប្រទេស

> **កិច្ចប្រជុំក្នុងប្រទេសជាលក្ខណៈអន្តរជាតិ**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

  បានរៀបចំកិច្ចប្រជុំពិភាក្សាការងារជាមួយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនិងការងារ និងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច នៃរដ្ឋគូវ៉ែត ស្តីពី **"ការផ្លាស់ប្តូរវិស័យកម្លាំងពលកម្មរវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋគូវ៉ែត"** និងការស្វែងយល់អំពីឱកាសវិនិយោគ នៃរដ្ឋគូវ៉ែត នៅកម្ពុជា។

- **អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

  - បានរៀបចំកិច្ចប្រជុំទ្វេភាគី លើកទី២ កម្ពុជា-ចិន ដើម្បីអនុវត្តកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ស្តីពីសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅរាជធានីភ្នំពេញ។

- បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងប្រទេសបញ្ជូន ចំនួន បីប្រទេស (កម្ពុជា ឡាវ ភូមា) ស្តីពីតួនាទីប្រទេសបញ្ជូន ក្នុងការលើកកម្ពស់សុវត្ថិភាពពលករក្នុងប្រទេសថៃ នៅខេត្តសៀមរាប។

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

បានរៀបចំកិច្ចប្រជុំអគ្គស្នងការដ្ឋាននគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា ជាមួយខេត្តស្រះកែវនៃព្រះរាជាណាចក្រថៃ **ស្តីពីកិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមបណ្តោយព្រំដែន។**

➢ **កិច្ចប្រជុំនៅក្រៅប្រទេស**

- **ថ្នាក់ជាតិ**

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានអញ្ជើញជា៖

- **តំណាងដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ**ព្រះរាជាណាចក្រកម្ពុជា** ទៅចូលរួមក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំកំពូល ដើម្បីអនុម័តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយនិងស្របច្បាប់ ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ នៅទីក្រុងម៉ារ៉ាគិច ប្រទេសម៉ារ៉ុក ដែលមានអ្នកចូលរួមក្នុងកិច្ចប្រជុំមានប្រមាណជាង២.០០០នាក់ ជាថ្នាក់ដឹកនាំប្រទេស និងតំណាងមកពីជាង២០០ប្រទេស ជុំវិញពិភពលោក។
- **តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
  - ◦ បានអញ្ជើញចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំកំពូល ដើម្បីអនុម័តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយនិងស្របច្បាប់ នៅអង្គការសហប្រជាជាតិ ទីក្រុងញូវយ៉ក។
  - ◦ បានដឹកនាំប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ទៅចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ និងសន្និសីទថ្នាក់រដ្ឋមន្ត្រី លើកទី៧ បាលីប្រូសេស(Bali Process) ស្តីពីការរត់ពន្ធ ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនពាក់ព័ន្ធ ប្រព្រឹត្តទៅនៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី ដោយមានការចូលរួមពីថ្នាក់រដ្ឋមន្ត្រី តំណាងប្រទេសចំនួន ៤៦ នៅជុំវិញពិភពលោក។
- **បានចូលរួមដឹកនាំ៖**

(១)កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី និងបញ្ជូនមន្ត្រីជាន់ខ្ពស់ចូលរួមកិច្ចប្រជុំ របស់ Bali Process ស្តីពីទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស នៅទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី។ (២) បានដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តកោះកុង ដើម្បីអញ្ជើញជួបពិភាក្សាការងារអំពីពលករនេសាទ ដែលមិនមានឯកសារច្បាប់គ្រប់គ្រាន់ ជាមួយអាជ្ញាធរខេត្តត្រាត តំណាងក្រសួងការងារ និង នាយកដ្ឋានជលផលថៃ ក្នុងខេត្តត្រាត ប្រទេសថៃ។

- **ក្រសួងកិច្ចការនារី**

ដឹកនាំដោយលោកជំទាវ **សាន្ត អរុណា** រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាប្រធានខមមីតកម្ពុជា បានដឹកនាំប្រតិភូចំនួន ០៦រូប (ស្រី ០៤រូប) មាន តំណាងក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជននិងកីឡា អង្គការ UN-ACT និងអង្គការរតនៈអន្តរជាតិ ចូលរួមប្រជុំ ស្តីពីការអនុវត្តច្បាប់ និងកិច្ចសម្របសម្រួលជនរងគ្រោះ និងកិច្ចប្រជុំខមមីតថ្នាក់តំបន់ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋាន ចំនួន ០៣រូប ទៅចូលរួមកិច្ចប្រជុំ ស្តីពី "សន្និសីទ នៃប្រទេសទាំង០៦ក្នុងសកម្មភាពរួមប្រឆាំងការជួញដូរមនុស្ស៖ **Working conference of the six countries joint action against human trafficking**" (ចិន ភូមា ថៃ ឡាវ វៀតណាម កម្ពុជា) នៅទីក្រុងគន់មិញ ខេត្តយន់ណាន សាធារណរដ្ឋប្រជាមានិតចិន។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំ០១រូប នៃក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ទៅចូលរួមប្រជុំ នៅបាលី ស្តីពី " សន្និសីទ អាស៊ីអគ្នេយ៍ ស្តីពី ការសម្របសម្រួលសហការ ក្នុងតំបន់ និងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចពលកម្ម ក្នុងវិស័យនេសាទ៖ **Southeast Asia Conference on Regional Coordination, and Action to Combat Trafficking and Labour Exploration in Fisheries ដែលជំរុញឲ្យមានការផ្តល់សច្ចាប័នលើ C.188**" និងសិក្ខាសាលាស្តីពី៖ "ការលើកកម្ពស់ការងារត្រឹមត្រូវ សម្រាប់ពលករនេសាទ ក្នុងតំបន់អាស៊ីអគ្នេយ៍៖ **Promotion of Decent Work for Fishers in Southeast Asia**"។

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

បានចាត់បញ្ជូននាយនគរបាលជាន់ខ្ពស់ ដើម្បីទៅចូលរួម៖ (១)កិច្ចប្រជុំពិភាក្សាតុមូលចែករំលែកបទពិសោធន៍ជំនាញទេសន្តរប្រវេសន៍អឺរ៉ុប (Migration EU Expertise) នៅប្រទេសថៃ។ (២)កិច្ចប្រជុំទ្វេភាគី ស្តីពីការពង្រឹងសម្ព័ន្ធភាពអន្តោប្រវេសន៍ថៃ-កម្ពុជា នៅខេត្តស្រះកែវ ប្រទេសថៃ។ (៣)កិច្ចប្រជុំកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់អន្តរជាតិកម្ពុជា-ចិន នៅខេត្តជាំងស៊ី សាធារណរដ្ឋប្រជាមានិតចិន។

- **ថ្នាក់ក្រោមជាតិ**

- **ខេត្តមណ្ឌលគិរី**

ស្នងការនៃស្នងការដ្ឋាននគរបាលខេត្ត បានដឹកនាំគណៈប្រតិភូ ចំនួន ០២លើក ដើម្បីទៅចូលរួមប្រកិច្ចប្រជុំបូកសរុបលទ្ធផលការងារសហប្រតិបត្តិការ ស្តីពីការរក្សាសន្តិសុខព្រំដែន និងការបង្ការ ទប់ស្កាត់បទល្មើសផ្សេងៗ នៅបញ្ជាការដ្ឋានកងទ័ពការពារព្រំដែន ខេត្តដាក់ណុង ប្រទេសវៀតណាម។

- **ខេត្តព្រះវិហារ**
  ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធាន គ.ខ.ប.ជ បានចូលរួមកិច្ចប្រជុំថ្នាក់ខេត្ត រវាងខេត្តព្រះវិហារ និងខេត្តចំប៉ាសាក់ ស្តីពីកិច្ចសហប្រតិបត្តិការទប់ស្កាត់បទល្មើស និងការការពារសន្តិសុខសណ្តាប់ធ្នាប់តាមបណ្តោយព្រំដែន ជាពិសេសពាក់ព័ន្ធការឆ្លងដែនខុសច្បាប់ និងអំពើជួញដូរមនុស្ស នៅខេត្តចំប៉ាសាក់ ប្រទេសឡាវ។
- **ខេត្តស្វាយរៀង**
  បានចូលរួមកិច្ចប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការទប់ស្កាត់បទល្មើស និងការការពារសន្តិសុខសណ្តាប់ធ្នាប់តាមតំបន់ព្រំដែន រវាងនគរបាលខេត្តតៃនិញ នៃប្រទេសវៀតណាម និងស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ព្រៃវែង និងខេត្តត្បូងឃ្មុំ នៃព្រះរាជាណាចក្រកម្ពុជា នៅមន្ទីរនគរបាលខេត្តតៃនិញ ប្រទេសវៀតណាម។
- **ខេត្តកោះកុង**
  ស្នងការដ្ឋាននគរបាលខេត្ត បានចាត់បញ្ជូនមន្ត្រីនគរបាលថ្នាក់នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីទៅចូលរួមកិច្ចប្រជុំក្រុមលេខាធិការដ្ឋាន នៃគណៈកម្មាធិការភូមិភាគកម្ពុជា-ថៃ លើកទី២១ រវាងភាគីកម្ពុជា (យោធភូមិភាគ៣) និងភាគីថៃ (កងបញ្ជាការការពារព្រំដែនខេត្តច័ន្ទបុរី និងខេត្តត្រាត) លើកទី២១ នៅខេត្តច័ន្ទបុរី ដែលមានការអញ្ជើញចូលរួមពីអង្គភាព និងមន្ទីរពាក់ព័ន្ធក្នុងខេត្ត។ អង្គប្រជុំបានលើកឡើងនៅចំណុចរួមមួយ គឺរួមគ្នាបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសការជួញដូរមនុស្សរវាងប្រទេសទាំងពីរ ដើម្បីដាក់ជូនគណៈកម្មាធិការ ថ្នាក់ភូមិភាគ នៃប្រទេសទាំងពីរពិនិត្យ និងសម្រេច។

## ២.គ.ទស្សនកិច្ចសិក្សា

➢ **ទស្សនកិច្ចក្រៅប្រទេស**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**
  - សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជាទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋឥណ្ឌា ដែលក្នុងដំណើរទស្សនកិច្ចនោះ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាតំណាងដ៏ខ្ពស់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយភាគីឥណ្ឌានូវ "**អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស**"។
  - លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំក្រុមការងារនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
    - (១)ទៅធ្វើទស្សនកិច្ចនៅតាមក្រុមហ៊ុនសំណង់មួយចំនួន ក្នុងខេត្តច័ន្ទបុរី ប្រទេសថៃ (រៀបចំដោយសមាគមពលករខ្មែរ-ថៃ)។
    - (២)ជួបសំណេះសំណាលនៅសហគមន៍គ្រួសារទេសន្តរប្រវេសន៍ខ្មែរ នៅខេត្តសមុទ្រប្រាកាន ប្រទេសថៃ (រៀបចំដោយអង្គការLPN) ដើម្បីស្វែងយល់ពីសុខទុក្ខពលករពលការិនីកម្ពុជា ក្នុងប្រទេសថៃ។
    - (៣)សហការជាមួយអភិបាលខេត្តកោះកុង ចុះសិក្សាស្វែងយល់ពីស្ថានភាពការងារ និងការរស់នៅរបស់ពលករកម្ពុជាក្នុងវិស័យនេសាទ ក្នុងសមាគមអ្នកនេសាទខេត្តត្រាត។

- **ថ្នាក់ក្រោមជាតិ**

- **ខេត្តបាត់ដំបង**

លេខាធិការដ្ឋានគ.ខ.ប.ជខេត្តបាត់ដំបង បានចូលរួមទស្សនកិច្ចអន្តរជាតិសម្រាប់ការពិភាក្សារវាងប្រទេសកម្ពុជា និងប្រទេសថៃ ស្តីពីបញ្ហាការជួញដូរមនុស្ស និងការចំណាកស្រុក នៅទីក្រុងបាងកក ប្រទេសថៃ។

## ២.ឃ.ការទទួលជួបពិភាក្សាការងារ

- **ថ្នាក់ជាតិ**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអនុញ្ញាតទទួលជួបពិភាក្សាការងារៈ

- (១)ជាមួយMr. RODRIGO តំណាងអង្គការUNDP, តំណាងអង្គការ UN-WOMEN និងលោក **លឹម ទិត្យ** តំណាងUN-ACT ស្តីអំពីករណីពពោះជំនួស នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- (២)ជាមួយតំណាងការិយាល័យ ឧត្តមស្នងការសិទ្ធិមនុស្ស ប្រចាំកម្ពុជាៈ High Commissioner for Human Rights (OHCHR – Cambodia) អំពីករណីពពោះជំនួស នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- (៣)ជាមួយតំណាងអង្គការ Winrock International មកពីទីស្នាក់ការកណ្តាល ទីស្នាក់ការតំបន់ និងប្រចាំនៅកម្ពុជា អំពីដំណើរការបន្តនៃកិច្ចប្រតិបត្តិការ។
- (៤)ជាមួយតំណាងដៃគូនានា មានសម្ព័ន្ធអង្គការចាប់ដៃ អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) អង្គការ IRIC អង្គការមូលនិធិកុមារ (Child Fund) អំពីកិច្ចសហប្រតិបត្តិការ។
- (៥)អង្គការ Plan, Cambodia ACTs ពិភាក្សាអំពី គម្រោងស្រាវជ្រាវប្រមូលទិន្នន័យ។

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

ថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ(ក្រុមជំនួយកិច្ចការយុត្តិធម៌)

- (១)បានទទួលជួបពិភាក្សាការងារ និងចែករំលែកបទពិសោធន៍ដល់ក្រុមសិក្សាស្រាវជ្រាវតំបន់អាស៊ី(RAPID ASIA) ចំនួន០២រូប ស្តីពីការអនុវត្តក្របខ័ណ្ឌច្បាប់នៅកម្ពុជាទាក់ទងទៅនឹងសំណងរដ្ឋប្បវេណី និងសំណងបដិទាន ទៅដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្សេងៗ នៅអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។
- (២)បានទទួលជួប ពិភាក្សាការងារ និងធ្វើបទបង្ហាញពីរចនាសម្ព័ន្ធ និងយន្តការជាតិ ថ្នាក់ក្រោមជាតិ ឆ្លើយតបក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ព្រមទាំងផែនការសកម្មភាពជាតិដល់ក្រុមសិក្សាស្រាវជ្រាវ របស់ USAID ប្រចាំតំបន់ និងអង្គការ WINROCK ប្រចាំនៅកម្ពុជា នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

## ៣.ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសមាន ៦១៤លើក មានអ្នកចូលរួមសរុប ២៦.០៨៥នាក់ (ស្រី ១៩.០៩៣នាក់) ក្នុងនោះគណៈកម្មាធិការ

ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ចំនួន **២៤៣**លើក ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងកិច្ចការនារី កាកបាទក្រហមកម្ពុជា អគ្គនាយកដ្ឋានអន្តោប្រវេសន៍ សរុបចំនួន ៨៤លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ២៨៧លើក។ **(ឧបសម្ព័ន្ធ២)**

## IV.ការសន្និដ្ឋានវាយតម្លៃ

### ១.ចំណុចខ្លាំង

- ការគាំទ្ររបស់រាជរដ្ឋាភិបាល ចំពោះសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស ដែលត្រូវបានចាត់ទុកថាជាការងារអាទិភាពមួយដ៏សំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់លទ្ធភាពឲ្យមានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពក្នុងក្របខ័ណ្ឌនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការចូលរួមជាមួយថ្នាក់តំបន់ និងសកលលោក។
- គោលនយោបាយសន្តិសុខជាតិ និងការដាក់ចេញនូវរបបសន្តិសុខសង្គម ក៏ដូចជាការលើកកម្ពស់ជីវភាព និងលក្ខខណ្ឌការងារ សម្រាប់ពលករក្នុងស្រុក និងគោលនយោបាយទេសន្តរប្រវេសន៍ជាតិរបស់រាជរដ្ឋាភិបាល បានផ្តល់នូវថាមពលដ៏ខ្លាំងក្លាសម្រាប់ជាវិធានការ បង្ការទប់ស្កាត់ភាពរងគ្រោះរបស់ពលករ និងធ្វើឲ្យបរិយាកាសការងារ ក្នុងព្រះរាជាណាចក្រកម្ពុជា បានកាន់តែល្អប្រសើរ។
- ក្រសួង ស្ថាប័នពាក់ព័ន្ធជាសមាជិក នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) បានដាក់ចេញនូវគោលនយោបាយ គោលការណ៍ វិធានការ ផែនការសកម្មភាព និងបទដ្ឋានការងារជាច្រើន ដែលធ្វើឲ្យសកម្មភាពបង្ការ ទប់ស្កាត់ ការពារ សង្គ្រោះ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទគ្រប់រូបភាព កាន់តែមានប្រសិទ្ធភាព។
- យន្តការជាតិ ដ៏ទូលំទូលាយ ច្បាស់លាស់ និងប្រកបដោយការទទួលខុសត្រូវ តាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ រួមទាំងការចូលរួមពីអង្គការសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិជាច្រើនទៀត បានក្លាយជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុប ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។
- កម្ពុជាបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិនានា ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព និងសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើពេស្យាចារកុមារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។ បានផ្តល់នូវការយោគយល់គ្នា និងកិច្ចសហការល្អ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាបានកាន់តែរលូន។
- ការបំពេញបន្ថែមក្នុងក្របខណ្ឌច្បាប់ ដែលនៅមានភាពខ្វះចន្លោះ ឆ្លើយតបទៅនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ទាំងក្របខណ្ឌអនុវត្តក្នុងប្រព័ន្ធយុត្តិធម៌ និងកិច្ចសហការអន្តរជាតិ បានធ្វើឲ្យការអនុវត្តច្បាប់បានកាន់តែទូលំទូលាយ ក្នុងក្របខណ្ឌអន្តរជាតិ។
- អនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងវិធានការ ០៦ចំណុច របស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតែជាត្រីវិស័យសម្រាប់តម្រង់ទិសការងារ ដល់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យទទួលបានប្រសិទ្ធភាពខ្ពស់។

## ២.ចំណុចខ្វះខាត និងភាពប្រឈម

- កិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសពាក់ព័ន្ធ ក្នុងការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ជាពិសេសក្នុងប្រទេសគោលដៅ នៅមានកម្រិត ដែលធ្វើឲ្យបញ្ហាខ្លះ មិនអាចឆ្លើយតប ឬដោះស្រាយបានទាន់ពេល និងពេញលេញបាន។
- ខ្វះការវាយតម្លៃប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការជាមួយប្រទេសពាក់ព័ន្ធ តាមការកំណត់ក្នុងកិច្ចព្រមព្រៀង ឬអនុស្សរណៈ។
- ស្ថាប័នអនុវត្តមួយចំនួន នៅមិនទាន់មានកិច្ចសហការល្អគ្រប់គ្រាន់ មិនទាន់បើកទូលាយ ឬជួយបង្កលក្ខណៈ និងផ្តល់ធនធានសម្រាប់ប្រតិបត្តិការជាប្រព័ន្ធ ដែលអាចឆ្លើយតបបញ្ហាទាន់ហេតុការណ៍ដោយប្រសិទ្ធភាពបាននៅឡើយ។
- ខ្វះកំណត់ត្រា និងការចងរបាយការណ៍ជាក់លាក់ដែលបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នក្នុងការរួមចំណែកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលបាននិងកំពុងប៉ះពាល់ដល់ដំណើរការនៃការអភិវឌ្ឍជាតិ តាមវិស័យនីមួយៗ។
- មន្ត្រីទទួលបន្ទុកនៅតាមក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមួយចំនួន (ជាពិសេសមន្ត្រីទទួលមុខតំណែងថ្មី) នៅមិនទាន់យល់ច្បាស់ពីការងារ និងតួនាទីភារកិច្ច ជាសមាជិកគណៈកម្មាធិការជាតិ ដែលត្រូវរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗ។
- របាយការណ៍ដែលផ្ញើមកអគ្គលេខាធិការដ្ឋាន តែងតែយឺតយ៉ាវ មិនទាន់ពេលវេលា។

## ៣.សំណូមពរ

- ត្រូវមានគម្រោង និងបានជួបពិភាក្សា ទៀងទាត់ ជាមួយប្រទេសជាភាគី នៃកិច្ចព្រមព្រៀង ឬអនុស្សរណៈ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីពិនិត្យ កែលម្អចំណុចខ្វះខាត និងពង្រឹងកិច្ចសហប្រតិបត្តិការ។
- ស្នើការជំរុញ និងពង្រឹងបន្ថែមពីថ្នាក់ដឹកនាំក្រសួង និងប្រធានអង្គភាព ស្ថាប័នជាសមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងអភិបាលរាជធានី ខេត្ត ដែលជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី ខេត្ត អំពីការចាត់តាំងអ្នកទទួល ខុសត្រូវឲ្យបានច្បាស់លាស់ និងរបៀបរបបការងារ ដើម្បីពង្រឹងការទទួលខុសត្រូវ ទំនាក់ទំនង កិច្ចសហប្រតិបត្តិការ និងការធ្វើរបាយការណ៍ ស្តីពីសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដូចមានចែងក្នុងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងអនុក្រឹត្យ និងសេចក្តីសម្រេច ពាក់ព័ន្ធនឹងតួនាទីភារកិច្ចរបស់ក្រសួងស្ថាប័នជាសមាជិក។
- បង្កើនវគ្គបណ្តុះបណ្តាលដល់មន្ត្រីជួរមុខ និងមន្ត្រីអនុវត្តន៍ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើឲ្យមានផែនការជាក់លាក់ និងសុំការគាំទ្រធនធាន និងស្មារតី ឲ្យបានសមស្រប តាមការគ្រោងទុកដើម្បីសម្រួលដល់ដំណើរការកិច្ចប្រតិបត្តិការរបស់ក្រុមការងារ និងមន្ត្រីអនុវត្តន៍។

## ៤.សន្និដ្ឋាន

- អាស្រ័យដោយមានការគាំទ្រ និងយកចិត្តទុកដាក់យ៉ាងខ្លាំងពីរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ

ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានធ្វើឲ្យសភាពការណ៍សន្តិសុខ សុវត្ថិភាព របស់ប្រជាពលរដ្ឋកម្ពុជា កាន់តែត្រូវបានយកចិត្តទុកដាក់ប្រសើរឡើង។ ប្រជាជនគ្រប់រូប គ្រប់មជ្ឈដ្ឋាន បានទទួលការការពារ យ៉ាងហ្មត់ចត់ ទើបធ្វើឲ្យស្ថានភាពជួញដូរមនុស្សនៅកម្ពុជា មានការប្រែប្រួលតិចតួច និងអាចគ្រប់គ្រងបាន។ ទន្ទឹមនឹងនោះ ការគិតគូពីរបបសន្តិសុខសង្គម សម្រាប់ពលករ ពលការិនី និយោជិកក្នុងវិស័យឯកជន និងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ត្រូវបានបង្កើតឡើង និងយកចិត្តទុកដាក់ខ្ពស់ពី រាជរដ្ឋាភិបាល ដែលធ្វើឲ្យបរិយាកាសសង្គមកាន់តែល្អប្រសើរ។

- រាជរដ្ឋាភិបាលកម្ពុជាមានច្បាប់ គោលនយោបាយគ្រប់គ្រាន់ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការគោរពសិទ្ធិ និងផលប្រយោជន៍ប្រជាពលរដ្ឋ ការពារសុវត្ថិភាព ពីភាពរងគ្រោះ ជាពិសេស ដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព។
- តួនាទីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាយន្តការជាតិ និងជាសេនាធិការរបស់រាជរដ្ឋាភិបាល មានសារសំខាន់ និងមានសក្តានុពលខ្ពស់ក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនធានមនុស្សដ៏ទូលំទូលាយ ដែលមានឆន្ទៈ មនសិកា និងការប្តេជ្ញាចិត្តមុះមុត និងមានសមត្ថភាពដោះស្រាយរាល់បញ្ហា ដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាប សង្គ្រោះ និងការពារជនរងគ្រោះពីអំពើជួញដូរមនុស្ស។
- ល្បិចកលរបស់ឧក្រិដ្ឋជនជួញដូរមនុស្សក្នុងការប្រព្រឹត្តបទល្មើស មានការប្រែប្រួល បត់បែន កាន់តែស្មុគស្មាញ និងពិបាកកំណត់។ ទោះបីយ៉ាងនេះក្តី ក៏មន្ត្រីអនុវត្តន៍ កាន់តែមានជំនាញ មានបទពិសោធន៍កាន់តែស៊ីជម្រៅ និងកាន់តែមានការចូលរួម និងកិច្ចសហការល្អពីអ្នកពាក់ព័ន្ធជាតិ និងអន្តរជាតិ។
- ប្រជាពលរដ្ឋកាន់តែច្រើនឡើងៗមានការយល់ដឹងពីអំពើជួញដូរមនុស្ស ផលប៉ះពាល់ និងព្រមទាំងមានការប្រុងប្រយ័ត្នខ្ពស់ និងចេះការពារខ្លួនពីភាពរងគ្រោះដោយអំពើជួញដូរមនុស្ស។
- ទោះបីជាយ៉ាងនេះក្តី ប្រភេទបទល្មើសដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សថ្មីៗ បានកើតមានជាបន្តបន្ទាប់ ដែលចាំបាច់ត្រូវតែបន្តការយកចិត្តទុកដាក់ដោះស្រាយជាបន្ទាន់ និងជាបន្តបន្ទាប់។

## V.ទិសដៅឆ្នាំ២០១៩

១.បន្តពង្រឹងកិច្ចសហការឲ្យបានទូលំទូលាយ ទាំងក្នុងក្របខណ្ឌជាតិ និងជាមួយបណ្តាប្រទេសពាក់ព័ន្ធជាអន្តរជាតិ ដើម្បីឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ការពារ និងបង្ក្រាប ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២.រៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ និងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួល។

៣.ត្រៀមកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន លើកទី៣ ស្តីពីការអនុវត្តកិច្ចព្រមព្រៀង ស្តីពីកិច្ចសហការ បង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៤.ត្រៀមកិច្ចប្រជុំទ្វេភាគី លើកទី១ ស្តីពីការអនុវត្តអនុស្សរណៈ កម្ពុជា-ឥណ្ឌា ប្រឆាំងការជួញដូរមនុស្ស។

៥.ជំរុញ និងតាមដានការកសាងអនុស្សរណៈ ឬកិច្ចព្រមព្រៀង ស្តីពីកិច្ចការពារសុវត្ថិភាពពលករ ក្នុងវិស័យនេសាទសមុទ្រ។

៦.ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូជាតិ និងអន្តរជាតិ ជំរុញអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលបានអនុម័ត នៅខែធ្នូ ឆ្នាំ២០១៨។

៧.សហការជាមួយអង្គការដៃគូ សិក្សាស្រាវជ្រាវលើសេវាកម្មនានា ដែលផ្តល់ជូនពលករ និងការស្រាវជ្រាវដទៃទៀតដែលចាំបាច់។

៨.ពង្រឹង និងពង្រីកកិច្ចសហការ កាន់តែទូលំទូលាយ ឈានទៅដោះស្រាយ ភាពងាយរងគ្រោះរបស់កុមារគ្រប់រូបភាព រួមទាំង កុមារ ក្នុងគ្រួសារទេសន្តរប្រវេសន៍ ។

៩.ពង្រឹងការអនុវត្តច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម អំពើជួញដូរផ្លូវភេទ ការដកហូតសរីរាង្គ អំពើជួញដូរទារក និងកុមារឆ្លងដែន អំពើពពោះជំនួស អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

១០.ជំរុញការកសាងច្បាប់ (ច្បាប់ស្តីពី អំពើពពោះជំនួស) និងវិសោធនកម្មច្បាប់ (ក្រមព្រហ្មទណ្ឌ)ឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់។

១១.សម្រេចបញ្ចប់លើសេចក្តីព្រាង និងប្រកាសដាក់ឲ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ (២០១៩-២០២៣) របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

១២.ចុះពិនិត្យ ស្ថានភាពប្រែប្រួល និងចំណុចសេសសល់ លើការងារលើកកម្ពស់សុវត្ថិភាពពលករនៅក្រៅប្រទេស ដើម្បីមានវិធានការ។

១៣.គាំទ្រនិងពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ និងពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

១៤.បន្តពង្រឹងការងារបង្ការ ទប់ស្កាត់ តាមរយៈការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

១៥.រៀបចំវេទិកាអន្តរសាសនា លើកទី៣ ប្រឆាំងអំពើជួញដូរមនុស្ស។

១៦.រៀបចំទិវាជាតិ ១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើកទី១៣ នៅថ្នាក់ជាតិ និងនៅទូទាំងប្រទេស។

១៧.បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ដើម្បីបំផុសប្រជាពលរដ្ឋ ឲ្យយល់ដឹង និងមានវិធានការ បង្ការ ទប់ស្កាត់ និងការពារខ្លួន ពីអំពើជួញដូរមនុស្ស អំពើជួញដូរកុមារ អំពើធ្វើអាជីវកម្មផ្លូវភេទ និងអំពើកេងប្រវ័ញ្ចគ្រប់រូបភាព។

១៨.បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

១៩.ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

២០.បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" និងការរៀបចំយន្តការទទួលពលករ នៅមណ្ឌលទទួលពលករប៉ោយប៉ែត និងត្រៀមរៀបចំបន្តតាមគោលដៅច្រកទ្វារសំខាន់ៗដទៃទៀត (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** )។

២១.បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី និងជំរុញការអនុវត្តគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្តល់សេវាសមស្រប ដល់មន្ត្រីអនុវត្តន៍នៅតាមបណ្តាក្រសួង ស្ថាប័ន រាជធានី-ខេត្ត និងមន្ត្រីស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ និងតាមដានការអនុវត្ត។

២២.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមកក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

២៣.បន្តចូលរួម សិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ ជាមួយបណ្តាប្រទេសពាក់ព័ន្ធ និងជាអន្តរជាតិពាក់ព័ន្ធនឹងវិធានការឆ្លើយតបអំពើជួញដូរមនុស្ស ព្រមទាំងសុវត្ថិភាពមនុស្ស ក្នុងទេសន្តរប្រវេសន៍។

ថ្ងៃ សុក្រ [illegible]........ខែ ផល្គុន.......ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០១.......ខែ មីនា.......ឆ្នាំ២០១៩

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**
- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ**

**"ដើម្បីគោរពជូនជ្រាបជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារ គ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
-លេខាធិការដ្ឋាន គ.រ.ប.ជ/ គ.ខ.ប.ជ

**"ដើម្បីជូនជ្រាប និងផ្សព្វផ្សាយ"**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១

## លទ្ធផលបង្ក្រាបបទល្មើសអាជីវកម្មផ្លូវភេទ និងអំពើជួញដូរមនុស្ស ទូទាំងប្រទេស (ប្រចាំឆ្នាំ២០១៨)
## គិតចាប់ពីថ្ងៃទី ២៦-១២-២០១៧ ដល់ថ្ងៃទី ២៥-១២-២០១៨

| ល.រ | រាជធានី-ខេត្ត | បង្ក្រាបរួម | | | | | | | | ជួញដូរមនុស្ស | | | | | | | | អាជីវកម្មផ្លូវភេទ | | | | | | | | បញ្ជូនជនរងគ្រោះទៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួនករណី | ជនល្មើស | | | ជនរងគ្រោះ | | | | ចំនួនករណី | ជនល្មើស | | | ជនរងគ្រោះ | | | | ចំនួនករណី | ជនល្មើស | | | ជនរងគ្រោះ | | | | មន្ទីរសង្គមកិច្ច | អង្គការ | គ្រួសារ |
| | | | រួម | ស្រី | បរទេស | រួម | -15 | 15-17 | 18+ | | រួម | ស្រី | បរទេស | រួម | -15 | 15-17 | 18+ | | រួម | ស្រី | បរទេស | រួម | -15 | 15-17 | 18+ | | | |
| 1 | បន្ទាយមានជ័យ | 7 | 7 | | | 8 | 6 | | 2 | 2 | 2 | | | 3 | 1 | | 2 | 5 | 5 | | | 5 | 5 | | | | | 8 |
| 2 | បាត់ដំបង | 13 | 13 | 2 | | 12 | 11 | | 1 | 2 | 2 | 2 | | 1 | | | 1 | 11 | 11 | | | 11 | 11 | | | | | 12 |
| 3 | កំពង់ចាម | 6 | 6 | 3 | | 7 | 5 | | 2 | 3 | 3 | 3 | | 4 | 2 | | 2 | 3 | 3 | | | 3 | 3 | | | | | 7 |
| 4 | កំពង់ឆ្នាំង | 5 | 5 | | | 5 | 5 | | | | | | | | | | | 5 | 5 | | | 5 | 5 | | | | | 5 |
| 5 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 6 | កំពង់ធំ | 2 | 2 | 1 | | 2 | | | 2 | 2 | 2 | 1 | | 2 | | | 2 | | | | | | | | | | | 2 |
| 7 | កំពត | 1 | 1 | 1 | | 3 | | | 3 | | | | | | | | | 1 | 1 | 1 | | 3 | | | 3 | | | 3 |
| 8 | កណ្តាល | 12 | 12 | 1 | | 13 | 13 | | | 1 | 1 | 1 | | 1 | 1 | | | 11 | 11 | | | 12 | 12 | | | | | 13 |
| 9 | កោះកុង | | | | | | | | | | | | | | | | | | | | | | | | | | | |
| 10 | ក្រចេះ | 6 | 8 | 4 | | 7 | 1 | 1 | 5 | 5 | 7 | 4 | | 6 | | 1 | 5 | 1 | 1 | | | 1 | 1 | | | | 2 | 5 |
| 11 | មណ្ឌលគិរី | 4 | 4 | | | 4 | 3 | | 1 | 1 | 1 | | | 1 | | | 1 | 3 | 3 | | | 3 | 3 | | | | | 4 |
| 12 | ភ្នំពេញ | 15 | 67 | 52 | 1 | 28 | 11 | | 17 | 3 | 54 | 50 | 1 | 3 | | | 3 | 12 | 13 | 2 | | 25 | 11 | | 14 | 16 | | 12 |
| 13 | ព្រះវិហារ | 3 | 5 | 3 | 1 | 4 | 3 | 1 | | 1 | 2 | 2 | | 2 | 1 | 1 | | 2 | 3 | 1 | 1 | 2 | 2 | | | | | 4 |
| 14 | ព្រៃវែង | 2 | 2 | | | 2 | 2 | | | | | | | | | | | 2 | 2 | | | 2 | 2 | | | | | 2 |
| 15 | ពោធិ៍សាត់ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 16 | រតនគិរី | | | | | | | | | | | | | | | | | | | | | | | | | | | |
| 17 | សៀមរាប | 9 | 20 | 7 | 11 | 20 | 3 | 5 | 12 | 1 | 1 | 1 | | 1 | | | 1 | 8 | 19 | 6 | 11 | 19 | 3 | 5 | 11 | 16 | | 4 |
| 18 | ព្រះសីហនុ | 6 | 7 | | 3 | 14 | 3 | 1 | 10 | 1 | 1 | | | 1 | | 1 | | 5 | 6 | | 3 | 13 | 3 | | 10 | 7 | | 7 |
| 19 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | 2 | 2 | | | 2 | 2 | | | | | | | | | | | 2 | 2 | | | 2 | 2 | | | | | 2 |
| 21 | តាកែវ | 2 | 2 | | | 2 | 2 | | | | | | | | | | | 2 | 2 | | | 2 | 2 | | | | | 2 |
| 22 | ឧត្តរមានជ័យ | 1 | 1 | | | 2 | 1 | 1 | | 1 | 1 | | | 2 | 1 | 1 | | | | | | | | | | | | 2 |
| 23 | កែប | 1 | 1 | | | 1 | 1 | | | | | | | | | | | 1 | 1 | | | 1 | 1 | | | | | 1 |
| 24 | ប៉ៃលិន | | | | | | | | | | | | | | | | | | | | | | | | | | | |
| **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** | ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **សុខ ផល** អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានអញ្ជើញចូលរួមចំនួន**៣៧**លើក៖<br>- កិច្ចប្រជុំ ក្រោមអធិបតីភាព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ ចំនួន១៦លើក៖<br>○ **កិច្ចប្រជុំពិភាក្សា**៖ (១)ពិនិត្យករណីពាក់ព័ន្ធបទល្មើសបរិហារកេរ្តិ៍ និងជេរប្រមាថអង្គព្រះមហាក្សត្រ។ (២)ធ្វើសេចក្តីរាយការណ៍អំពីការងាររបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍។ (៣)ស្តីពីការវិភាគមុខងារ ការកំណត់ក្របខ័ណ្ឌ។ (៤)ការងារវិសោធនកម្មរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌ។ (៥)ចុះហត្ថលេខាលើផែនការសហប្រតិបត្តិការ ឆ្នាំ២០១៨។ (៦)ស្តីពីការធ្វើមាតុភូមនិវត្តន៍ពលរដ្ឋខ្មែរពីសហរដ្ឋអាមេរិក។ (៧)ស្តីពីបញ្ហាពាក់ព័ន្ធសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (NGO)។ (៨)ស្តីពីអន្តោប្រវេសន៍ជនជាតិចិន ដែលកំពុងស្នាក់នៅ និងធ្វើអាជីវកម្មនៅខេត្តព្រះសីហនុ។ (៩)ក្រុមការងារអន្តរក្រសួងចុះសិក្សាស្ថានភាពតាមបណ្តាប៉ុស្តិ៍ច្រកទ្វារព្រំដែន។ (១០)ក្រុមការងារដើម្បីសិក្សាធ្វើវិសោធនកម្មច្បាប់ ស្តីពីសញ្ជាតិ (ចំនួន០២លើក)។ (១១)កំណត់ទិសដៅរួមគ្នាសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុង |

| | |
|---|---|
| | ការងារគ្រប់គ្រងទេសន្តរប្រវេសន៍ និងត្រៀមចូលរួមកិច្ចប្រជុំក្រុមប្រទេសបញ្ចូនទាំងបី (កម្ពុជា ឡាវ មីយ៉ាន់ម៉ា)។ (១២)កិច្ចប្រជុំការងារវិសោធនកម្មច្បាប់ ស្តីពីអន្តោប្រវេសន៍។ (១៣)ស្តាប់សេចក្តីរាយការណ៍ អំពីសកម្មភាពអនុវត្តការដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី និងទទួលពាក្យសុំប្រកាសទទួលស្គាល់ និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍រយៈពេល០៦ខែ។<br>- ក្នុងឱកាស **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** អនុញ្ញាតឲ្យចូលជួបសម្តែងការគួរសម នៅសាលទទួលភ្ញៀវអន្តរជាតិ នៅទីស្តីការក្រសួងមហាផ្ទៃ ចំនួន០៥លើក៖ (១)ឯកឧត្តម **VU QUANG MINH** ឯកអគ្គរដ្ឋទូតវៀតណាម ទើបតែងតាំងថ្មី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ (២)ឯកឧត្តម ឧត្តមសេនីយ៍ឯកបំរុង **ប៊ុយ វ៉ាន់ណាម** អនុរដ្ឋលេខាធិការក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ (៣)ឯកឧត្តម **DMITRI TSVETKOV** ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី។ (៤)ឯកឧត្តម **CHEN SHIGU** អគ្គនាយករងក្រសួងសន្តិសុខសាធារណរដ្ឋចិន និងជាប្រធានក្រុមការងារខេមមីតចិន។ (៥)ឯកឧត្តម **ZHAO KEZHI** សមាជិកក្រុមប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងជំនួបពិភាក្សាផ្លូវការ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន។<br>- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៨ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** របស់អគ្គនាយកដ្ឋាន និងរដ្ឋបាលរាជធានី-ខេត្ត ចំនួន០៩លើក (អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គាធិការដ្ឋានក្រសួងមហាផ្ទៃ គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ និងរដ្ឋបាលរាជធានីភ្នំពេញ កណ្តាល បន្ទាយមានជ័យ បាត់ដំបង)។<br>- កិច្ចប្រជុំពិភាក្សា៖ (១)ក្រុមការងារអន្តរក្រសួង ទទួលបន្ទុករៀបចំតាក់តែងសេចក្តីព្រាងច្បាប់ ស្តីពីអន្តោប្រវេសន៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្រោមអធិបតីភាព ឯកឧត្តម **អ៊ុក គីមលេខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ (ចំនួន០២លើក)។ (២)ដើម្បីត្រៀមរៀបចំសម្របសម្រួលខ្លឹមសារកំណត់ហេតុ នៃកិច្ចប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការឆ្នាំ២០១៨ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្រោមអធិបតីភាព ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។ (៣)ដឹកនាំកិច្ចប្រជុំក្រុមពិភាក្សាការងារជំនាញរវាងភាគីទាំងពីរ កម្ពុជា និងចិន ស្តីពីការគ្រប់គ្រងព្រំដែន ការតាមចាប់ជនសង្ស័យ កិច្ចសហប្រតិបត្តិការ ការពារសុវត្ថិភាពវិធីមួយផ្លូវសូត្រមួយ ការប្រយុទ្ធប្រឆាំងបទល្មើស ការប្រយុទ្ធប្រឆាំងជនបរទេសប្រព្រឹត្តបទល្មើស ការជួញដូរមនុស្ស ការឆបោកតាមទូរគមនាគមន៍ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការជំរុញកិច្ចសហប្រតិបត្តិការលើកិច្ចការនគរបាលនៅតាមមូលដ្ឋាន។<br>- បានទទួលជួបពិភាក្សាការងារចំនួន ០៤លើក ជាមួយ៖ (១)គណៈប្រតិភូនគរបាលជាតិសាធារណរដ្ឋកូរ៉េ ដឹកនាំដោយលោក IM BYUNG HO ប្រធាននាយកដ្ឋានស៊ើបអង្កេតបទល្មើសឧក្រិដ្ឋនៃការិយាល័យកិច្ចការបរទេស នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍។ (២)គណៈប្រតិភូ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងសន្តិសុខសាធារណរដ្ឋចិន ដែលដឹកនាំដោយលោក LIAO JINRONG អគ្គនាយកកិច្ចសហប្រតិបត្តិការអន្តរជាតិចិន នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍។ |

| | |
|---|---|
| | (៣)លោកស្រី DOMICA POTTIE ឯកអគ្គរដ្ឋទូតកាណាដា ប្រចាំនៅទីក្រុងបាងកក និងលោកស្រី ALLISON STWARD ភារធារីស្ថានទូតកាណាដាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។ (៤)លោក រ៉ូប៊ឺត ថមមិន អនុព័ន្ធប្រចាំតំបន់ នៃក្រសួងសន្តិសុខមាតុភូមិ ទទួលបន្ទុកកិច្ចការគេយ និងព្រំដែនសហរដ្ឋអាមេរិក។<br>- ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **សុខ ផល** អគ្គនាយកអន្តោប្រវេសន៍ បានអញ្ជើញចូលរួម៖ (១)កិច្ចប្រជុំពិភាក្សាការអនុវត្តច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដឹកនាំប្រជុំដោយ ឯកឧត្តម **ប៊ុន ហុន** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ។ (២)ជួបពិភាក្សាការងារជាមួយលោកស្រី **សេ ស៊ីលា** តំណាងនគរបាលនៃប្រទេស NORDIC ប្រចាំនៅទីក្រុងបាងកក ប្រទេសថៃ និសហការី។ (៣)ដឹកនាំកិច្ចប្រជុំបូកសរុបការងារឆមាសទី១ និងលើកទិសដៅអនុវត្តការងារបន្តឆមាសទី២ ឆ្នាំ២០១៨។<br>- បានអញ្ជើញចូលរួមក្នុងឱកាស **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** អនុញ្ញាតឲ្យលោកជំទាវ TINA SUSAN RIDSHAW ឯកអគ្គរដ្ឋទូតចក្រភពអង់គ្លេស ទើបតែងតាំងថ្មីប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម។<br>- ជំនួបពិភាក្សាការងារជាមួយលោក JOSEPH GALOSKI តំណាងសេនានុព័ន្ធប្រចាំប្រទេសរបស់សហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា និងសហការី។<br>- ដឹកនាំគណៈប្រតិភូអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងជាប្រធានកុងស៊ុលអាស៊ានលើកទី២២(22nd DGICM) និងកិច្ចប្រជុំពាក់ព័ន្ធ ដែលប្រព្រឹត្តទៅថ្ងៃទី០៦ ដល់១០ ខែសីហា ឆ្នាំ២០១៨។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត សម្របសម្រួលចំនួន២៨៧លើក អ្នកចូលរួមសរុបចំនួន១៧.៣៩៥នាក់ (ស្រី៧.៧៩១នាក់)** | |
| **ខេត្តបន្ទាយមានជ័យ** | - **បានរៀបកិច្ចប្រជុំ៖**(១)ប្រចាំខែ និងប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ខ.ប.ជខេត្ត អ្នកចូលរួមចំនួន៤៨នាក់ ស្រី០៨នាក់។ (២)លើកកម្ពស់ការយល់ដឹង ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព អ្នកចូលរួមចំនួន៣៦នាក់ ស្រី០៥នាក់។ (៣)រវាងអង្គការដៃគូ 3PC និងអង្គការគ្រួសារថ្មី ស្តីពីការសហការគ្នា នៅកន្លែងការធ្វើចំណាកស្រុករបស់ពលករ អ្នកចូលរួមចំនួន០៦នាក់ ស្រី០២នាក់។ (៤) ប្រចាំខែ រវាងបុគ្គលិកមណ្ឌលស្នាក់នៅបណ្តោះអាសន្នចំនួន ០១នាក់ និង CS DIC ចំនួន០២នាក់ ជាមួយអង្គការសាម៉ារីតាន់ភឺស និងអង្គការគ្រួសារថ្មី ស្តីពីការសហការគ្នាទទួលពលករទេសន្តរប្រវេសន៍ និងស្តីពីការងារការធ្វើចំណាកស្រុក។ (៥)ស្តីពីការពង្រឹងកិច្ចសហការរវាងអាជ្ញាធរពាក់ព័ន្ធ និងអង្គការដៃគូ ក្នុងការទទួលពលករដែលថៃចាប់បញ្ជូនមកវិញ នៅអគារមជ្ឈមណ្ឌលប៉ោយប៉ែត។ (៦)ស្តីពីការពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងនីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់ការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ (៧)ស្តីពីការប្រគល់សំណង់អាគារមជ្ឈមណ្ឌលសំចតប៉ោយប៉ែត។ (៨)ស្តីពីរបៀបរបបការងារទទួលពលករនៅមជ្ឈមណ្ឌលសំចតប៉ោយប៉ែតថ្មី។<br>- **បានចូលរួម៖** (១)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់ គ.ជ.ប.ជ។ (២)វគ្គបណ្តុះបណ្តាលស្តីពីការកសាងចងក្រង និងវិភាគស្ថិតិព័ត៌មានទីផ្សារការងារ អ្នកចូលរួមចំនួន ៩៣នាក់ ស្រី១៨នាក់ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ (៣)សិក្ខាសាលាស្តីពី ពិគ្រោះយោបល់លើសេចក្តីព្រាងនៃការ សិក្សាស្រាវជ្រាវស្តីពី ការថែទាំជំនួសចំពោះកុមារជាលក្ខណៈគ្រួសារនៅកម្ពុជា។ (៤)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |

| | |
|---|---|
| **ខេត្តប៉ៃលិន** | - **បានចូលរួម៖** (១)ពិគ្រោះយោបល់ប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីក្រុមប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីបញ្ហារួមគ្នា និងដំណោះស្រាយ នៅទីស្តីការក្រសួងមហាផ្ទៃ។ (២)ស្តីពីការព្រាងរបាយការណ៍ប្រចាំត្រីមាសទី១ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត។ (៣)ស្តីពីការផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។ (៤)សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិលើសេចក្តីព្រាងរបាយការណ៍ជាតិគួបផ្សំលើកទី៤ ទី៥ ទី៦ សម្រាប់ផ្ញើជូនគណៈកម្មាធិការសិទ្ធកុមារ នៃអង្គការសហប្រជាជាតិ។ (៦)កិច្ចប្រជុំពិនិត្យពិភាក្សាសេចក្តីព្រាង ការកែសម្រួលសមាសភាព និងរបាយការណ៍ឆមាសទី១ ២០១៨ របស់ គ.ខ.ប.ជ ខេត្ត អ្នកចូលរួមចំនួន៣២នាក់ ស្រី០៥នាក់។ (៦)បានរៀបចំកិច្ចប្រជុំប្រចាំខែ និងផ្សព្វផ្សាយអំពីការជួញដូរមនុស្សអំពើហិង្សាក្នុងគ្រួសារ និងការធ្វើចំណាកស្រុកដោយខុសច្បាប់។ (៧)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តបាត់ដំបង** | - **បានចូលរួម៖** (១)ពិគ្រោះយោបល់ប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីក្រុមប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីបញ្ហារួមគ្នា និងដំណោះស្រាយ នៅទីស្តីការក្រសួងមហាផ្ទៃ។ (២)សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ លើសេចក្តីព្រាងរបាយការណ៍ជាតិ ខួបលើកទី៥ និងទី៦ សម្រាប់ជូនគណៈកម្មាធិការសិទ្ធិកុមាររបស់ អង្គការសហប្រជាជាតិ នៅសណ្ឋាគារខេមរា ខេត្តបាត់ដំបង អ្នកចូលរួមចំនួន៧០នាក់។ (៣)ប្រជុំជាមួយអង្គការអន្តរជាតិខាងការងារ ILO ក្នុងគម្រោងត្រីកោណ ស្តីពីការរៀបចំបច្ចេកទេសការងារ នៅភ្នំពេញសេនជីវ អ្នកចូលរួមមកពីបណ្តាខេត្តដូចជាខេត្តបាត់ដំបង កំពង់ធំ និងខេត្តកំពង់ចាម សរុបចំនួន១៦នាក់ ស្រី០៦នាក់។ (៤)សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ ទិសដៅឆ្នាំ២០១៨ នៃការអនុវត្តផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ ឆ្នាំ២០១៤-២០១៨ អ្នកចូលរួមចំនួន៤៧០នាក់ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ (៥)ជាវាគ្មិនធ្វើបទបង្ហាញអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព អ្នកចូលរួមចំនួន១២៧នាក់ ស្រី៧៦នាក់។ (៦)ទិវាជាតិសុខភាពមាត់ធ្មេញ ពិនិត្យ ព្យាបាលឥតគិតថ្លៃដោយទន្តពេទ្យកម្ពុជា និងកម្មវិធីពិនិត្យជម្ងឺនិងផ្តល់វ៉ែនតាដោយឥតគិតថ្លៃ ដោយគ្រូពេទ្យស្ម័គ្រចិត្តមកពីអាមេរិក និងបានផ្សព្វផ្សាយអំពីការជួញដូរមនុស្ស និងការចំណាកស្រុកដោយសុវត្ថិភាព ចំនួន១.៦៥២នាក់។ (៧)ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ផ្លូវការអាគារមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន និងបានផ្សព្វផ្សាយអំពីការជួញដូរមនុស្ស និងការចំណាកស្រុកដោយសុវត្ថិភាព អ្នកចូលរួមចំនួន៤៥០នាក់។ (៨)វគ្គបណ្តុះបណ្តាលស្តីពីទេសន្តរប្រវេសន៍ និងសមភាពយេនឌ័រដល់អាជ្ញាធរក្រុង ស្រុក ប្រព័ន្ធផ្សព្វផ្សាយ និងអង្គការដៃគូ អ្នកចូលរួមចំនួន៤១នាក់ ស្រី២៧នាក់។ (៩)រៀបចំវគ្គពិភាក្សាផ្សព្វផ្សាយ និងពិគ្រោះយោបល់ស្តីពីការចំណាកស្រុកដោយសុវត្ថិភាពចំនួន០២លើក អ្នកចូលរួមចំនួន១២៧នាក់ ស្រី៦៥នាក់។ (១០)សហការជាមួយអង្គការការីតាសកម្ពុជា រៀបចំវគ្គបណ្តុះបណ្តាលជនបង្គោលនិងអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព អ្នកចូលរួមចំនួន១៨៤នាក់ ស្រី៦១នាក់។ (១១)ជាវាគ្មិនក្នុងកម្មវិធីលើកកម្ពស់សិទ្ធិមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពដែលរៀបចំដោយអង្គការប្រតិបត្តិការកុមារកម្ពុជា(OEC) អ្នកចូលរួមចំនួន២១នាក់ ស្រី១៦នាក់។ (១២) ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តតាកែវ** | - **បានចូលរួម៖**(១)កិច្ចប្រជុំផ្សព្វផ្សាយពង្រឹងការងារជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមបណ្តាស្រុក អ្នកចូលរួមចំនួន២.១៩៧នាក់ ស្រី ១.០០០នាក់។(២)ស្តីពីការផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។ (៣)ជាមួយក្រុមការងារថ្នាក់ក្រុង ស្រុកទាំង១០ អំពីយន្តការពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុក និងការរំលោភសេពសន្ថវៈ ចំនួន១៣លើក មនុស្សចូលរួម ២.៩៣៧នាក់ ស្រី ១.៨០១នាក់។ ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |

| | |
|---|---|
| **ខេត្តសៀមរាប** | - (១)កិច្ចប្រជុំពិភាក្សាប្រចាំខែ ត្រីមាសទី១ និងឆមាសទី១ ឆ្នាំ២០១៨ ស្តីពីការបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ អ្នកចូលរួមចំនួន៤៤៤នាក់ ស្រី២០៥នាក់។ (២)កិច្ចប្រជុំពិភាក្សា ស្តីពីការបូកសរុបឆ្លុះបញ្ចាំងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ អ្នកចូលរួមចំនួន២៣៦នាក់ ស្រី៩២នាក់។ (៣)ស្តីពីការផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។ (៤)កិច្ចប្រជុំសម្របសម្រួលការងារគ្រប់គ្រងករណី និងសមាហរណកម្មកុមារក្នុងគ្រួសារប្រចាំត្រីមាសទី២ ឆ្នាំ២០១៨។ (៥)កិច្ចប្រជុំស្តីពីដំណើរការគ្រប់គ្រងករណីរួមគ្នារវាងប្រទេសកម្ពុជា និងថៃ។ (៦)កិច្ចពិភាក្សាពិគ្រោះយោបល់កម្រិតបច្ចេកទេសនៃប្រទេសបញ្ជូនមាន(កម្ពុជា-ឡាវ និងមីយ៉ាន់ម៉ា) នៅសណ្ឋាគារសុខាល័យអង្គរ។ (៧)កិច្ចប្រជុំផ្សព្វផ្សាយ ប្រកាសអន្តរក្រសួងលេខ៧១៩ ប្រក ស្តីពីការពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា។ (៨)ពិធីបិទវគ្គបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន តំណាងក្រុមយុវជន និងក្រុមការងារការពារកុមារ។ (៩) កិច្ចប្រជុំតុមូលស្តីពីការការពារសុវត្ថិភាពកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណេត អ្នកចូលរួមចំនួន៧៤នាក់ ស្រី៣១នាក់។ (១០)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តឧត្តរមានជ័យ** | - **បានចូលរួម៖**(១) កិច្ចប្រជុំ គ ក ស ក អ្នកចូលរួមចំនួន២៥នាក់ ស្រី១១នាក់ នៅសាលាខេត្ត។ (២)វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ អ្នកចូលរួមចំនួន៥០នាក់ ស្រី៤៦នាក់។ (៣)ស្តីពីការផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។ (៤)រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ រយៈពេល៨ខែ ឆ្នាំ២០១៨ របស់គណៈកម្មធិការ គ.ខ.ប.ជខេត្ត អ្នកចូលរួមចំនួន៧៦នាក់ ស្រី២៣នាក់។ (៥)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តព្រះវិហារ** | - (១)កិច្ចប្រជុំអំពីការពិភាក្សា ជាមួយក្រុមការងារទាំង០៦ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ជំរុញឲ្យក្រុមការងារទាំង០៦ ធ្វើផែនការតាមជំនាញរៀងខ្លួន ក្នុងឆ្នាំ២០១៨ ដើម្បីអនុវត្តន៍សកម្មភាព ធ្វើការងារផ្សព្វផ្សាយដល់ប្រជាពលរដ្ឋបន្ត ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងជោគជ័យ អ្នកចូលរួមចំនួន២២នាក់ ស្រី១១នាក់។ (២)ស្តីពីការផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។ (៣)លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាសទី១ និងប្រចាំឆ្នាំ២០១៨ ដើម្បីពង្រឹង និងជំរុញឲ្យក្រុមការងារទាំង០៦ យកចិត្តទុកដាក់ ដើម្បីអនុវត្តបន្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ មានអ្នកចូលរួមចំនួន ៦៩នាក់ ស្រី ២២នាក់។ (៤)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តកំពង់ធំ** | - **បានចូលរួមកិច្ចប្រជុំ៖** (១)ពិគ្រោះយោបល់ប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីក្រុមប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីបញ្ហារួមគ្នា និងដំណោះស្រាយ នៅទីស្តីការក្រសួងមហាផ្ទៃ (២)សិក្ខាសាលា ស្តីពីការត្រួតពិនិត្យ តាមដានការអនុវត្តក្រុមប្រតិបត្តិយេនឌ័រ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។ (៣)បូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារក្នុងឆ្នាំ២០១៨ របស់ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី។ (៤)វគ្គបណ្តុះបណ្តាល និងការផ្សព្វផ្សាយ ស្តីពីការបញ្ជ្រាបយេនឌ័រអនុសញ្ញា ការលុបបំបាត់រាល់ទម្រង់ |

| | |
|---|---|
| | នៃការរើសអើងប្រឆាំងនារីភេទ(ស៊ី-ដ) ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្នុងវិស័យទេសចរណ៍ នៅសាលប្រជុំផ្ទះសំណាក់ពន្លឺថ្មី។ (៥) ជាអធិបតី ក្នុងវគ្គបណ្តុះបណ្តាល និងការផ្សព្វផ្សាយយល់ដឹង ស្តីពីយន្តការ និងផែនការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់០៨ក្រុង-ស្រុក ទូទាំងខេត្ត។ (៦)បានសម្ភាសន៍ជាមួយគម្រោងអូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (AAPTI P) ដើម្បីស្វែងយល់ពីភាពរីកចម្រើន និងបញ្ហាប្រឈមនានា នៃការអនុវត្តសកម្មភាព យេនឌ័រ និងក្រុមប្រតិបត្តិយេនឌ័រ ដែលបានអនុវត្តកន្លងមកនៅការិយាល័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត។ (៧)ស្តីពីការផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។ (៨)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។<br>- **បានរៀបចំកិច្ចប្រជុំ៖** (១)ប្រចាំត្រីមាសទី១ ស្តីពីការផ្សព្វផ្សាយការងារទេសន្តរប្រវេសន៍។ (២)ប្រចាំឆមាសទី១ ត្រីមាសទី៣ ប្រចាំខែធ្នូ ឆ្នាំ២០១៨ ដើម្បីពិភាក្សាអំពីសកម្មភាពដែលបានអនុវត្តកន្លងមក និងបញ្ហាប្រឈមនានា មានអ្នកចូលរួមចំនួន ២៥នាក់ ស្រី១១នាក់។ (៣)ប្រកាសសមាសភាពគណៈកម្មាធិការ និងលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត នៅសាលប្រជុំ សាលាខេត្តកំពង់ធំ។ (៤)ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីពិភាក្សារកបញ្ហាប្រឈម និងដំណោះស្រាយរួមគ្នា។ |
| **ខេត្តកណ្តាល** | - **បានរៀបចំកិច្ចប្រជុំ៖** (១) ថ្នាក់ស្រុកប្រចាំខែ ពង្រឹងសមត្ថភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន៦៣លើក អ្នកចូលរួមចំនួន១.៣១៩នាក់ ស្រី៩០៥នាក់។ (២)របស់លេខាធិការដ្ឋាន គ.ខ.ប.ជ ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ២០១៨ ចំនួន០៧លើក អ្នកចូលរួមចំនួន៤១៧នាក់ ស្រី២២៥នាក់។ (៣) ស្តីពីការលុបបំបាត់ប៉ុស្តិ៍ត្រួតពិនិត្យនៅ ក្នុងផ្ទៃប្រទេស និងការអនុវត្តច្បាប់ផ្សព្វផ្សាយត្រួតពិនិត្យចរាចរណ៍ឆ្លងដែន ដើម្បីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរត់ពន្ធមនុស្សឆ្លងដែន។ (៤)ប្រជុំពិនិត្យបូកសរុបរបាយការណ៍១០ខែ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៥)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តកំពង់ឆ្នាំង** | - **បានរៀបចំកិច្ចប្រជុំចំនួន១៨លើក** អ្នកចូលរួមចំនួន**៥១៣**នាក់ ស្រី**២៥៧**នាក់៖ (១)ស្តីពីការពង្រឹងសមត្ថភាព និងការវាយតម្លៃ លទ្ធផលការងាររបស់សមាជិក គ.ខ.ប.ជខេត្ត អ្នកចូលរួមចំនួន១១នាក់ ស្រី០៥នាក់។ (២)ស្តីពីការរំលឹករបាយការណ៍របស់ក្រុមការងារលេខាធិការដ្ឋាន និងក្រុមទាំង៦ដែលពាក់ព័ន្ធលេខាធិការដ្ឋានគ.ខ.ប.ជ ដល់បណ្តាក្រុង/ស្រុកទាំង៨ទូទាំងខេត្ត ចំនួន០៣លើក អ្នកចូលរួមចំនួន៥៨នាក់ ស្រី៣៧នាក់។ (៣)ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដល់ គ.ក.ន.ក យុវជននិងក្រុមគ្រួសារ ឪពុកម្តាយ ចំនួន១២លើក អ្នកចូលរួមចំនួន៤៧៩នាក់ ស្រី២៤២នាក់។ **និងចូលរួមកិច្ចប្រជុំ៖** (៤)ប្រជុំពិនិត្យបូកសរុបរបាយការណ៍១០ខែ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។(៥)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៦)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តពោធិ៍សាត់** | - **បានទៅចូលរួម៖** (១)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (២)ប្រជុំពិនិត្យបូកសរុបរបាយការណ៍១០ខែ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៣)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ (៤)ទៅចូលរួមវគ្គហ្វឹកហ្វឺនជំនាញស៊ើបអង្កេត បទល្មើសជួញដូរមនុស្ស នៅរាជធានីភ្នំពេញ។ |

| | |
|---|---|
| **ខេត្តកំពង់ស្ពឺ** | - **បានរៀបចំកិច្ចប្រជុំ៖** (១)បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ អ្នកចូលរួមចំនួន១៩៣នាក់ ស្រី៩៨នាក់។ (២)ការងារអន្តរមន្ទីរ ស្ថាប័ន អ្នកចូលរួមចំនួន៤៣នាក់ ស្រី១៩នាក់។ **និងចូលរួមកិច្ចប្រជុំ៖** (៣)ប្រជុំពិនិត្យបូកសរុបរបាយការណ៍១០ខែ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៤)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៥)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តរតនគិរី** | - **បានចូលរួម៖** (១)ជាគណអធិបតី ក្នុងវគ្គសិក្ខាសាលាចំនួន០២លើក ស្តីពីផែនការសកម្មភាព ការបង្ការ ទប់ស្កាត់អាពាហ៍ ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះក្នុងវ័យជំទង់ និងស្តីពីការអភិវឌ្ឍន៍កុមារតូច និងការអប់រំក្រុមឪពុក ម្តាយ។ (២)វគ្គបណ្តុះបណ្តាល ស្តីពីការថែទាំមនុស្សចាស់ ការការពារកុមាររងគ្រោះ និងងាយរងគ្រោះ ដែលអ្នកចូលរួមចំនួន១២៥នាក់។(៣)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៤) ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តស្ទឹងត្រែង** | - **បានចូលរួម៖** (១)វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីសកម្មភាពថ្នាក់ភូមិ ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា នៅខេត្តរតនគិរី។ (២)វគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(ស៊ី-ដ)នៅខេត្តក្រចេះ។ (៣)ប្រជុំពិនិត្យបូកសរុបរបាយការណ៍១០ខែ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៤)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៥)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តក្រចេះ** | - **បានរៀបចំកិច្ចប្រជុំ៖** (១)ស្តីពីការពង្រឹងតួនាទី ភារកិច្ច និងត្រៀមធ្វើរបាយការណ៍ប្រចាំខែ ៩ខែ និងរបាយការណ៍១០ខែ ឆ្នាំ២០១៨ ជូនគ.ជ.ប.ជ អ្នកចូលរួម ៦៨នាក់ ស្រី៤៥នាក់។ (២)ស្តីពីការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែចំនួន០៥លើក អ្នកចូលរួមចំនួន៣៥នាក់ ស្រី១៥នាក់។ (៣)ស្តីពីការពង្រឹងការអនុវត្តតួនាទី ភារកិច្ចដល់ក្រុមការងារទាំង៦ របស់ គ.ខ.ប.ជ និងរៀបចំធ្វើផែនការសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០៥លើក អ្នកចូលរួមចំនួន៣២៥នាក់ ស្រី២៩៤នាក់។ **និងបានចូលរួមកិច្ចប្រជុំ៖** (៤)ជាមួយគណៈកម្មការចម្រុះស្តីពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ មនុស្សចូលរួម ១៤នាក់ ស្រី១០នាក់។ (៥)វគ្គបណ្តុះបណ្តាលស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងផែនការនិងស្ថិតិ និងការផ្សព្វផ្សាយអនុសញ្ញាស៊ី-ដ ដែលអ្នកចូលរួម ៧៥នាក់ ស្រី៦៥នាក់។ (៦)ប្រជុំពិនិត្យបូកសរុបរបាយការណ៍១០ខែ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៧)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៨)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តកំពង់ចាម** | - **បានចូលរួមកិច្ចប្រជុំ៖** (១)ប្រចាំខែ ឆ្នាំ២០១៨ ចំនួន០២លើក អ្នកចូលរួមចំនួន៣៨នាក់ ស្រី១០នាក់។ (២)ស្តីពីនីតិវិធីទៅធ្វើការស្របច្បាប់នៅក្រៅប្រទេស នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។ (៣)ប្រជុំពិនិត្យបូកសរុបរបាយការណ៍១០ខែ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៤)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៥)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ និង(៦)បានចូលរួមសិក្ខាសាលា ស្តីពីការបើកប្រាក់ឈ្នួល២ដង ក្នុងមួយខែ សម្រាប់កម្មករ និយោជិក និងការទូទាត់ប្រាក់អតីតភាពការងារ សម្រាប់អ្នកធ្វើការក្នុងប្រទេស អ្នកចូលរួមមកពីរាជធានី ខេត្តចំនួន ០៩ខេត្ត។ |

| | |
|---|---|
| **ខេត្តត្បូងឃ្មុំ** | - **បានចូលរួមកិច្ចប្រជុំ៖** (១)ប្រជុំពិនិត្យបូកសរុបរបាយការណ៍១០ខែ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (២)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៣)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ និង(៤) សហការជាមួយអង្គការស៊ីកាស្វា និងអង្គការភ្លែនអន្តរជាតិ បានរៀបចំសិក្ខាសាលាស្តីពីការអនុវត្តល្អ និងការពង្រឹងនីតិវិធីនគរបាលយុត្តិធម៌ បែបកុមារមេត្រី និងសេវាសង្គម ព្រមទាំងពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ អ្នកចូលរួមចំនួន៧៩នាក់ ស្រី៣៣នាក់។ |
| **ខេត្តកោះកុង** | - **បានរៀបចំកិច្ចប្រជុំ៖** (១)ផ្សព្វផ្សាយសេចក្តីសម្រេចលេខ០២១/១៨ របស់ គ.ខ.ប.ជខេត្ត។ (២)ផ្សព្វផ្សាយសេចក្តីសម្រេចលេខ០២២/១៨ របស់រដ្ឋបាលខេត្ត ស្តីពីការបង្កើតក្រុមការការជំនាញ អង្គភាព អន្តរមន្ទីរ សម្រាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ **និងចូលរួមកិច្ចប្រជុំ៖**(៣)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៤)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តព្រះសីហនុ** | - **បានរៀបចំកិច្ចប្រជុំ៖** (១)ប្រចាំខែ ស្តីពីការពង្រឹងសមត្ថភាព និងជំរុញដល់មន្ទីរ អង្គភាពជុំវិញខេត្ត និងតាមក្រុង/ស្រុក ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឲ្យអនុវត្តន៍ទៅតាមតួនាទី និងភារកិច្ច សហការគ្នាផ្តល់របាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ មកលេខាធិការដ្ឋានជាប្រចាំ។ **និងចូលរួម៖**(២)ប្រជុំពិនិត្យបូកសរុបរបាយការណ៍១០ខែ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៣)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៤)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តកំពត** | - **បានរៀបចំកិច្ចប្រជុំ៖** (១)ស្តីពី គោលការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧ អ្នកចូលរួមចំនួន ៣៥នាក់ ស្រី០៤នាក់។ (២)ដើម្បីត្រួតពិនិត្យសកម្មភាព ជំរុញការផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(ចំនួន០៣លើក)។ ចូលរួមកិច្ចប្រជុំ៖(៣)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៤)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ និងទទួលជួបជាមួយ(៥)លោកស្រី Dr. Anna Miki តំណាងអង្គការ Caram International ដើម្បីវាយតម្លៃដោយឯករាជ្យនូវកម្មវិធីការពារកុមារ។ (៦)ប្រធានក្រុមការងារពង្រឹងយុត្តិធម៌ និងបណ្តុះបណ្តាល អង្គការអេស្ប៉ាញ អង្គការ Aple ពាក់ព័ន្ធការបំពារបំពានផ្លូវភេទលើកុមារ និងស្នើសុំសហការទប់ស្កាត់ជនជាតិអាល្លឺម៉ង់ម្នាក់ធ្លាប់ប្រព្រឹត្តល្មើសនៅប្រទេសរបស់គាត់ ប៉ុន្តែបច្ចុប្បន្នកំពុងស្នាក់នៅខេត្តកំពត។ |
| **ខេត្តកែប** | - **បានរៀបចំកិច្ចប្រជុំ៖** (១) ដើម្បីឆ្លងសេចក្តីព្រាងរបាយការណ៍ និងត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ចំនួន០២លើក)។ **និងចូលរួម៖**(២)ប្រជុំពិនិត្យបូកសរុបរបាយការណ៍១០ខែ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៣)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៤)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តព្រៃវែង** | - **បានចូលរួម៖** (១)កិច្ចប្រជុំពិគ្រោះយោបល់ប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីក្រុមប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីបញ្ហារួមគ្នា និងដំណោះស្រាយ នៅទីស្តីការក្រសួងមហាផ្ទៃ។ (២)កិច្ចប្រជុំប្រចាំត្រីមាសរបស់ស្ត្រី នៅសាលាខេត្តព្រៃវែង រៀបចំដោយអង្គការ យេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)។ (៣)ជាគណៈអធិបតីក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងរាល់ទម្រង់នៃការកេងប្រវ័ញ្ច នៅសាលាស្រុកពាធីរៀង រៀបចំ |

| | |
|---|---|
| | ដោយអង្គការសម្ព័ន្ធចាប់ដៃ។ (៤)ជាអធិបតីប្រជុំត្រីមាសទី១ ត្រីមាសទី២ ត្រីមាសទី៣ និងឆមាសទី១ ឆ្នាំ២០១៨ នៅសាលាខេត្តព្រៃវែង។ (៥)ធ្វើជាអធិបតីប្រជុំត្រីមាសរបស់ស្ត្រីដឹកនាំនៅថ្នាក់ក្រោមជាតិ នៅសាលាខេត្តព្រៃវែង។ (៦)ជាអធិបតីក្នុងវគ្គបណ្តុះបណ្តាលច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងយន្តការដោះស្រាយវិវាទពលករទេសន្តរប្រវេសន៍។ (៧)ជាវាគ្មិនវេទិកាចំណាកស្រុកដោយសុវត្ថិភាព និងការងារ អ្នកចូលរួមចំនួន១.០៣០នាក់ ស្រី ៧៧២នាក់។ (៨)ប្រជុំពិនិត្យបូកសរុបរបាយការណ៍១០ខែ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៩)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (១០)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តស្វាយរៀង** | - (១)**បានរៀបចំកិច្ចប្រជុំ** ដើម្បីផ្សព្វផ្សាយអប់រំអំពីច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ចំនួន ១២លើក អ្នកចូលរួមចំនួន ២៨នាក់ ស្រី២៤នាក់។ **និងចូលរួម៖** (២)ប្រជុំពិនិត្យបូកសរុបរបាយការណ៍១០ខែ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៣)ប្រជុំផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៤)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |
| **ខេត្តមណ្ឌលគិរី** | - **បានចូលរួម៖**(១)សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការតាមដានត្រួតពិនិត្យ ការអនុវត្តក្រុមប្រតិបត្តិការងារយេនឌ័រក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅរាជធានីភ្នំពេញ។ (២)ប្រជុំពិនិត្យបូកសរុបរបាយការណ៍១០ខែ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៣)ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ (៤)ទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |

# ឧបសម្ព័ន្ធ៣

## ក. ការបង្ការ ទប់ស្កាត់

### ក.១. ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

**តារាងការងារផ្សព្វផ្សាយសកម្មភាពរបស់អង្គការដៃគូនានា**

| ឈ្មោះអង្គការ | សកម្មភាព |
|---|---|
| IOM | - (១)ផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាជន យុវជន និងអាជ្ញាធរមូលដ្ឋាន (ស្រុកព្រះនេត្រព្រះ)ខេត្តបន្ទាយមានជ័យ (ស្រុកក្រឡាញ់) ខេត្តសៀមរាប, (ស្រុកភ្នំព្រឹក) ខេត្តបាត់ដំបង និងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ អ្នកចូលរួមចំនួន ១.០០៩នាក់ (ស្រី **៧៣៩**នាក់) សហការជាមួយអង្គការទស្សនពិភពលោក។ (២)ផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ពលករខ្មែរដែលវិលត្រឡប់មកវិញ ក្រោយពីនិរទេសពីប្រទេសថៃ មានចំនួនប្រមាណពី ៣០នាក់ ទៅ ១០០នាក់ ក្នុង១ថ្ងៃ តាមច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ |
| សម្ព័ន្ធចាប់ដៃ | - បានសហការជាមួយមន្ត្រីសាលាស្រុក ការិយាល័យមន្ទីរសង្គមកិច្ចស្រុក អធិការដ្ឋាននគរបាលស្រុក និងអាជ្ញាធរមូលដ្ឋានស្រុក ដើម្បីចែកចាយនូវព័ត៌មានថ្មីៗ និងពិភាក្សាផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ក្នុងការផ្សព្វផ្សាយឲ្យមានប្រសិទ្ធភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ ការទប់ស្កាត់កុមារធ្វើចំណាកស្រុកខុសច្បាប់ និងអំពើហិង្សាក្នុងគ្រួសារ ដល់ប្រជាពលរដ្ឋតាមសហគមន៍ដែលរស់នៅក្នុងឃុំទាំង៣ របស់ស្រុកចំការលើ ខេត្តកំពង់ចាម និងស្រុកបាភ្នំ ខេត្តព្រៃវែង ចំនួន ១០រូប ដែលមានការចូលរួមពី អភិបាលរងស្រុក ០១រូប អធិការស្រុក ០១រូប ប្រធានការិយាល័យសង្គមកិច្ច ០១រូប ប្រធានការិយាល័យកិច្ចការនារី ០១រូប គ្រូគង្វាល ០១រូប អាជ្ញាធរមូលដ្ឋាន ០៥រូប និងកិច្ចការនារីឃុំ ០៤រូប ដល់ប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន **៣៩១**នាក់ (ស្រី៥១នាក់)។ |

### ក.២. ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

- **អង្គការសម្ព័ន្ធចាប់ដៃ** ក្នុងឆមាសទី១ ឆ្នាំ២០១៨នេះ បានសហការជាមួយវិទ្យុជាតិភ្នំប្រុសភ្នំស្រី អេហ្វអឹម៩២.៥០ មេហ្គាហឺត ដើម្បីចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធ នឹងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព៖
  - ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១៨ ចាក់ផ្សាយជាប្រចាំ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងសិទ្ធិកុមារ ដល់ប្រជាពលរដ្ឋ នៅតាមសហគមន៍។
  - ដើម្បីបង្កើតកម្មវិធីផ្សាយផ្ទាល់ដោយមានការចូលរួមពី៖ (១)មន្ត្រីនគរបាល ០១រូប មកពីការិយាល័យប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាល ខេត្តកំពង់ចាម ដើម្បីចូលរួមបកស្រាយលើប្រធានបទច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ (២)លោកស្រី **ឡៅ សុជាតិ** មកពីការិយាល័យអធិការកិច្ច និងវិវាទការងារ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម បានចូលរួមជាវាគ្មិនកិត្តិយស លើប្រធានបទ ស្តីពីការធ្វើចំណាកស្រុកស្របច្បាប់។ (៣)ការចាក់ផ្សាយបានចំនួន ០៦លើក លើប្រធានបទ សិទ្ធិកុមារ និងតួនាទីឪពុក ម្តាយល្អ ដែល

មានការចូលរួមដោយបុគ្គលិកគម្រោង ធ្វើជាវាគ្មិនផ្ទាល់។ ហើយការចាក់ផ្សាយនេះមានការចូលរួមពីប្រិយមិត្តតាមរយៈទូរស័ព្ទចំនួន ២៩រូប ដើម្បីសួរសំណួរ និងបញ្ចេញមតិយោបល់បន្ថែមលើប្រធានបទផងដែរ។

- **អង្គការ IOM** បានសហការជាមួយមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា និងវិទ្យុវាយោ VAYO ដើម្បីចូលរួមផ្សព្វផ្សាយ ច្បាប់ពាក់ព័ន្ធ នឹងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព៖
  - **តាមប៉ុស្តិ៍វិទ្យុ៖** ស្តីពី **"ចំណាកស្រុកជោគជ័យ"** ដល់ក្រុមគោលដៅគឺស្ត្រីកម្ពុជា ដែលមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៤៥ឆ្នាំ បានចំនួន ១៤លើក។
  - **តាមវីដេអូ៖** (១)បង្កើតខ្សែវីដេអូស្តីពីការរៀបអាពាហ៍ពិពាហ៍ទៅប្រទេសចិន មានចំណងជើងថា **"ចំណាកស្រុកជោគជ័យ"** ផលិតដោយមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា សម្របសម្រួលដោយអង្គការ IOM និងផ្តល់មូលនិធិដោយអង្គការ IOM-X ដល់ក្រុមគោលដៅគឺស្ត្រីកម្ពុជា ដែលមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៤៥ឆ្នាំ នៅស្រុកចំការលើ ខេត្តកំពង់ចាម។ (២)ការសម្របសម្រួលដោយមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា និងអង្គការ IOM និងផ្តល់មូលនិធិ ដោយអង្គការ IOM-X ៖ (១)ការចាក់បញ្ចាំងខ្សែវីដេអូ **"ចំណាកស្រុកជោគជ័យ"** នៅតាមទូរទស្សន៍ PNN និងទូរទស្សន៍ My TV ដល់ក្រុមគោលដៅ គឺស្ត្រីកម្ពុជា ដែលមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៤៥ឆ្នាំ ចំនួន០៥លើក។ (២)ចាក់បញ្ចាំងខ្សែវីដេអូនៅសហគមន៍ ស្តីពីការរៀបអាពាហ៍ពិពាហ៍ទៅប្រទេសចិន មានចំណងជើងថា **"ចំណាកស្រុកជោគជ័យ"** ដល់ក្រុមគោលដៅគឺស្ត្រីកម្ពុជា ដែលមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៤៥ឆ្នាំ នៅភូមិតាអុង ឃុំតាអុង ស្រុកចំការលើ ខេត្តកំពង់ចាម។
  - **ផ្តល់ព័ត៌មានដល់ពលករតាមរយៈទូរស័ព្ទ/អ្នកមកជួបផ្ទាល់៖** (១)ព័ត៌មានទាក់ទងនឹងការចំណាកស្រុកដោយសុវត្ថិភាពចំនួន ១៤២នាក់ (ស្ត្រី ៥៨នាក់)។ (២)ព័ត៌មានទាក់ទងនឹងឱកាសការងារនៅក្នុងប្រទេសចំនួន ៣២ នាក់ (ស្ត្រី ៨នាក់)។ (៣)ព័ត៌មានផ្សេងៗទៀតចំនួន ២១នាក់ (ស្ត្រី ៩នាក់)។
- **អង្គការ Friend International** គម្រោងកល្យាណមិត្ត បានធ្វើការចែកខិត្តប័ណ្ណ និងសម្ភារ ផ្សព្វផ្សាយដែលមានខ្លឹមសារទាក់ទងនឹងកិច្ចការការពារកុមារ មានដូចជា៖ គន្លឹះទាំង៧សម្រាប់ជួយដល់កុមារ ចំនួន ៤៦៦សន្លឹក គន្លឹះទាំង៧សម្រាប់ជនបរទេសចំនួន ៩១៤សន្លឹក កាតទូរស័ព្ទបន្ទាន់ចំនួន ៨៨៤សន្លឹក ស្លាកទូរស័ព្ទបន្ទាន់ចំនួន ១២រ៉ឺម៉កម៉ូតូកង់បី លេខទូរស័ព្ទបន្ទាន់នៅលើផូស្ទ័រចំនួន ៤០ផូស្ទ័រ រក្សាកុមារនៅក្នុងគ្រួសារ/សហគមន៍ (មណ្ឌលកុមារកំព្រាធ្វើឲ្យកុមារបែកចេញពីគ្រួសារ) ចំនួន ៨៥ផូស្ទ័រ ភ្នាក់ងារសុវត្ថិភាពកុមារចំនួន ៦៣អាវនិង១០៦ស្ទីកគ័រ កុមារមិនមែនជាឧបករណ៍សម្រាប់ទាក់ទាញកុមារទេ ចំនួន ៨៦សន្លឹក។

## ២. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ២.១. ការជួយសង្គ្រោះជនរងគ្រោះ

- **អង្គការសម្ព័ន្ធចាប់ដៃ** ក្នុងឆមាសទី១ ឆ្នាំ២០១៨នេះ បានសហការជាមួយ ស្ថានទូត ស្ថានតំណាងនៅបរទេស ដើម្បីជួយ អន្តរាគមន៍ ពលរដ្ឋខ្មែរដែលរងគ្រោះដោយអំពើជួញដូរមនុស្ស ឲ្យវិលត្រឡប់មកស្រុកកំណើតវិញ ក្នុងនោះ៖ (១)ប្រទេសចិន បានជួយធ្វើអន្តរាគមន៍សង្គ្រោះនារីខ្មែររងគ្រោះ ដោយសារចាញ់បោកមេខ្យល់បង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ ជាមួយបុរសជនជាតិចិន ចំនួន៦០ករណី។ (២)ស្ថានទូតខ្មែរប្រចាំនៅប្រទេសម៉ាឡេស៊ី បានជួយធ្វើអន្តរាគមន៍សង្គ្រោះនារីខ្មែររងគ្រោះដោយសារ ចាញ់បោកមេខ្យល់ជួញដូរកម្លាំងពលកម្ម ចំនួន០៥ករណី បានត្រឡប់មកស្រុកកំណើតវិញ។ (៣)សហជីពពលករកម្ពុជា

បានជួយសង្គ្រោះនារីខ្មែរចំនួន០១រូប នៅប្រទេសអារ៉ាប៊ីសាអូឌីត។ (៤)ស្ថានទូតខ្មែរប្រចាំនៅប្រទេសឡាវ បានជួយសង្គ្រោះពលករខ្មែរចំនួន០១រូប បានត្រឡប់មកស្រុកកំណើតវិញ។ (៥)បានជួយកុមាររីរងគ្រោះដោយរំលោភសេពសន្ថវៈ ចំនួន ២៣ករណី និងការជួញដូរកុមារ ចំនួន ០៣ករណី។ (៦)បានជួយមនុស្សពេញវ័យរងគ្រោះដោយរំលោភសេពសន្ថវៈ ចំនួន ០១ករណី។

- **អង្គការ RATANAK អន្តរជាតិ** ប្រចាំឆ្នាំ២០១៨នេះ បានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការ IJM និងអង្គការសម្ព័ន្ធចាប់ដៃ បានទទួលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាចំនួន **២៩**លើក មាន មនុស្សសរុប ចំនួន **៦៣**នាក់(ស្ត្រី) ក្នុងនោះ៖ ប្រទេសចិនចំនួន **៤៣**នាក់ ប្រទេសវៀតណាម ចំនួន **១៤**នាក់ (ជាករណីជួញដូរផ្លូវភេទ) និងប្រទេសម៉ាឡេស៊ីចំនួន **០៣**នាក់ ប្រទេសកម្ពុជាចំនួន **០៣**នាក់ (ជាករណីជួញដូរកម្លាំងពលកម្ម)។
- **អង្គការ IOM** បានសហការជាមួយស្ថានទូត ស្ថានតំណាងនៅបរទេស បានជួយពលរដ្ឋខ្មែរដែលរងគ្រោះដោយអំពើជួញដូរមនុស្ស ឲ្យវិលត្រឡប់មកស្រុកកំណើតវិញសរុបចំនួន **១១០**នាក់(ស្ត្រី **៣៥**នាក់) ក្នុងនោះ៖ ប្រទេសចិនចំនួន **០៤**នាក់ ម៉ាឡេស៊ីចំនួន **៤៩**នាក់ ឥណ្ឌូនេស៊ីចំនួន **០៧**នាក់ និងប្រទេសសថៃចំនួន **៥០**នាក់។

## ខ.២. ការជួយឧបត្ថម្ភជនរងគ្រោះ

- **អង្គការសម្ព័ន្ធចាប់ដៃ** ក្នុងឆមាសទី១ ឆ្នាំ២០១៨នេះ អង្គការសម្ព័ន្ធចាប់ដៃ បានជួយឧបត្ថម្ភ និងផ្តល់សេវាផ្សេងៗ ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស មានដូចខាងក្រោម៖បានជួយឧបត្ថម្ភដល់នារីខ្មែររងគ្រោះ ដោយចាញ់បោកមេខ្យល់ ដូចជា៖ (១)បានទិញសំបុត្រយន្តហោះពីប្រទេសម៉ាឡេស៊ី មកប្រទេសកម្ពុជាវិញ ចំនួន០១លើក (ករណីជួញដូរ) ប្រទេសចិន ចំនួន២៨លើក (ករណីចាញ់បោកមេខ្យល់បង្ខំឲ្យរៀបអាពាហ៍ពិពាហ៍) និងប្រទេសវៀតណាម ចំនួន០១លើក (ករណីជួញដូរផ្លូវភេទ) បានវិលត្រឡប់មកស្រុកកំណើតវិញ។ (២)តាមដាន និងប្រឹក្សាផ្តល់យោបល់ផ្លូវចិត្ត ដើម្បីស្តារនីតិសម្បទាបាន ចំនួន៣០ករណី។ (៣)ផ្តល់សេវាកម្មផ្លូវច្បាប់ជាមេធាវី ដល់ជនរងគ្រោះបាន ចំនួន២៤ករណី។ (៤)បានផ្តល់សេវាពិនិត្យសុខភាព ដល់អនីតិជន ចំនួន២ករណី។ (៥)បានផ្តល់គ្រឿងឧបភោគបរិភោគមួយចំនួនដល់ជនរងគ្រោះ។
- **អង្គការរតនៈ អន្តរជាតិ** ក្នុងប្រចាំឆ្នាំនេះ សហការជាមួយ**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** (អគ្គនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស) និងអង្គការសម្ព័ន្ធចាប់ដៃ អង្គការ IJM បានទទួលជនរងគ្រោះពីប្រទេសចិន និងវៀតណាម ចំនួន **៥៦**នាក់(ករណីជួញដូរផ្លូវភេទ) ប្រទេសម៉ាឡេស៊ី ចំនួន **០៣**នាក់ នៅក្នុងប្រទេសកម្ពុជា **០៣**នាក់(ករណីជួញដូរកម្លាំងពលកម្ម) និងបាន៖ (១)ផ្តល់សេវាឲ្យជនរងគ្រោះ និងជូនទៅសម្ភាសនៅស្នងការដ្ឋាននគរបាល ជាពិសេសបានផ្តល់កន្លែងស្នាក់នៅ ផ្តល់អាហារ៣ពេលក្នុង១ថ្ងៃ ផ្តល់ទឹកដោះគោឆៅ កញ្ចប់ជំនួយបន្ទាន់ មុននឹងសមាហរណកម្ម ការពិនិត្យសុខភាព ការព្យាបាលជំងឺផ្លូវចិត្ត ជួយសម្របសម្រួលសេវាផ្នែកច្បាប់ ជួយទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់អតិថិជនទៀតផង។ (២) ធ្វើសមាហរណកម្មជនរងគ្រោះចំនួន **១៥**លើក មនុស្សចំនួន **៥៦**នាក់ ក្នុងនោះករណីជួញដូរផ្លូវភេទ **៥៤**នាក់ (ស្រី) និងករណីជួញដូរពលកម្ម **០២**នាក់ ទៅស្រុកកំណើតវិញ។ (៣)ធ្វើ

សមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ ចំនួន ០១នាក់(ស្រី) ទៅខេត្តកណ្ដាល និងបានទទួលសេវាកម្មរយៈពេលវែងក្នុងកម្មវិធីសិទ្ធផលរតនៈ តាំងពីឆ្នាំ២០១៧មក។

- **អង្គការ សាម៉ារីតាន់ភឺស** ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៨នេះ បានធ្វើការសម្ភាសន៍ និងផ្ដល់សេវាផ្សេងៗ ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស មានដូចខាងក្រោម៖ (១)បានសម្ភាសន៍ជនចំណាកស្រុកដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះដោយប្រើទម្រង់បន្ទាន់ និងទម្រង់វែង ចំនួន **៧៤៩**នាក់ ស្រី **២៦៧**នាក់។ (២)ផ្ដល់ជំនួយដល់ពលករចំណាកស្រុកដែលបានបញ្ជូនមកដល់ទីកន្លែងមុខទីស្នាក់ការច្រកទ្វារ ចំនួន **៨៦៤**នាក់ រួមមាន៖ ចែកខិត្តប័ណ្ណផ្សព្វផ្សាយស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ជនចំណាកស្រុក ចំនួន **៧៧៣**នាក់ ស្រី **២៨៦**នាក់។ ផ្ដល់ទឹក និងអាហារសម្រន់ ចំនួន **៨៦៤**នាក់ ស្រី **៣២៨**នាក់ កុមារ **៤៣**នាក់។ ផ្ដល់សោហ៊ុយធ្វើដំណើរទៅខេត្តកំណើតវិញ ចំនួន **៦០**នាក់ ស្រី **១២**នាក់ ។ ផ្ដល់ទូរស័ព្ទដៃ **៤០**នាក់ ស្រី **០៤**នាក់ ស៊ីមកាត **៥០**នាក់ ស្រី **០៥**នាក់ ដើម្បីសួរសុខទុក្ខអំពីការធ្វើដំណើរ និងកាតបញ្ចូលទឹកប្រាក់ **៤៧**នាក់ ស្រី **១១**នាក់។ ទំនាក់ទំនង សួរសុខទុក្ខតាមប្រព័ន្ធអេឡិចត្រូនិកអំពីការធ្វើដំណើរទៅស្រុកកំណើតវិញ ចំនួន **១៦០**នាក់ ស្រី **៥១**នាក់។ ផ្ដល់អាហារ ចំនួន **៦៥**នាក់ ស្រី **០៤**នាក់ កុមារ **០៣**នាក់ ការស្នាក់នៅ **១៧**នាក់ ស្រី **០៤**នាក់ និងផ្ដល់ស្បែកជើង សម្លៀកបំពាក់ ក្រមារ ចំនួន **១៦**នាក់។
- **អង្គការ IOM** ជនទេសន្តរប្រវេសន៍ដែលត្រឡប់មកវិញចំនួន **១១០**នាក់ ត្រូវបានផ្ដល់ជំនួយដោយផ្ទាល់មកដល់ក្នុងរាជធានីភ្នំពេញ និងតាមរយៈមជ្ឈមណ្ឌលធនធានចំណាកស្រុកអង្គការ IOM នៅប៉ោយប៉ែត។ នៅពេលមកដល់រាជធានីភ្នំពេញជនទេសន្តរប្រវេសន៍ទាំងអស់ត្រូវបានគេផ្ដល់នូវ៖

- កន្លែងស្នាក់នៅសម្ភារៈអនាម័យ សំលៀកបំពាក់នៅពេលចាំបាច់ ការថែទាំវេជ្ជសាស្ត្រនិងចិត្តសាស្ត្រ ប្រាក់ឧបត្ថម្ភអាហារប្រចាំថ្ងៃ អង្ករ ត្រីខ ទូរស័ព្ទ ស៊ីមកាត និងថវិកាធ្វើដំណើរ។
- រួមទាំងការបញ្ជូនទៅរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលសម្រាប់ជំនួយផ្ទាល់ និងសមាហរណកម្មបន្ត។
- ក្នុងអំឡុងពេលស្នាក់នៅ ជនចំណាកស្រុកនៅភ្នំពេញសម្រាប់ការពិនិត្យសុខភាព អង្គការ IOM បានផ្ដល់នូវសេវាដើម្បីគាំទ្រដល់ការធ្វើសមាហរណកម្មនាពេលអនាគត ការផ្ញើសារ ការធ្វើចំណាកស្រុកមានសុវត្ថិភាព ការថែទាំសុខភាពជាមូលដ្ឋាន និងការផ្ដល់ដំបូន្មានផ្នែកហិរញ្ញវត្ថុ ការអប់រំផ្នែកចិត្តសាស្ត្រដល់ជនរងគ្រោះ និងក្រុមគ្រួសារ។

## ខ.៣. ការជួយផ្នែកសុខភាព៖

- **អង្គការ IOM៖**

- ផ្ដល់សេវាសង្គ្រោះបឋមសម្រាប់ពលករដែលមានបញ្ហាសុខភាពតិចតួចចំនួន **១០៧១**នាក់ ដែលក្នុងនោះរួមមានបុរស **៥០៧**នាក់ ស្ត្រី **៤៨០**នាក់ កុមារ៉ា **៤៥**នាក់ និងកុមារី **៣៩**នាក់។
- ធ្វើការបញ្ជូនពលករដែលមានបញ្ហាសុខភាពធ្ងន់ធ្ងរទៅកាន់មន្ទីរពេទ្យបង្អែកប៉ោយប៉ែតចំនួន **១២**នាក់ ដែលក្នុងនោះរួមមានបុរស **៧**នាក់ ស្ត្រី **៤**នាក់ និងកុមារ៉ា **១**នាក់។

## គ. ការលើកកម្ពស់សមត្ថភាព

### គ.១. ការងារបណ្តុះបណ្តាលក្នុងប្រទេស

**តារាងកម្មវិធីបណ្តុះបណ្តាល**

| ឈ្មោះអង្គការ | សកម្មភាព | ចំនួនវគ្គ | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|
| IOM | បើកវគ្គបណ្តុះបណ្តាល៖ (១)ស្តីពីចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្សទៅដល់យុវជនក្លឹបរបស់អង្គការទស្សនៈពិភពលោក និងក្រុមយុវជនមកពីខេត្តចំនួន៣៖ បាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប សរុបចំនួន១៨នាក់ (ស្រី ១១នាក់)។ (២)ស្តីពីការចូលរួមចំណែកលុបបំបាត់អំពើទាសភាព និងជួញដូរមនុស្ស (CREST) ទៅដល់ទីភ្នាក់ងារជ្រើសរើសពលករឯកជន នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប អ្នកចូលរួមចំនួន៦៦នាក់ (ស្រី២២នាក់)។ (៣) ស្តីពីការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត ស្តីពីអំពើជួញដូរមនុស្ស ការកំណត់អត្តសញ្ញាណជនរងគ្រោះនិងកិច្ចការពារទិន្នន័យ ដល់មន្ត្រីមកពីនាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងសមាហរណកម្មរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អ្នកចូលរួមចំនួន ៣៨នាក់ (ស្រី ១៥នាក់) នៅរាជធានីភ្នំពេញ សហការជាមួយអង្គការ IJM។ (៤) ស្តីពីចិត្តសង្គម ដល់សហគមន៍ដើមរបស់ពលករ រួមទាំងជនរងគ្រោះដោយអំពើជួញដូរមនុស្ស ពលករងាយរងគ្រោះ និងក្រុមគ្រួសារ អ្នកចូលរួមចំនួន១០២នាក់(ស្រី៦២នាក់) សហការជាមួយមន្ត្រីបង្គោលរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប។ | ០៧ | ២២៤ | ១១០ |
| សម្ព័ន្ធចាប់ដៃ | បើកវគ្គបណ្តុះបណ្តាល៖ (១)ស្តីពីការចូលរួមរបស់កុមារដល់បុគ្គលិករបស់ខ្លួន និងអាជ្ញាធរមូលដ្ឋាន អ្នកចូលរួមចំនួន ១២នាក់ (ខេត្តសៀមរាប និងខេត្តបាត់ដំបង)។ (២)គ្រូបង្គោលស្តីពី គោលការណ៍ណែនាំ សម្រាប់ការចូលរួមរបស់កុមារ ដល់សមាជិកអង្គការចំនួន០៥អង្គការ និង មន្ត្រី ក.ជ.ក នៃមន្ទីរសង្គមកិច្ចខេត្តសៀមរាប សហការជាមួយមន្ត្រីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានអ្នកចូលរួមចំនួន២៥នាក់ (ស្រី១៥នាក់)។ | ០២ | ៤២ | ១៥ |
| អង្គការ Cambodia ACTs | បើកវគ្គបណ្តុះបណ្តាល៖ (១)ស្តីពី "យន្តការនៃការបញ្ជូនពលករចំណាកស្រុក និងកុមារ និងរបៀបរៀបចំសកម្មភាពផ្សព្វផ្សាយពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព" ដល់បណ្តាញការពារថ្នាក់ឃុំ នៅឃុំគោលដៅរបស់ស្រុកព្រះស្តេច ស្រុកពាមជរ ខេត្តព្រៃវែង និងស្រុកកំរៀង ខេត្តបាត់ដំបង មានអ្នកចូលរួមចំនួន១០២នាក់ (ស្រី២៣នាក់)។ (២)ដល់សមាជិកអង្គការរបស់អង្គការ សម្ព័ន្ធអង្គការមិនមែន រដ្ឋាភិបាល ប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា អំពីការបង្កើតបណ្តាញការពារកុមារ មានសមាជិកចំនួន១៨នាក់ (ស្រី០៦នាក់) ។ | ០២ | ១២០ | ២៩ |
| RATANAK International | - បើកវគ្គបណ្តុះបណ្តាលបំណិនជីវិត និង ជំនាញទន់ ការចុះទស្សនកិច្ចវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងប្រចាំខែរយៈពេលទទួលវគ្គបណ្តុះបណ្តាល ដល់ស្ត្រីរងគ្រោះ។ | ០១ | ០៥ | ០៥ |
| **សរុប** | | **១០** | **២៦៦** | **១៣០** |

## គ.២. ការងារសិក្ខាសាលាក្នុងប្រទេស

### តារាងទិន្នន័យនៃកម្មវិធីសិក្ខាសាលា

| ឈ្មោះអង្គការ | សកម្មភាព | ចំនួនលើក | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|
| IOM | រៀបចំសិក្ខាសាលា៖ (១)ស្តីពីការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត ដល់មន្ត្រីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អ្នកផ្តល់សេវាមណ្ឌលសុខភាព អង្គការដៃគូ ប្រធានសហគមន៍និងវិស័យឯកជន នៅរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប សិក្ខាកាមសរុបចំនួន ១៤៣នាក់ (ស្រី ៤៩នាក់)។ (២)ស្តីពីចំណាកស្រុកដោយសុវត្ថិភាព និងជំនាញទន់ ដល់ភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ អ្នកផ្តល់សេវា អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន សិក្ខាកាមសរុបចំនួន ៥០នាក់ (ស្រី ១៨នាក់) ដោយបានសហការជាមួយក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ នៅខេត្តសៀមរាប។ | ០២ | ១៩៣ | ៦៧ |
| | សរុប | ០២ | ១៩៣ | ៦៧ |

## គ.៣. ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ

| | |
|---|---|
| អង្គការសម្ព័ន្ធចាប់ដៃ | បានរៀបចំកិច្ចប្រជុំពិភាក្សាចែករំលែកចំណេះដឹង បទពិសោធន៍លើប្រធានបទ ស្តីពីការជួញដូរមនុស្ស ការធ្វើចំណាកស្រុកខុសច្បាប់ និងការអភិវឌ្ឍន៍កុមារ សហការជាមួយអាជ្ញាធរ មន្ត្រីសង្គមកិច្ច និងមន្ត្រីកិច្ចការនារីចំនួន៣០នាក់ ដើម្បីជួយជនរងគ្រោះ។ |
| អង្គការ IOM | សហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ UNACT, WINROCK, UNWOMEN Chab Dai បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ក្នុងចំណោមប្រទេសបញ្ជូនទាំងបី កម្ពុជា ឡាវ និងភូមា អំពីតួនាទីរបស់ប្រទេសបញ្ជូនក្នុងការពង្រឹងកិច្ចការពារពលករពីហានិភ័យនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស អ្នកចូលរួមមកពីតំណាងពីអង្គការជាតិ អន្តរជាតិ អង្គការសហប្រជាជាតិនៃប្រទេសទាំង៣ នៅខេត្តសៀមរាប។ |
| អង្គការ RATANAK International | **ប្រធានគ្រប់គ្រងករណីបានចូលរួមកិច្ចប្រជុំពិភាក្សា៖** (១)ជាមួយអង្គការដៃគូដូចជា អង្គការ IJM អង្គការសម្ព័ន្ធចាប់ដៃ ស្តីពីសេវាកម្មកត្តាប្រឈម និងការបញ្ជូនជនមាតុភូមិនិវត្តន៍។ (២)បូកសរុបការងារត្រីមាសទី១ ស្តីពីកត្តាប្រឈម និងវឌ្ឍនៈភាពការងារជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការដៃគូ។ (៣)ស្តីពីកិច្ចសហការ និងវឌ្ឍនៈភាពការងារជាមួយអង្គការដៃគូមិនមែនរដ្ឋាភិបាល និងការងារពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ។ (៤)ជាអ្នកសម្របសម្រួលអ្នកថែទាំជាមួយអង្គការសម្ព័ន្ធចាប់ដៃ ស្តីពីលទ្ធផលនៃការស្រាវជ្រាវរបស់គម្រោងមេអំបៅ។ និងជាមួយអង្គការ UNDP ស្តីពីអន្តរទំនាក់ទំនងរវាងអង្គការដៃគូ។ (៥)អ្នកសម្របសម្រួលពង្រឹងសេដ្ឋកិច្ច បានចូលរួមប្រជុំជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារស្តីពីការសហការ និងភាពជាដៃគូ។ (៦)បានចូលរួមសិក្ខាសាលា ប្រចាំឆ្នាំជាមួយអង្គការសម្ព័នចាប់ដៃ ស្តីពីការពង្រឹងការទំនាក់ទំនង និងការសហការការងារជាមួយអង្គការដៃគូដទៃទៀត។ (៧)បានចូលរួមសិក្ខាសាលា ជាមួយអង្គការ IOM ស្តីពីការគាំទ្រផ្លូវចិត្តដល់អនីតិជនដែលធ្វើចំណាកស្រុក។ (៨)បានចូលរួមសិក្ខាសាលា ស្តីពីប្រព័ន្ធប្រមូលព័ត៌មានដៃគូអភិវឌ្ឍលើសេវាកម្មសម្រាប់ជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ។ |

# ក្រមុងរូបភាព

# សកម្មភាព និងលទ្ធផលការងារ

# ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# ឆ្នាំ ២០១៨

## របស់

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

( គ.ជ.ប.ជ )

# ការប្ដេជ្ញាចិត្តរបស់ប្រមុខរដ្ឋាភិបាល












ភាពសប្បាយរីករាយរបស់កម្មករ កម្មការិនី ពេលបានជួប **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងបានទទួលនូវគោលនយោបាយលើកកម្ពស់ស្ថានភាពជីវភាពសម្រាប់កម្មករ កម្មការិនី









ពិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# កិច្ចប្រជុំត្រួតពិនិត្យរបាយការណ៍១០ខែ ឆ្នាំ២០១៨
# និងពិធីប្រកាសចូលកាន់តំណែង អគ្គលេខាធិការ គ.ជ.ប.ជ











# វេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី២នៅកម្ពុជា ពិធីសូត្រធម៌ អធិដ្ឋាន និងបញ្ជូន សារដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើប




កម្មវិធីប្រារព្ធធ្វើឡើងនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌល និងពិពណ៌កោះពេជ្រ









# ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៨





ថ្នាក់ដឹកនាំក្នុងរាជរដ្ឋាភិបាលជាតំណាងអង្គការនីតិបញ្ញត្តិ អង្គការនីតិប្រតិបត្តិ តុលាការ កងកម្លាំងគ្រប់ប្រភេទ អង្គទូតនានា អង្គការសង្គមស៊ីវិល អាជ្ញាធរដែនដី តំណាងនិកាយសាសនា សាស្ត្រាចារ្យសិស្ស និស្សិត បានចូលរួមក្នុងកម្មវិធីនេះយ៉ាងច្រើនកុះករ (ប្រមាណ៣០០០នាក់)











# ការពង្រឹងសមត្ថភាព និងចែករំលែកបទពិសោធន៍ជាមួយអន្តរជាតិ (កិច្ចប្រជុំក្រៅប្រទេស)



កិច្ចប្រជុំនៃការអនុម័ត កត្តិកាសញ្ញាពិភពលោក ស្ដីពី **"ទេសន្តរប្រវេសន៍នៅប្រទេសម៉ារ៉ុក"** នៅប្រទេសម៉ារ៉ុក




សេចក្ដីថ្លែងការណ៍ក្នុងឱកាសនៃការអនុម័ត កត្តិកាសញ្ញាពិភពលោក ស្ដីពី **"ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់"** រៀបចំដោយអង្គការសហប្រជាជាតិ (ខែធ្នូ ឆ្នាំ២០១៨)




សន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី៧ ស្ដីពីការរត់ពន្ធ ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន នៅប្រទេសឥណ្ឌូនេស៊ី



ដំណើរទស្សនកិច្ចនៅបណ្ដាខេត្តភាគនិរតីនៃព្រះរាជាណាចក្រកម្ពុជា របស់គណប្រតិភូនៃកិច្ចព្រមព្រៀងទ្វេភាគី កម្ពុជា-ចិន ក្នុងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស




កិច្ចប្រជុំទ្វេភាគីកម្ពុជា-ថៃស្ដីពី **"ទេសន្តរប្រវេសន៍ការងារ និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស"** នៅប្រទេសថៃ



សមាជិកក្នុងកិច្ចប្រជុំ GFMD បានចែករំលែក និងពិភាក្សា អំពីជំហានបន្ត សម្រាប់ការអនុវត្ត GCM និងភាពប្រឈម



ការជួបសំណេះសំណាលជាមួយវេជ្ជបណ្ឌិតកូរ៉េដែលផ្ដល់ការពិនិត្យព្យាបាលជូនប្រជាពលរដ្ឋខ្មែរកំពុងស្នាក់នៅសិក្សានិងធ្វើការនៅសាធារណរដ្ឋកូរ៉េខាងត្បូង



កិច្ចប្រជុំប្រទេសបញ្ជូនពលករទាំងបី៖ កម្ពុជា ឡាវ មីយ៉ាន់ម៉ា (នៅខេត្តសៀមរាប)

# វគ្គបណ្តុះបណ្តាលជំនាញរបស់មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ (នៅសាធារណរដ្ឋកូរ៉េ)


















# បេសកកម្មដោះស្រាយបញ្ហាពលករនេសាទ នៅខេត្តត្រាត ប្រទេសថៃ










# កិច្ចប្រជុំក្រុមការងារចម្រុះ ត្រៀមសកម្មភាពទទួលពលករដែលត្រូវបានបញ្ជូនត្រឡប់ពីប្រទេសថៃតាមច្រកអន្តរជាតិប៉ោយប៉ែត











ជនរងគ្រោះដែលត្រូវបានបញ្ជូនត្រលប់ ក្នុងស្ថានភាព
ពិការរាងកាយ និងខួរក្បាល



ការជួយសង្គ្រោះពលករ ដែលត្រូវបានបញ្ជូនត្រឡប់នៅ
ច្រកអន្តរជាតិ ប៉ោយប៉ែត



ការចុះសួរសុខទុក្ខពលកររងគ្រោះដែលទើបបញ្ជូនត្រលប់
ពីប្រទេសថៃ

# សកម្មភាពក្រុមការងារអន្តរក្រសួងទាំង៦

## ក្រុមការងារយុត្តិធម៌



ឯកឧត្តម អង្គវង្ស វឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារកិច្ចការយុត្តិធម៌










កិច្ចប្រជុំវាយតម្លៃក្នុងគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (AAPTIP)

# ក្រុមការងារការពារជនរងគ្រោះ



ឯកឧត្តម វង់ សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធានក្រុមការងារការពារជនរងគ្រោះ





ការជួបសំណេះសំណាលជាមួយក្រុមគ្រួសារជនរងគ្រោះ ពីប្រទេសសូម៉ាលី



ការប្រគល់ថវិកាជូនជនរងគ្រោះ ពីប្រទេសសូម៉ាលី



ការទទួលពលករបញ្ជូនត្រលប់ពីក្រៅប្រទេស



ការតាមដានស្ថានភាពគ្រួសារស្ត្រីពពោះជំនួស នៅសហគមន៍

# ក្រុមការងារបង្ការទប់ស្កាត់



ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានក្រុមការងារបង្ការទប់ស្កាត់



កិច្ចប្រជុំក្រុមការងារបង្ការទប់ស្កាត់ ដឹកនាំដោយឯកឧត្តម ស សុខា រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា











# ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ




លោកជំទាវវេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ




សន្និបាតអាស៊ីអាគ្នេយ៍៖ "កិច្ចសម្របសម្រួលថ្នាក់តំបន់ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម"



កិច្ចប្រជុំពិនិត្យរបាយការណ៍ប្រចាំត្រីមាស របស់ក្រុមការងារ សហប្រតិបត្តិការជាតិ និងអន្តរជាតិ




កិច្ចប្រជុំប្រទេសក្នុងមហាអនុតំបន់មេគង្គស្តីពី **"ការរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សាធារណរដ្ឋប្រជាមានិតចិន"**




កិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-អឺរ៉ុបលើកទី១០ នៅទីក្រុងប្រ៊ុចសែល ប្រទេសប៊ែលហ្ស៊ិក



វគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងបណ្តាញការងាររបស់ប្រទេស អាស៊ានលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# ក្រុមការងារអនុវត្តច្បាប់




ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ប្រធានក្រុមការងារអនុវត្តច្បាប់















# ករណីស៊ីឈ្នួលពពោះជំនួសក្នុងនីតិវិធីតុលាការ វិធានការអប់រំ និងសង្គ្រោះ



ករណីបង្ក្រាបអំពើពពោះជំនួសនៅទីក្រុងភ្នំពេញ



ក្រុមស្ត្រីជាប់ចោទ ក្នុងករណីពពោះជំនួស





ការសួរសុខទុក្ខដល់ស្ត្រីស៊ីឈ្នួលពពោះជំនួស ដែលត្រូវបានសង្គ្រោះបន្ទាន់ក្នុងពេលសម្រាល

# ក្រុមការងារទេសន្តរប្រវេសន៍











កិច្ចប្រជុំទ្វេភាគីកម្ពុជា-ថៃស្តីពី ទេសន្តរប្រវេសន៍ការងារ និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស





ការជួយសង្គ្រោះពលករ ដែលត្រូវបានបញ្ជូនត្រឡប់នៅច្រកអន្តរជាតិ ប៉ោយប៉ែត

# អនុស្សរណៈនៃការយោគយល់គ្នា និងការអនុវត្ត



កិច្ចប្រជុំប្រចាំឆ្នាំលើកទី២ កម្ពុជា-ចិន ក្នុងកិច្ចសហការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៨ នៅសណ្ឋាគារភ្នំពេញ



ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង គ.ជ.ប.ជ និងសមាគមឈានឆាយ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ



ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង គ.ជ.ប.ជ និងរវាងអង្គការ GVC នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ





កិច្ចប្រជុំពិភាក្សាការងាររវាងគ.ជ.ប.ជ និង ក្រុមការងារនាយកដ្ឋានស៊ើបអង្កេតពិសេស (Department of Special Investigation: DSI)



តំណាងក្រុមការងារវាយតម្លៃ របស់អង្គការ IOM ចូលជួបពិភាក្សាការងារ និង វឌ្ឍនភាព នៃកិច្ចសហប្រត្តិបត្តិការក្នុងឆ្នាំ២០១៨ រវាង គ.ជ.ប.ជ និង អង្គការ IOM



ជំនួបពិភាក្សាការងារពាក់ព័ន្ធ និងករណីពពោះជំនួស ជាមួយតំណាងការិយាល័យឧត្តមស្នងការ ទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ប្រចាំប្រទេសកម្ពុជា

# កិច្ចសហការជាមួយអង្គការដៃគូអភិវឌ្ឍន៍






សិក្ខាសាលាស្តីពី៖ "ការបង្ការ និងការឆ្លើយតបចំពោះអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍"






សិក្ខាសាលាស្តីពី៖ "ការតាមដានត្រួតពិនិត្យ ការអនុវត្តក្រមប្រតិបត្តិយេនឌ័រក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស"










សិក្ខាសាលាស្តីពី៖ "ការណែនាំពីការប្រើប្រាស់ Mobile App របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
សម្រាប់ស្វែងរកទីតាំងអង្គការដៃគូអភិវឌ្ឍន៍ ដែលផ្តល់សេវាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស"

# សមិទ្ធិផលការងារព័ត៌មានវិទ្យា របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ




គេហទំព័រផ្លូវការណ៍របស់
គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស



ទំព័រហ្វេសប៊ុកផ្លូវការណ៍របស់
គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស




បណ្ណាសាររបស់
គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស







ប្រព័ន្ធទំនាក់ទំនង Telegram Messenger ប្រើប្រាស់
ក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

Mobile App សម្រាប់ងាយស្រួលដល់ប្រជាពលរដ្ឋស្វែងរក
ទីតាំងអង្គការដៃគូអភិវឌ្ឍន៍ ដែលផ្តល់សេវាពាក់ព័ន្ធទៅនឹង
អំពើជួញដូរមនុស្ស (ជួយជនរងគ្រោះ)

# សកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រោមជាតិ























































រួមគ្នាបង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ
និងការពារដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស
អបអរសាទរ! ទិវាជាតិ លើកទី១២ ប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៨


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
អបអរសាទរ
ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ២០១៧

























របាយការណ៍នេះអាចទាញយកពី គេហទំព័រ

**www.ncct.gov.kh**

បោះពុម្ពដោយ៖

**ថវិកាជាតិ**

បោះពុម្ពនៅ រោងពុម្ពអន្តរជាតិ ចំនួន១០០០ក្បាល